ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២

## ឆ្នាំ២០២៥



## មាតិកា

* * *


**អារម្ភកថា**.....i

**អក្សរកាត់**.....iv

**ខ្លឹមសារសង្ខេប**.....vii

**ផ្នែកទី១ - របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០២៥**

I- **ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច**.....១

១- បរិស្ថានសេដ្ឋកិច្ចពិភពលោក.....១

២- កំណើនសេដ្ឋកិច្ច.....៣

៣- ស្ថានភាពអតិផរណា.....៨

៤- ស្ថានភាពអត្រាប្ដូរប្រាក់.....១០

៥- ស្ថានភាពជញ្ជីងទូទាត់.....១១

៦- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ.....១៥

II- **ការគ្រប់គ្រងរូបិយវត្ថុ**.....១៦

១- ការផ្គត់ផ្គង់រូបិយវត្ថុ.....១៦

២- អត្រាប្រាក់បម្រុងកាតព្វកិច្ច.....១៦

៣- មូលបត្រអាចជួញដូរបាន.....១៧

៤- ប្រតិបត្តិការផ្ដល់សន្ទនីយភាព.....១៨

III- **ប្រព័ន្ធធនាគារនៅកម្ពុជា**.....២០

១- ស្ថានភាពទូទៅ.....២០

២- ស្ថិរភាពហិរញ្ញវត្ថុ.....២៣

៣- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ.....២៥

៤- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ.....២៨

IV- **ការផ្គត់ផ្គង់សេវាធនាគារកណ្ដាល**.....៣២

១- ប្រព័ន្ធទូទាត់សងប្រាក់.....៣២

២- សេវាទូទាត់សងប្រាក់.....៣៥

៣- សេវាគ្រប់គ្រងគណនី.....៣៨

៤- សេវាគ្រប់គ្រងមូលបត្រ.....៣៩

៥- ការគ្រប់គ្រងចរាចរណ៍ធនបត្រ.....៤១

V- **ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**.....៤៣

១- ការងារត្រួតពិនិត្យបុគ្គលរាយការណ៍.....៤៣

២- ការងារវិភាគប្រតិបត្តិការ ..... ៤៤
៣- កិច្ចសហប្រតិបត្តិការ ..... ៤៤
៤- ការពង្រឹងសមត្ថភាព ..... ៤៦
**VI- កិច្ចសហប្រតិបត្តិការអន្តរជាតិ** ..... ៤៧
១- កិច្ចសហប្រតិបត្តិការពហុភាគី ..... ៤៧
២- កិច្ចសហប្រតិបត្តិការទ្វេភាគី ..... ៥០
**VII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិកម្ពុជា** ..... ៥៣
១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល ..... ៥៣
២- ការអភិវឌ្ឍធនធានមនុស្ស ..... ៥៤
៣- ការងារសវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ..... ៥៨
៤- សាខាធនាគារជាតិនៃកម្ពុជា ..... ៥៩
៥- សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ..... ៦១
**VIII- ទំនាក់ទំនងសាធារណៈ** ..... ៦២
១- ការផ្សព្វផ្សាយតាមបណ្តាញសង្គម ..... ៦២
២- ការផ្សព្វផ្សាយប្រព័ន្ធបាគង ..... ៦២
៣- ការលើកកម្ពស់ការយល់ដឹងអំពីប្រាក់រៀល ..... ៦៣
៤- កិច្ចសហការជាមួយសមាគម និងស្ថាប័នផ្សេងៗក្នុងការងារផ្សព្វផ្សាយ ..... ៦៤
៥- ការរួមចំណែកក្នុងការងារសង្គម ..... ៦៤
៦- សារមន្ទីរព្រះស្រីឦសានវរ្ម័ន ..... ៦៦
**សេចក្តីសន្និដ្ឋាន** ..... ៦៩

**ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៥**
១- ការអនុវត្តនយោបាយរូបិយវត្ថុ ..... ៧២
២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ..... ៧២
៣- ការងារអភិវឌ្ឍទីផ្សារប្តូរប្រាក់ ..... ៧៣
៤- ប្រព័ន្ធទូទាត់សងប្រាក់ ..... ៧៣
៥- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ..... ៧៣
៦- ការងារបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ ..... ៧៤
៧- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ..... ៧៦
៨- ការងារប្រតិបត្តិការទីផ្សាររូបិយវត្ថុ ..... ៧៦
៩- ការងារសេវាធនាគារ ..... ៧៦

១០- ការងារគ្រប់គ្រងសាច់ប្រាក់ ................................................ ៧៧
១១- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ................................................ ៧៧
១២- ការគ្រប់គ្រងសាខា ................................................ ៧៨
១៣-ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស................................................ ៧៨
១៤- កិច្ចសហប្រតិបត្តិការអន្តរជាតិ ................................................ ៧៨
១៥- ការងារស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច ................................................ ៧៨
១៦- ការងារស្ថិតិ. ................................................ ៧៩
១៧-ការងារស្ថិរភាពហិរញ្ញវត្ថុ ................................................ ៧៩
១៨- ការងារទំនាក់ទំនងសាធារណៈ................................................ ៨០
១៩- ការងារសារមន្ទីរ ស.ស.រ. ................................................ ៨០
២០- ការងារវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ................................................ ៨០

**ផ្នែកទី៣ - ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ ១ តារាង ១ -តារាងជម្រើសសូចនាករសេដ្ឋកិច្ច ................................................ ៨១
ឧបសម្ព័ន្ធ ២ តារាង ២ -ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ................................................ ៨២
ឧបសម្ព័ន្ធ ៣ តារាង ៣ -ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ).... ៨៣
ឧបសម្ព័ន្ធ ៤ តារាង ៤ -ស្ថិតិស្ថានភាពធនាគារកណ្តាល ................................................ ៨៤
ឧបសម្ព័ន្ធ ៥ តារាង ៥ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត................................................ ៨៥
ឧបសម្ព័ន្ធ ៦ តារាង ៦ -ស្ថិតិស្ថានភាពគ្រឹះស្ថានទទួលប្រាក់បញ្ញើ................................................ ៨៦
ឧបសម្ព័ន្ធ ៧ តារាង ៧ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ................................................ ៨៧
ឧបសម្ព័ន្ធ ៨ តារាង ៨ -ស្ថិតិស្ថានភាពគ្រឹះស្ថានហិរញ្ញវត្ថុ................................................ ៨៨
ឧបសម្ព័ន្ធ ៩ តារាង ៩ -ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច................................................ ៨៩
ឧបសម្ព័ន្ធ ១០ តារាង ១០ -ប្រាក់បញ្ញើនៅគ្រឹះស្ថានធនាគារ................................................ ៩០
ឧបសម្ព័ន្ធ ១១ តារាង ១១ -ជញ្ជីងទូទាត់ប្រទេសកម្ពុជា................................................ ៩១
ឧបសម្ព័ន្ធ ១២ តារាង ១២ -បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
ពីឆ្នាំ២០២១ - ខែមីនា ២០២៥ ................................................ ៩២
ឧបសម្ព័ន្ធ ១៣ បញ្ជីលេខទូរសព្ទទំនាក់ទំនងអំពីចម្ងល់និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់
សេវាហិរញ្ញវត្ថុ ................................................ ៩៤

# អារម្ភកថា

ពិភពលោកបន្តប្រឈមនឹងភាពមិនប្រាកដប្រជាកាន់តែខ្លាំង ដោយសារនិន្នាការកើនឡើងនៃគោលនយោបាយគាំពារនិយម ជម្លោះប្រដាប់អាវុធ និងភាពតានតឹងភូមិសាស្ត្រនយោបាយ។ ការអនុវត្តគោលនយោបាយគាំពារនិយម បានបង្កឱ្យមានភាពរង្គោះរង្គើដល់គោលការណ៍ពហុភាគីនិយម ដែលអាចនាំទៅរកការពង្រីកសង្គ្រាមពាណិជ្ជកម្ម និងការធ្លាក់ចុះពាណិជ្ជកម្មអន្តរជាតិ។ ទន្ទឹមនេះ ជម្លោះប្រដាប់អាវុធ ដែលកំពុងរីករាលដាលនៅមជ្ឈិមបូព៌ានិងតំបន់ផ្សេងទៀត បានបង្កជាសោកនាដកម្ម និងផលវិបាករយៈពេលវែងដល់សង្គមនិងសេដ្ឋកិច្ច។ ក្នុងបរិការណ៍នេះ ការអនុវត្តនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការវិនិយោគ ក៏ដូចជាពាណិជ្ជកម្មនានា មានភាពមិនច្បាស់លាស់ ដែលធ្វើឱ្យល្បឿនកំណើនសេដ្ឋកិច្ចពិភពលោកថយចុះជាងការរំពឹងទុក។ ចំណែកឯ អត្រាអតិផរណាបានបន្តថយចុះ ប៉ុន្តែក៏នៅតែប្រឈមនឹងការកើនឡើងវិញដែរ ដែលបានធ្វើឱ្យធនាគារកណ្ដាលមួយចំនួនបន្ថយអត្រាការប្រាក់គោលសន្សឹមៗ ហើយធនាគារកណ្ដាលផ្សេងទៀតបន្តរក្សាជំហរនយោបាយរូបិយវត្ថុនៅដដែល។

កម្ពុជាដែលជាប្រទេសបើកទូលាយនិងមានសមាហរណកម្មទៅក្នុងតំបន់និងពិភពលោកក៏ប្រឈមនឹងភាពមិនច្បាស់លាស់នេះដែរ ជាពិសេសទៅលើពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគ និងទេសចរណ៍ ដែលអាចមានឥទ្ធិពលបន្តទៅកាន់វិស័យផ្សេងទៀតក្នុងសេដ្ឋកិច្ច។ ទោះយ៉ាងណាកំណើនក្នុងឆមាសទី១នេះ មិនទាន់ទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ទេ ដោយសារភាពរឹងមាំនៃមូលដ្ឋានសេដ្ឋកិច្ចកម្ពុជា និងខណៈពេលដែលឥទ្ធិពលនៃពន្ធគយបដិការរបស់សហរដ្ឋអាមេរិក និងជម្លោះព្រំដែនកម្ពុជា-ថៃ នៅមានកម្រិតនៅឡើយ ប៉ុន្តែផលប៉ះពាល់អាចកើតមាននាឆមាសទី២ ឆ្នាំ២០២៥។ ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តនយោបាយរូបិយវត្ថុ អភិវឌ្ឍប្រព័ន្ធធនាគារនិងគរពូនទុនបម្រុងអន្តរជាតិ ប្រកបដោយភាពប្រុងប្រយ័ត្ននិងបត់បែន សំដៅរក្សាស្ថិរភាពថ្លៃ ស្ថិរភាពហិរញ្ញវត្ថុ និងគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជាក់ស្ដែង អត្រាប្ដូរប្រាក់ត្រូវបានរក្សាឱ្យមានស្ថិរភាពល្អប្រសើរ ក្នុងពេលដែលអត្រាការប្រាក់បានថយចុះសន្សឹមៗ ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការរក្សាស្ថិរភាពថ្លៃ។ គួររំលេចថា លំហូរមូលធនមកកាន់ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍបន្តប្រឈមនឹងការរឹតត្បិត និងបានធ្វើឱ្យអត្រាប្ដូរប្រាក់នៅតាមបណ្ដាប្រទេសនានាមានការប្រែប្រួលខ្លាំង។ ក្នុងបរិការណ៍ដែលកម្ពុជាមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ការបន្តរក្សាបានស្ថិរភាពអត្រាប្ដូរប្រាក់និងកម្រិតទាបនៃអតិផរណា បានរួមចំណែកយ៉ាងសំខាន់ដល់ការការពារអំណាចទិញរបស់ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ការពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិន ក៏ដូចជាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា។

ជាមួយគ្នានេះ ការពង្រឹងជាលំដាប់នូវតួនាទីរបស់ប្រាក់រៀលនៅក្នុងចរាចរ ការសន្សំ និងការវិនិយោគ មានសារៈសំខាន់ណាស់ ដើម្បីបន្តពង្រឹងភាពធន់នៃសេដ្ឋកិច្ច ក្នុងពេលដែលតម្លៃប្រាក់ដុល្លារអាមេរិកកាន់តែមានការប្រែប្រួលខ្លាំងនៅលើទីផ្សារអន្តរជាតិ និងបង្កជាបញ្ហាប្រឈមដល់ការប្រើប្រាស់សម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ។ នៅក្នុងតំបន់រូបិយវត្ថុជាតិត្រូវបានលើកកម្ពស់ជាបន្តបន្ទាប់ ដើម្បីជំរុញពាណិជ្ជកម្ម និងពង្រឹងយន្តការឱ្យខ្ចីទៅវិញទៅមកសម្រាប់បង្ការ និងដោះស្រាយវិបត្តិ នៅក្នុងក្របខ័ណ្ឌអាស៊ាននិងអាស៊ាន+៣។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តលើកកម្ពស់បន្ថែមទៀតនូវការប្រើប្រាស់ប្រាក់រៀលក្នុងកម្រិតសមស្រប និងបន្តពង្រីកការតភ្ជាប់ប្រព័ន្ធទូទាត់ ជាមួយប្រទេសក្នុងតំបន់ និងជាមួយក្រុមហ៊ុនផ្ដល់សេវាទូទាត់អន្តរជាតិ។

ចំពោះប្រព័ន្ធធនាគារ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តរក្សាបានភាពធន់ទប់ទល់នឹងការប៉ះទង្គិចនាពេលកន្លងមក។ ទោះយ៉ាងណា កំណើនឥណទានបានបន្តមានល្បឿនយឺត ដោយសារការប្រុងប្រយ័ត្នជាងមុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងតម្រូវការឥណទានទាបក្នុងវិស័យមួយចំនួន ក្នុងស្ថានភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក។ ឆ្លើយតបនឹងបញ្ហានេះ ធនាគារជាតិនៃកម្ពុជាបន្តសហការយ៉ាងជិតស្និទ្ធជាមួយនឹងសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ក្នុងការគាំទ្រការផ្តល់ឥណទានទៅកាន់វិស័យសំខាន់ៗ ការបន្ធូរបន្ថយអត្រាការប្រាក់ ការរៀបចំឥណទានឡើងវិញ ការសម្រួលលក្ខខណ្ឌឥណទាន ជាពិសេសទៅកាន់វិស័យអចលនទ្រព្យ កសិកម្ម ព្រមទាំងសហគ្រាសធុនមីក្រូ តូច និងមធ្យម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ ដើម្បីគ្រប់គ្រងហានិភ័យពីភាពមិនច្បាស់លាស់ ការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ និងទស្សនៈអនាគតត្រូវបានបន្តពង្រឹងជាលំដាប់ រួមទាំងការបន្តដាក់ចេញបទប្បញ្ញត្តិប្រុងប្រយ័ត្នសមស្រប ខណៈដែលក្របខ័ណ្ឌកិច្ចការពារប្រាក់បញ្ញើអតិថិជនក៏កំពុងត្រូវបានអភិវឌ្ឍ ក្នុងគោលដៅពង្រឹងកិច្ចការពារអ្នកដាក់ប្រាក់បញ្ញើនិងរក្សាជំនឿទុកចិត្តមកលើប្រព័ន្ធធនាគារ។

ភាពធន់នៃប្រព័ន្ធធនាគារត្រូវបានគាំទ្រមិនអាចខ្វះបាន ពីការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងឌីជីថល និងការបង្កលក្ខណៈអំណោយផលដល់ការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដូចជា ការបើកគណនីធនាគារ និងការប្រើប្រាស់ការទូទាត់អេឡិចត្រូនិក។ កន្លងមក យុទ្ធនាការផ្សព្វផ្សាយនិងបណ្តាញសង្គម រួមទាំងកម្មវិធីនៅតាមរាជធានី-ខេត្ត ត្រូវបានធ្វើឡើងយ៉ាងសកម្ម ដើម្បីបញ្ជ្រាបការយល់ដឹងដល់ប្រជាពលរដ្ឋ អំពីសារៈសំខាន់នៃការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងបញ្ចៀសពីការឆបោកផ្សេងៗតាមប្រព័ន្ធអនឡាញ។ ម្យ៉ាងទៀត ក្នុងគោលដៅគាំទ្រការអភិវឌ្ឍប្រកបដោយចីរភាព និងកាត់បន្ថយហានិភ័យពីការប្រែប្រួលអាកាសធាតុ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីរៀបចំប្រព័ន្ធវគ្គីករសាស្រ្តស្តីពីហិរញ្ញប្បទានប្រកបដោយចីរភាព និងផែនទីមគ្គុទេសក៍សម្រាប់ហិរញ្ញវត្ថុបៃតងនៅកម្ពុជា ដែលឯកសារទាំងនេះនឹងក្លាយជាមូលដ្ឋានដ៏សំខាន់ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចបង្កើនហិរញ្ញប្បទាននិងការវិនិយោគបៃតង។

ក្នុងស្ថានភាពនៃភាពមិនប្រាកដប្រជាខ្ពស់ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុទាំងក្នុងក្របខ័ណ្ឌពិភពលោក និងតំបន់ តាមរយៈការគាំទ្រការបង្កើនកូតារបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ការបង្កើនទំហំអាស៊ានស្វប់ និងការពង្រឹងយន្តការពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃក្នុងតំបន់អាស៊ាន+៣។ ការពង្រឹងសមាហរណកម្មនិងយន្តការការពារហានិភ័យទាំងនេះនឹងពង្រឹងការបង្ការវិបត្តិ ក៏ដូចជាការដោះស្រាយវិបត្តិ ប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា។

ដោយឡែក ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គឺជាបញ្ហាដែលកំពុងគំរាមកំហែងដល់សន្តិសុខ ស្ថិរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍសេដ្ឋកិច្ច ទាំងក្នុងតំបន់និងសកលលោក។ ក្នុងន័យនេះ ដើម្បីការពារសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែរឹងមាំ និងទទួលបាននូវជំនឿទុកចិត្តពីសាធារណជន វិនិយោគិនជាតិ និងអន្តរជាតិ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានបន្តកិច្ចខិតខំប្រឹងប្រែងអនុវត្តការងារជាប្រចាំ រួមមាន ការវិភាគរបាយការណ៍ប្រតិបត្តិការ ការត្រួតពិនិត្យបុគ្គលរាយការណ៍ និងការសហការជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ លើការងារ

ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ទន្ទឹមនេះ ស.ហ.ក. បានបន្តពង្រឹងការអភិវឌ្ឍធនធានមនុស្សជាប្រចាំ ពាក់ព័ន្ធនឹងការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងស្តង់ដារបស់ក្រុមការងារហិរញ្ញវត្ថុ ក្នុងបរិបទនៃការរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងនវានុវត្តន៍ហិរញ្ញវត្ថុ។

នាឆមាសទី២ ឆ្នាំ២០២៥ សេដ្ឋកិច្ចកម្ពុជានឹងអាចបន្តប្រឈមភាពមិនប្រាកដប្រជាពីខាងក្រៅខ្ពស់ ខណៈដែលវិស័យសេដ្ឋកិច្ចចម្បងៗក្នុងស្រុក នៅមិនទាន់បានងើបឡើងស្មើសាច់នៅឡើយ។ ការអនុវត្តគោលនយោបាយគាំពារនិយម ដែលមានឥទ្ធិពលដោយផ្ទាល់មកលើសេដ្ឋកិច្ចកម្ពុជា និងការថយចុះកំណើននៃសេដ្ឋកិច្ចពិភពលោក ជាពិសេសនៅក្នុងប្រទេសជាដៃគូវិនិយោគពាណិជ្ជកម្ម ក៏ដូចជាទេសចរណ៍ នឹងអាចដាក់សម្ពាធបន្ថែមលើវិស័យដែលពឹងផ្អែកលើតម្រូវការខាងក្រៅ ដូចជាការនាំចេញផលិតផលកាត់ដេរ និងវិស័យកម្មន្តសាលដែលទើបលេចឡើង។ ម្យ៉ាងទៀតភាពមិនច្បាស់លាស់លើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ក៏អាចបង្កើនហានិភ័យដល់ស្ថិរភាពហិរញ្ញវត្ថុកម្ពុជាផងដែរ តាមរយៈភាពមិនប្រាកដប្រជានៃលំហូរមូលធនចូលមកកម្ពុជា ការប្រែប្រួលអត្រាការប្រាក់និងការថយថ្លៃនៃប្រាក់ដុល្លារអាមេរិក។ ទន្ទឹមនេះ ហានិភ័យខាងក្នុងនៃសេដ្ឋកិច្ច ដែលរួមមានការងើបឡើងយឺតនៃវិស័យសំណង់និងអចលនទ្រព្យ បញ្ហាបំណុលក្រុមគ្រួសារនិងក្រុមហ៊ុន-សហគ្រាស ការកើនឡើងនៃឥណទានមិនដំណើរការ នឹងធ្វើឱ្យការគ្រប់គ្រងស្ថិរភាពហិរញ្ញវត្ថុ និងការគាំទ្រកំណើនពីវិស័យហិរញ្ញវត្ថុ អាចមានបញ្ហាប្រឈមច្រើន។

ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជានឹងបន្តរួមចំណែកគាំទ្រគោលនយោបាយអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល តាមរយៈការរក្សាស្ថិរភាពថ្លៃ និងការអភិវឌ្ឍប្រព័ន្ធធនាគារ ដែលគាំទ្រដល់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងការតាមដាននិងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានគ្រប់ជ្រុងជ្រោយ ព្រមទាំងដាក់ចេញវិធានការបុរេសកម្មនិងមានសហ-ថាមភាពជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីទប់ទល់នឹងហានិភ័យនានា សំដៅបន្តរក្សាបានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាដែលតែងតែផ្តល់ការគាំទ្រ និងមន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានខិតខំបំពេញតួនាទី-ភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមគ្នាកសាងប្រព័ន្ធធនាគារឱ្យមានការអភិវឌ្ឍជឿនលឿន និងប្រកបដោយចីរភាព។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនាពេលកន្លងមក។ ខ្ញុំជឿជាក់យ៉ាងមុតមាំថាសមាជិកក្រុមប្រឹក្សាភិបាល មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ និងភាគីពាក់ព័ន្ធនានានឹងបន្តគាំទ្រ និងរួមចំណែកសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងប្រព័ន្ធធនាគារ ដែលនឹងបម្រើជាប្រយោជន៍រួមសម្រាប់ជាតិមាតុភូមិនិងប្រជាជនកម្ពុជា។

**ទេសាភិបាល**

**ជា សិរី**

# អក្សរកាត់

| | | |
|---|---|---|
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ស.ម.ធ | សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា | |
| ស.ស.រ. | សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន | SOSORO – Cambodia's Museum of Economy and Money |
| ស.ហ.ក. | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit (CAFIU) |
| អ.គ.ល.ក. | អគ្គលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា | Commercial Gambling Management Commission of Cambodia General Secretarial (C.G.M.C) |
| អ.ស.ហ. | អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | |
| ACGM | កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន | ASEAN Central Banking Governor Meeting |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AFMGM | កិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន | ASEAN Finance Minister and Central Bank Governor Meeting |
| AFTN | បណ្តាញអ្នកជំនាញហិរញ្ញវត្ថុអាស៊ាន+៣ | ASEAN+3 Finance Think-Tank Network |
| AMRO | អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ | ASEAN+3 Macroeconomic Research Office |
| APG | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| ASA | អាស៊ានស្វប់ | ASEAN Swap Arrangement |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| AUSTRAC | មជ្ឈមណ្ឌលវិភាគនិងរាយការណ៍ប្រតិបត្តិការអូស្ត្រាលី | Australian Transaction Reports and Analysis Centre |
| Bakong LVPs | ប្រព័ន្ធទូទាត់តម្លៃធំបាគង | Bakong Large Value Payment System |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| CAR | អនុបាតភាពគ្រប់គ្រាន់នៃដើមទុន | Capital Adequacy Ratio |
| CamDX | សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច | Cambodia Data Exchange |
| CBDCs | រូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាល | Central Banking Digital Currency |
| CIFRS | ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា | Cambodian International Financial Reporting Standards |
| CLEO Platform | ថ្នាលផ្លាស់ប្តូរព័ត៌មាន | |
| CMIM | ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ | Chiang Mai Initiative Multilateralization |

| | | |
|---|---|---|
| CPWG | ក្រុមការងារគ្រប់គ្រងថ្នាលផ្លាស់ប្តូរព័ត៌មាន CLEO | CLEO Platform Working Group |
| CSE | ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ | Child Sexual Exploitation |
| CTR | របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ | Cash Transaction Report |
| E-Library | បណ្ណាល័យអេឡិចត្រូនិក | Electronic-Library |
| ECOFEL | កម្មវិធីសិក្សា Egmont Certificate of FIU Excellence and Leadership | Egmont Certificate of FIU Excellence and Leadership |
| ECP | កម្មវិធីសិក្សា ECOFEL | ECOFEL Certificate Program |
| ERIA | វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា | Economic Research Institute for ASEAN and East Asia |
| ESG | បរិស្ថាន សង្គម និងអភិបាលកិច្ច | Environmental, Social, and Governance |
| ESW | ប្រព័ន្ធ Egmont Secure Web | Egmont Secure Web |
| EWS | ប្រព័ន្ធព្រមាន | Early Warning System |
| FATF | ក្រុមការងារហិរញ្ញវត្ថុ | Financial Action Task Force |
| FICG | ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ | Financial Intelligence Consultative Group |
| FinTech | បច្ចេកវិទ្យាហិរញ្ញវត្ថុ | Financial Technology |
| FSIs | សូចនាករភាពរឹងមាំហិរញ្ញវត្ថុ | Financial Soundness Indicators |
| FSI Connect | កម្មវិធីសិក្សារបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Institute Connect |
| IBS | វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ | Institute for Banking Studies |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ | International Finance Corporation |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| ITRS | ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ | International Transaction Reports |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន | Japan International Cooperation Agency |
| KDIC | សាជីវកម្មធានារ៉ាប់រងប្រាក់បញ្ញើប្រទេសកូរ៉េ | Korea Deposit Insurance Corporation |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-Providing Collateralized Operation |
| LCR | អនុបាតគ្របខ័ណ្ឌសន្ទនីយភាព | Liquidity Coverage Ratio |
| MDI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | Microfinance Deposit-Taking Institutions |
| MEC | កិច្ចប្រជុំគណៈកម្មការវាយតម្លៃអញ្ញមញ្ញ | Mutual Evaluation Committee |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | Microfinance Institutions |
| MIT | វិទ្យាស្ថានបច្ចេកវិទ្យា Massachusetts | Massachusetts Institute of Technology |

| | | |
|---|---|---|
| MLF | ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី | Marginal Lending Facility |
| MSMEs | សហគ្រាសធុនមីក្រូ តូច និងមធ្យម | Micro, Small and Medium Enterprises |
| NBCP | ថ្នាលធនាគារជាតិនៃកម្ពុជា | National Bank of Cambodia Platform |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| NPL | ឥណទានមិនដំណើរការ | Non-Performing Loan |
| OBS | ប្រព័ន្ធធនាគារអេឡិចត្រូនិក | Online Banking System |
| PED | សមិទ្ធផលអាទិភាពសេដ្ឋកិច្ច | Priority Economic Development |
| PFMI | គោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ | Principles for Financial Market Infrastructures |
| ROA | អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Asset |
| ROE | អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក | Return on Equity |
| RPPI | សន្ទស្សន៍ថ្លៃលំនៅឋាន | Residential Property Price Indices |
| SEACEN | មជ្ឈមណ្ឌលស៊ាសិន | South East Asian Central Banks |
| SREP | វិធីសាស្ត្រត្រួតពិនិត្យស្រេប | Supervisory Review and Evaluation Process |
| STR | របាយការណ៍ប្រតិបត្តិការសង្ស័យ | Suspicious Transaction Report |
| UMS | ប្រព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ | University Management System |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ | United Nations Development Programme |
| UPI | ក្រុមហ៊ុនអន្តរជាតិយូញៀនផេ | UnionPay International |
| UTC | គម្រោង Universal Trusted Credentials | Universal Trusted Credentials |
| WB | ធនាគារពិភពលោក | World Bank |
| WEDC | មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពជាស្ត្រី | Women's Enterprise Development Center |

# ខ្លឹមសារសង្ខេប

សេដ្ឋកិច្ចពិភពលោកបាននិងកំពុងរងផលប៉ះពាល់ពីភាពមិនច្បាស់លាស់កាន់តែខ្លាំងនៃគោលនយោបាយគាំពារនិយម ការកើនឡើងជម្លោះប្រដាប់អាវុធ និងភាពតានតឹងភូមិសាស្ត្រនយោបាយ។ បញ្ហានេះបានបន្ថយល្បឿនកំណើនសេដ្ឋកិច្ចពិភពលោក ទន្ទឹមពេលដែលអតិផរណានៅបណ្តាប្រទេសជាច្រើនបានបន្តថយចុះមកជិតកម្រិតគោលដៅ ដែលបានអនុញ្ញាតឱ្យធនាគារកណ្តាលភាគច្រើនអាចកាត់បន្ថយអត្រាការប្រាក់គោល ដើម្បីជួយទ្រទ្រង់កំណើន។

ក្នុងស្ថានភាពនេះ សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងភាពមិនច្បាស់លាស់ផងដែរ ក៏ប៉ុន្តែនៅឆមាសទី១នេះ កំណើននៅបន្តសម្រេចបានក្នុងអត្រា ៥,៩% ដែលគាំទ្រដោយការកើនឡើងនៃវិស័យកម្មន្តសាល ទេសចរណ៍ និងកសិកម្ម។ ចំណែកឯ អត្រាអតិផរណាមានកម្រិត ៣,៥% ដែលបណ្តាលមកពីកំណើនថ្លៃក្រុមម្ហូបអាហារ និងអតិផរណាស្នូល ខណៈថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានថយចុះ។ អត្រាប្តូរប្រាក់មានកម្រិតជាមធ្យម ៤.០១១ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានឡើងថ្លៃ ១,៦% ធៀបនឹងគ្រាដូចគ្នាឆ្នាំ២០២៤។ សមតុល្យជញ្ជីងទូទាត់មានអតិរេក ២៧៥,៥ លានដុល្លារអាមេរិក ដែលគាំទ្រជាចម្បងដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិបានកើនឡើងដល់ ២៤,៨ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង ៧,៥ខែនៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់។

ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់ និងបានរួមចំណែកគាំទ្រសកម្មភាពសេដ្ឋកិច្ច ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនទ្រព្យសកម្ម ៧,៣% កំណើនឥណទាន ២,៩% និងកំណើនប្រាក់បញ្ញើ ១៤,៥%។ គួររំលេចថា កំណើនឥណទានបន្តមានកម្រិតទាប ដូចឆ្នាំមុនដែរ ហើយឥណទានមិនដំណើរការបានកើនឡើងបន្តិចដល់ ៨,៣%។ ក្នុងស្ថានភាពនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានធ្វើសំវិធានធនគ្រប់គ្រាន់ ព្រមទាំងរក្សាបានភាពរឹងមាំនៃដើមទុននិងកម្រិតខ្ពស់នៃសន្ទនីយភាព ដោយអនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានកម្រិត ២២,៨% សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៣១,៦% សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (ធៀបនឹងអត្រាអប្បបរមាកំណត់ដោយបទប្បញ្ញត្តិ ១៥%) ហើយអនុបាតសន្ទនីយភាពមានកម្រិត ១៨៥% សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (ធៀបនឹងអត្រាអប្បបរមាកំណត់ដោយបទប្បញ្ញត្តិ ១០០%)។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងការត្រួតពិនិត្យ តាមដាននិងវិភាគការវិវត្តនៃហានិភ័យនានា ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយនឹងភាគីពាក់ព័ន្ធ ក្នុងការជំរុញការផ្តល់ឥណទាន ការបន្ធូរបន្ថយអត្រាការប្រាក់ និងការរៀបចំឥណទានឡើងវិញ។

បរិយាបន្នហិរញ្ញវត្ថុត្រូវបានលើកកម្ពស់ជាប្រចាំ ដែលបានបង្កើនការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដល់ប្រជាជននៅតាមទីជនបទ ស្ត្រី និងសហគ្រាសធុនមីក្រូ តូច និងមធ្យម ដោយចំនួនអ្នកដាក់ប្រាក់បញ្ញើបានកើនដល់ ១៥,៧ លាននាក់ និងចំនួនអ្នកប្រើប្រាស់សេវាឥណទានកើនដល់ ៤,៥ លាននាក់។ ម្យ៉ាងទៀត ការប្រើប្រាស់សេវាទូទាត់សងប្រាក់ឌីជីថលបន្តមាននិន្នាការកើនឡើងយ៉ាងឆាប់រហ័ស ដោយចំនួនគណនីអ៊ីវ៉ាឡេតបានកើនដល់ ២២,៩ លានគណនី ហើយប្រតិបត្តិការនៃសេវាទូទាត់សងប្រាក់ឌីជីថលជារៀលបានកើនដល់ ២៣៥,៤ ទ្រីលានរៀល និងជាដុល្លារអាមេរិកបានកើនដល់ ១៧៧,៥ ប៊ីលានដុល្លារអាមេរិក នៅក្នុងឆមាសទី១នេះ។ បច្ចុប្បន្ន ប្រាក់រៀលក្នុងចរាចរណ៍មានចំនួន ១៨,១ ទ្រីលានរៀល ដែលបានកើនឡើង ៥,៣% ខណៈដែលដុល្លារូបនីយកម្ម

បន្តមានកម្រិតខ្ពស់ ដោយអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅស្មើនឹង ៨៥,៩%។ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានបន្តរួមចំណែកបម្រើសេវាជូនមន្ទីរ-អង្គភាពរបស់រាជរដ្ឋាភិបាល និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងបានសម្រួលដល់ការប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែក និងលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធទូទាត់បាគង ជូនដល់សាធារណជនដែលបានគាំទ្រដល់ការរីកចម្រើនសេដ្ឋកិច្ចតាមមូលដ្ឋាន។ ម៉្យាងទៀត សារមន្ទីរព្រះស្រីឰសានវរ្ម័នបានរួមចំណែកលើកកម្ពស់ចំណេះដឹងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទន្ទឹមនឹងការរៀបចំសិក្ខាសាលា និងការចុះផ្សព្វផ្សាយពីសេវាធនាគារជាមួយភាគីពាក់ព័ន្ធ ទាំងដោយផ្ទាល់និងតាមបណ្តាញសង្គម។ នៅឆមាសទី១ ឆ្នាំ២០២៥នេះ អ្នកទស្សនាសារមន្ទីរព្រះស្រីឰសានវរ្ម័នបានកើនឡើងដល់ ២៥.៣៣៨រូប ដែលក្នុងនោះមានទាំងភ្ញៀវជាតិ និងអន្តរជាតិ ជាពិសេសសិស្ស-និស្សិតមកពីបណ្តារាជធានី-ខេត្តនានា។

ការងារពង្រឹងអភិបាលកិច្ច និងការបន្តអភិវឌ្ឍធនធានមនុស្ស ជាការងារអាទិភាពសម្រាប់គាំទ្រការរីកចម្រើនរបស់ធនាគារជាតិនៃកម្ពុជា។ ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចបានលើកកម្ពស់ការប្រតិបត្តិតាម ការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ច។ បច្ចុប្បន្ន មន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជាសរុបមានចំនួន ២.០២៦រូប ហើយសមត្ថភាពជំនាញនិងឯកទេសកម្ម ត្រូវបានអភិវឌ្ឍជាលំដាប់ តាមរយៈការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស និងការសិក្សាតាមប្រព័ន្ធអនឡាញ។ លើសពីនេះ វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារបានបន្តពង្រឹងតួនាទីក្នុងការអភិវឌ្ឍចំណេះដឹងនិងជំនាញក្នុងវិស័យធនាគារ ដោយមាននិស្សិតកំពុងសិក្សាចំនួន ៥០៨រូប។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែកជំរុញសមាហរណកម្មវិស័យហិរញ្ញវត្ថុ និងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ ស្របតាមគោលដៅសហគមន៍សេដ្ឋកិច្ចអាស៊ាន។

ដោយឡែក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានបន្តបំពេញមុខងារ-ភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងការពង្រឹងសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា។ ស.ហ.ក. បានបន្តទទួលរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងរបាយការណ៍ប្រតិបត្តិការសង្ស័យពីបុគ្គលរាយការណ៍ដោយមានការកើនឡើង ១៣,១% និង ២១,៨% រៀងគ្នា និងបានភ្ជាប់ប្រព័ន្ធរាយការណ៍ដល់បុគ្គលរាយការណ៍ចំនួន ៣៧។ ស.ហ.ក. បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះបុគ្គលរាយការណ៍ចំនួន ២៤ ផ្តល់អនុសាសន៍កែតម្រូវចំណុចខ្វះខាត និងទទួលស្គាល់មន្ត្រីប្រតិបត្តិចំនួន ៧៧ រូប ព្រមទាំងពង្រឹងការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាលើកកម្ពស់ការយល់ដឹង ជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ និងបុគ្គលរាយការណ៍ អំពីច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងស្តង់ដាអន្តរជាតិ។ ទន្ទឹមនេះ ស.ហ.ក. បានពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្រុក និងក្រៅប្រទេស ព្រមទាំងបានចូលរួមប្រជុំ និងផ្តល់ធាតុចូលជូនក្រុមលេខាធិការដ្ឋាន APG និង FATF ក្រុម Egmont និង FICG។ ស.ហ.ក. បានបន្តការសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២។

នៅឆមាសទី២ ឆ្នាំ២០២៥ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងអាចថមថយល្បឿនកំណើន ដោយសារការប្រឈមនឹងហានិភ័យពីខាងក្រៅកាន់តែខ្លាំង ជាពិសេសនិន្នាការគាំពារនិយម និងភាពតានតឹងភូមិសាស្ត្រនយោបាយពិភពលោកនិងតំបន់ ដែលអាចប៉ះពាល់ដល់ការនាំចេញ វិនិយោគផ្ទាល់បរទេស និងទេសចរណ៍នៅកម្ពុជា។ ចំណែកឯ អត្រាអតិផរណាត្រូវបានព្យាករថានឹងថយចុះមកកម្រិតទាបវិញ។ ស្ថិតក្នុងបរិការណ៍នេះ នយោបាយរូបិយវត្ថុនឹងត្រូវបន្តអនុវត្តប្រកបដោយភាពបត់បែននិងប្រុងប្រយ័ត្ន ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ និងអត្រាប្តូរប្រាក់ ដែលនឹង

គាំទ្រដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងភាពធន់របស់ប្រព័ន្ធធនាគារ ជាមួយនឹងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីបន្តរួមចំណែកគាំទ្រសកម្មភាពសេដ្ឋកិច្ច ក្នុងពេលដែលការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នឹងចូលរួមលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ ប្រព័ន្ធការពារប្រាក់បញ្ញើ ក៏កំពុងត្រូវបានអភិវឌ្ឍ ដើម្បីពង្រឹងបន្ថែមទៀតនូវទំនុកចិត្តសាធារណជនលើប្រព័ន្ធធនាគារ ស្របពេលដែលសេចក្តីព្រាងប្រព័ន្ធវដ្តករសាស្ត្រស្តីពីហិរញ្ញវត្ថុប្រកបដោយចីរភាព និងផែនទីមគ្គុទ្ទេសក៍សម្រាប់ហិរញ្ញវត្ថុបៃតងនៅកម្ពុជា កំពុងត្រូវបានរៀបចំ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

# ផ្នែកទី១-របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០២៥

# I- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

## ១- បរិស្ថានសេដ្ឋកិច្ចពិភពលោក

សេដ្ឋកិច្ចពិភពលោកបន្តប្រឈមនឹងភាពតានតឹងភូមិសាស្ត្រនយោបាយ ផលវិបាកដែលសេសសល់ពីវិបត្តិកូវីដ-១៩ គួបផ្សំនឹងការកើនឡើងនិន្នាការគាំពារនិយមនៃបណ្ដាប្រទេសនានា។ ទន្ទឹមនេះ ការប្រកាសអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាមេរិកបានធ្វើឱ្យកំណើនសេដ្ឋកិច្ចក្នុងតំបន់នានាមានកម្រិតទាបជាងការរំពឹងទុក។ ជាក់ស្ដែង សហរដ្ឋអាមេរិកមានកំណើនត្រឹម ១,៨% តំបន់អឺរ៉ូ ១,១% និង ចិន ៥,២% ក្នុងត្រីមាសទី២ ឆ្នាំ២០២៥ នេះ។ ជាមួយគ្នានេះ ការកើនឡើងនៃជម្លោះប្រដាប់អាវុធនៅមជ្ឈិមបូព៌ា និងការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ក៏បានប៉ះពាល់ដល់សកម្មភាពពាណិជ្ជកម្មផងដែរ ដោយទំហំពាណិជ្ជកម្មទំនិញអន្តរជាតិត្រូវបានប៉ាន់ស្មានថាថយចុះ -០,២% ។

**ក្រាហ្វ ១៖ កំណើនសេដ្ឋកិច្ចរបស់ប្រទេសមួយចំនួន**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ត្រី.៤ ឆ្នាំ២០២៤ - ត្រី.២ ឆ្នាំ២០២៥ប)




ប្រភព៖ Bloomberg
សម្គាល់៖ ប=ប៉ាន់ស្មាន, ទិន្នន័យកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិននិងសិង្ហបុរីក្នុងត្រីមាសទី២ ឆ្នាំ២០២៥ ជាទិន្នន័យជាក់ស្ដែង

តម្លៃរូបិយប័ណ្ណរបស់ប្រទេសភាគច្រើនបានកើនឡើងធៀបនឹងដុល្លារអាមេរិក ដូចជាប្រាក់ផោនអង់គ្លេសនិងយេនជប៉ុនបានឡើងថ្លៃ ២,៣% និង ២,៤% រៀងគ្នា ស្របពេលដែលរីងហ្គីតម៉ាឡេស៊ីឡើងថ្លៃ ៨% និងបាតថៃ ៨% ដែលបណ្ដាលមកពីការកើនឡើងនៃអតិរេកគណនីចរន្ត[9]។ ចំណែកឯ ប្រាក់វ៉ុនកូរ៉េបានថយថ្លៃ ៥,៣% ដោយសារភាពទន់ខ្សោយនៃសេដ្ឋកិច្ចក្នុងស្រុក។

**ក្រាហ្វ ២៖ អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិក**
(មធ្យម, ឆ្នាំលើឆ្នាំ, ៦ខែ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ដោយឡែក អត្រាអតិផរណារបស់បណ្ដាប្រទេសភាគច្រើននៅមានកម្រិតទាប ដូចជាសហរដ្ឋអាមេរិក ២,៦% តំបន់អឺរ៉ូ ២,២% ហើយចិនមានបរិតផរណា -០,០៦%។ ប្រទេសអាស៊ាន-៥ បន្តមានកម្រិតអតិផរណាក្រោម ៤% ក្នុងនោះ វៀតណាម ៣,៣% ហ្វីលីពីន ១,៨% ម៉ាឡេស៊ី ១,៤% ឥណ្ឌូណេស៊ី ១,២% និង ថៃមានបរិតផរណា ០,៤%។

[9] អតិរេកគណនីចរន្តរបស់ប្រទេសថៃបានកើនឡើងខ្ពស់ដល់ ៨,៩ ប៊ីលានដុល្លារអាមេរិកសម្រាប់រយៈពេល៤ខែដើមឆ្នាំ ២០២៥ (៣,៤ ប៊ីលានដុល្លារអាមេរិកសម្រាប់ត្រីមាសទី១ ឆ្នាំ២០២៥) និង ម៉ាឡេស៊ីកើនដល់ ១៦,៧ ប៊ីលានរីងហ្គីតក្នុងត្រីមាសទី១ ឆ្នាំ២០២៥ (១២,៩ ប៊ីលានរីងហ្គីតត្រីមាសទី៤ ឆ្នាំ២០២៤)។

**ក្រាហ្វ ៣៖ អត្រាអតិផរណាសហរដ្ឋអាមេរិក ចិន និងតំបន់អឺរ៉ូ**
(គិតជាភាគរយ, ឆ្នាំ២០១៩ - ៦ខែ ឆ្នាំ២០២៥)




ប្រភព៖ Trading Economics

**ក្រាហ្វ ៤៖ អត្រាអតិផរណាប្រទេសអាស៊ាន-៥**
(គិតជាភាគរយ, ឆ្នាំ២០១៩ - ៦ខែ ឆ្នាំ២០២៥)




ប្រភព៖ Trading Economics

ការថមថយនៃអតិផរណាខិតកៀកមករកកម្រិតគោលដៅបានអនុញ្ញាតឱ្យធនាគារកណ្តាលភាគច្រើនមានលទ្ធភាពបន្ទាបអត្រាការប្រាក់គោល ដែលក្នុងនោះ ធនាគារកណ្តាលអឺរ៉ុបបានបន្ថយមកត្រឹម ២,១៥% កាណាដា ២,៧៥% ចិន ៣% ខណៈដែលសហរដ្ឋអាមេរិករក្សាអត្រាការប្រាក់គោលដដែល (៤,៥%) ដោយសារភាពមិនច្បាស់លាស់នៃស្ថានភាពសេដ្ឋកិច្ចក្នុងស្រុកនិងគោលនយោបាយពន្ធគយបដិការ។ ទន្ទឹមនេះ ធនាគារកណ្តាលជប៉ុននៅរក្សាអត្រាការប្រាក់គោលដដែល (០,៥%) ដោយសារកម្រិតខ្ពស់នៃអតិផរណា។ ចំពោះតំបន់អាស៊ាន ធនាគារកណ្តាលថៃបានបន្ថយអត្រាការប្រាក់គោលមកត្រឹម ១,៧៥% ហ្វីលីពីនបន្ថយមក ៥,២៥% ឥណ្ឌូណេស៊ីបន្ថយមក ៥,៥% ខណៈម៉ាឡេស៊ី និងវៀតណាមបានរក្សាអត្រាការប្រាក់គោលដដែល ៣% និង ៤,៥% រៀងគ្នា។

**ក្រាហ្វ ៥៖ អត្រាការប្រាក់គោលនៃប្រទេសអភិវឌ្ឍន៍**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែមិថុនា ឆ្នាំ២០២៥)




ប្រភព៖ Trading Economics

**ក្រាហ្វ ៦៖ អត្រាការប្រាក់គោលនៃប្រទេសក្នុងតំបន់អាស៊ី**
(គិតជាភាគរយ, ខែមករា ឆ្នាំ២០២២ - ខែឧសភា ឆ្នាំ២០២៥)




ប្រភព៖ Trading Economics

## ២- កំណើនសេដ្ឋកិច្ច

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ សេដ្ឋកិច្ចកម្ពុជាបានកើន ៥,៩% បើទោះបីជាប្រឈមនឹងភាពមិនច្បាស់លាស់ពីកត្តាខាងក្រៅខ្លាំងក៏ដោយ។ កំណើននេះត្រូវបានគាំទ្រដោយការកើនឡើងនៃវិស័យកម្មន្តសាល ទេសចរណ៍ និងកសិកម្ម ខណៈវិស័យសំណង់និងអចលនទ្រព្យបន្តមានភាពទន់ខ្សោយ។

- វិស័យកម្មន្តសាលបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ដោយមានកំណើន ៩,៥%។ អនុវិស័យកម្មន្តសាលកាត់ដេរត្រូវបានប៉ាន់ស្មានថាកើនឡើង ១០,៨% ស្របពេលដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរកើនឡើង ៨,៥%។ គួររំលេចថា ការនាំចេញផលិតផលកម្មន្តសាល[២] បានកើនឡើងគួរឱ្យកត់សម្គាល់ ១៥,៣% (គិតជាតម្លៃ) នាឆមាសទី១ ឆ្នាំ២០២៥ ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (៨,៧%) ដោយសារការសម្រុកនាំចេញយ៉ាងគំហុកមុនពេលពន្ធគយបដិការត្រូវបានអនុវត្ត។ កំណើននេះគាំទ្រជាចម្បងដោយការនាំចេញផលិតផលកាត់ដេរ[៣] និងផលិតផលដែលកំពុងលេចឡើង ដូចជាសំបកកង់រថយន្ត អំពូលភ្លើង និងខ្សែភ្លើងនិងបង្គុំខ្សែភ្លើង។

**ក្រាហ្វ ៧៖ តម្លៃនិងកំណើនផលិតផលកម្មន្តសាលសរុប**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែមេសា ឆ្នាំ២០២៥)




**សកម្មភាពដំឡើងខ្សែភ្លើង រោងចក្រ យូរ៉ាហាតនេស**
ប្រភព៖ មូលនិធិអភិវឌ្ឍន៍ជំនាញ Skills Development Fund




**ក្រុមហ៊ុនផលិតសំបកកង់ IRONHEAD Tire, Cambodia ខេត្តស្វាយរៀង**
ប្រភព៖ គេហទំព័រ Business Cambodia

[២] មិនរាប់បញ្ចូលមាសនិងផលិតផលកសិកម្ម។

[៣] ផ្នែកវាយនភ័ណ្ឌ សម្លៀកបំពាក់ កាបូប ស្បែកជើង និងផលិតផលពីស្បែក។

**ក្រាហ្វ ៨៖ ភ្ញៀវអន្តរជាតិ**

(ឆមាសទី១ ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ក្រសួងទេសចរណ៍

- វិស័យទេសចរណ៍បន្តមានកំណើន ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃភ្ញៀវអន្តរជាតិនិងទេសចរក្នុងស្រុក។ កំណើននេះត្រូវបានគាំទ្រដោយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងការតភ្ជាប់ជើងហោះហើរត្រង់ជាមួយបណ្តាប្រទេសនានា ក៏ដូចជាការរៀបចំព្រឹត្តិការណ៍ធំៗដែលចូលរួមទាក់ទាញអ្នកទស្សនា។ ភ្ញៀវអន្តរជាតិកើន ៦,២% ដល់ ៣,៤ លាននាក់ ដែលក្នុងនោះ ភ្ញៀវថៃឈរនៅលំដាប់ទី១ (សមាមាត្រ ២៧,៦% នៃភ្ញៀវអន្តរជាតិសរុប) បន្ទាប់មក វៀតណាម (១៨,៤%) និង ចិន (១៧,៤%)។ ភ្ញៀវអន្តរជាតិដែលចូលមកតាមផ្លូវអាកាស (សមាមាត្រ ៤២,៣% នៃភ្ញៀវអន្តរជាតិសរុប) កើន ២៣,៧% និងតាមផ្លូវគោកនិងផ្លូវទឹក (សមាមាត្រ ៥៧,៧%) ថយ -៣,៧%។ ទន្ទឹមនេះ កម្ពុជារំពឹងថានឹងទទួលបានភ្ញៀវអន្តរជាតិសរុបប្រមាណ ៧,២ ទៅ ៧,៥ លាននាក់[៤] នាឆ្នាំ២០២៥ ដែលគាំទ្រជាចម្បងដោយវិធានការសំខាន់ៗរបស់រាជរដ្ឋាភិបាល ជាពិសេសការដាក់ឱ្យដំណើរការអាកាសយានដ្ឋានអន្តរជាតិតេជោ ដែលនឹងអាចទទួលអ្នកដំណើរបានរហូតដល់ ១៣ លាននាក់ក្នុងមួយឆ្នាំក្នុងដំណាក់កាលទី១។ ក្នុងនោះផងដែរចំណូលទេសចរណ៍អន្តរជាតិត្រូវបានប៉ាន់ស្មានថាទទួលបានចំនួន ១,៩ ប៊ីលានដុល្លារអាមេរិក ដែលកើន ៩,១% ធៀបនឹងឆមាសដូចគ្នាឆ្នាំមុន និងចំណូលពីការលក់បណ្ណចូលទស្សនារមណីយដ្ឋានអង្គរទទួលបាន ២៦,៣ លានដុល្លារអាមេរិក[៥] ដែលបានកើន ៨%។

ជាមួយគ្នានេះ ទេសចរក្នុងស្រុកបន្តកើន ៥០,៣% ដល់ ១៤,៦ លាននាក់។ រាជធានីភ្នំពេញឈរនៅលំដាប់ទី១ ជាតំបន់ដែលទទួលទេសចរច្រើនជាងគេដែលមានសមាមាត្រ ៣៨,៤% នៃទេសចរក្នុងស្រុកសរុប និងទី២តំបន់ឆ្នេរ (៣៦,៦%) ខណៈខេត្តសៀមរាបឈរនៅលំដាប់ទី៣ (១៦%) និងតំបន់អេកូទេសចរណ៍ឈរនៅលំដាប់ទី៤ (១,៩%)។

**ក្រាហ្វ ៩៖ ទេសចរក្នុងស្រុក**

(ឆមាសទី១ ឆ្នាំ២០២២ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ក្រសួងទេសចរណ៍

**ក្រាហ្វ ១០៖ ចំណូលភ្ញៀវអន្តរជាតិ**

(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ក្រសួងទេសចរណ៍ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

[៤] របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងទេសចរណ៍។

[៥] ប្រភពពីគ្រឹះស្ថានអង្គរ។



គម្រោងអាកាសយានដ្ឋានអន្តរជាតិតេជោ ដែលគ្រោងនឹងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥

ប្រភព៖ គេហទំព័រ STB Travel & Tours



ព្រឹត្តិការណ៍សមរាត្រី (Equinox) រយៈពេល៣ថ្ងៃកាលពីថ្ងៃទី២១-២៣ ខែមីនា ឆ្នាំ២០២៥

ប្រភព៖ គេហទំព័រក្រសួងទេសចរណ៍

**ក្រាហ្វ ១១៖ ផលស្រូវ**

(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

- វិស័យកសិកម្មបន្តទទួលបានកំណើន ១,២% ដែលគាំទ្រដោយកំណើនផលដំណាំ និងធនធានជលផល។ ផលស្រូវរដូវប្រាំងបានកើន ១០,៩% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (កើន ១២,១%) ដល់ ៤,៣ លានតោន ដែលជាចម្បងដោយសារភាពអំណោយផលនៃអាកាសធាតុ និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ។ ទន្ទឹមនេះ ការកើនឡើងនៃថ្លៃស្រូវ[៦] នាឆ្នាំ២០២៣-២០២៤ ក៏បានរួមចំណែកជំរុញការដាំដុះផងដែរ។ លើសពីនេះ ផ្ទៃដីដាំដុះស្រូវរដូវវស្សាក៏បានកើន ៤,៤% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (-៧,៥%)។

ផលដំរកៅស៊ូកើនឡើង ១,៣% ដល់ ១៩២,៥ ពាន់តោន ដោយសារកំណើនតម្រូវការ ស្របពេលតម្លៃជ័រកៅស៊ូជាមធ្យមបន្តកើនឡើងខ្ពស់ ៣០,១% ដល់ ១.៩៨៦ ដុល្លារអាមេរិក ក្នុង១តោន (១.៥២៣ ដុល្លារអាមេរិក ក្នុង១តោន នាឆមាសទី១ ឆ្នាំ២០២៤)។

ធនធានជលផលបានកើន ១៥,៨% បន្ទាប់ពីថយចុះ -៣,៧% នាគ្រាដូចគ្នាឆ្នាំមុន ដែលក្នុងនោះផលនេសាទទឹកសាបនិងសមុទ្របានកើន ២៣,២% ដែលជាចម្បងដោយសារការពង្រឹងវិធានការទប់ស្កាត់សកម្មភាពនេសាទខុសច្បាប់ ស្របពេលដែលផលវារីវប្បកម្ម[៧] កើន ៦%។

---

[៦] តម្លៃស្រូវ OM5451 បានកើនឡើងខ្ពស់នៅឆ្នាំ២០២៣-២០២៤ ដោយសារបាតុភូត El Niño ប៉ះពាល់ខ្លាំងដល់ដំណាំស្រូវ ដែលនាំឱ្យប្រទេសមួយចំនួន បានអនុវត្តគោលនយោបាយស្ថិរភាពស្បៀងដោយបិទការនាំចេញអង្ករ។ ស្ថានភាពនេះបានបង្កើតឱកាសទីផ្សារ និងជំរុញឱ្យតម្លៃស្រូវកម្ពុជាកើនឡើង។ ទោះយ៉ាងណានាដើមឆ្នាំ២០២៥ តម្លៃបានធ្លាក់ចុះវិញបន្ទាប់ពីរដ្ឋាភិបាលនៃប្រទេសនោះបើកការនាំចេញឡើងវិញ ធ្វើឱ្យទីផ្សារអង្ករសកលមានការប្រកួតប្រជែងខ្ពស់និងវិលទៅរកតម្លៃដើមវិញ។

[៧] វារីវប្បកម្មសំដៅលើការចិញ្ចឹមត្រី បង្គា បង្កង និងកង្កែប។ល។

**ក្រាហ្វ ១២៖ ផលជ័រកៅស៊ូ**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ក្រាហ្វ ១៣៖ អនុវិស័យជលផល**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

- ទោះជាការនាំចូលសម្ភារនិងបរិក្ខារសំណង់កើនឡើងខ្ពស់ វិស័យសំណង់នៅតែបន្តមានកំណើនទាប ០,៧% ដែលគាំទ្រដោយសកម្មភាពសាងសង់សំណង់ឧស្សាហកម្ម និងសំណង់ឯកជន ខណៈសំណង់សាធារណៈមានកំណើនយឺត។ ការនាំចូលសម្ភារនិងបរិក្ខារសំណង់មានកំណើន ៥៥,១% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (២៧,៥%)។ ទន្ទឹមនេះ តម្លៃគម្រោងសំណង់ទទួលបានការអនុម័តកើនឡើង ៣៧,៧% ដែលក្នុងនោះ សំណង់ឧស្សាហកម្ម (សមាមាត្រ ៣៦,៤%) កើន ៩៣,៣% សំណង់លំនៅឋាន (សមាមាត្រ ៥២,៥% នៃតម្លៃគម្រោងសំណង់សរុប) កើន ៨៤% និងសំណង់ផ្សេងៗ (សមាមាត្រ ៩៥,៩%) កើន ៣៩,៨% ស្របពេលសំណង់សាធារណៈ (សមាមាត្រ ៤,១%) កើន ២,៤%។ ទោះយ៉ាងណា លំហូរវិនិយោគផ្ទាល់បរទេសទៅកាន់វិស័យសំណង់បន្តធ្លាក់ចុះ -១៤%។

**ក្រាហ្វ ១៤៖ ការនាំចូលសម្ភារនិងបរិក្ខារសំណង់**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

**ក្រាហ្វ ១៥៖ តម្លៃនិងកំណើនតម្លៃគម្រោងសំណង់**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)



"ស្ពានតេជោសន្តិភាពឬស្សីជ្រុំ" ស្ពានខ្ពស់ជាងគេនៅកម្ពុជា ដំឡើងធ្នឹមបណ្តោយទាំង៩ប្រឡោះរួចរាល់ ខេត្តពោធិ៍សាត់
ប្រភព៖ ទូរទស្សន៍ជាតិកម្ពុជា



ការសាងសង់អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ
ប្រភព៖ airport-technology.com

- វិស័យអចលនទ្រព្យបន្តមានកំណើនទាប ០,៨% ដោយសារការធ្លាក់ចុះនៃថ្លៃ និងទំហំឥណទានសម្រាប់លំនៅឋាន ស្របពេលដែលការវិនិយោគផ្ទាល់បរទេសក្នុងវិស័យនេះធ្លាក់ចុះ។ សន្ទស្សន៍ថ្លៃលំនៅឋាន (RPPI) រួមថយចុះជាមធ្យម -៣,៦%[៨] ដែលក្នុងនោះនៅរាជធានីភ្នំពេញនិងតាមបណ្តាខេត្តបានថយ -៣,៦% និង -៧,១% រៀងគ្នា។ ជាមួយគ្នានេះ ទំហំឥណទានសម្រាប់លំនៅឋានបែងចែកតាមប្រភេទ សមាមាត្រ ៤៨,៦% នៃឥណទានសរុបបានថយចុះប្រមាណ -១៧,២%។

**ក្រាហ្វ ១៦៖ សន្ទស្សន៍ថ្លៃលំនៅឋានកម្ពុជា**
(បម្រែបម្រួលឆ្នាំលើឆ្នាំគិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២១ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែមេសា ឆ្នាំ២០២៥)

**ក្រាហ្វ ១៧៖ ទំហំឥណទានសម្រាប់លំនៅឋាន**
(ឆមាសទី១ ឆ្នាំ២០២១ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែមេសា ឆ្នាំ២០២៥)

[៨] ទិន្នន័យជាក់ស្តែងត្រឹមខែមេសា ឆ្នាំ២០២៥។

### ប្រអប់ ១៖ ការធ្វើអង្កេតទំនុកចិត្តធុរកិច្ច

ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមធ្វើអង្កេតទំនុកចិត្តធុរកិច្ចប្រចាំឆមាស ចាប់តាំងពីឆមាសទី២ ឆ្នាំ២០២៤ ដើម្បីបង្កើតជាសន្ទស្សន៍ទំនុកចិត្តធុរកិច្ច សម្រាប់តាមដាន និងវាយតម្លៃលើការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច និងបរិយាកាសវិនិយោគឱ្យកាន់តែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ។ នាឆមាសទី១ ឆ្នាំ២០២៥ ការអង្កេតនេះត្រូវបានអនុវត្តចាប់ពីថ្ងៃទី១៩ ខែឧសភា ដល់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ និងតាមបណ្តាសាខាខេត្តនៃធនាគារជាតិនៃកម្ពុជា ដោយបែងចែកជា២ផ្នែក៖ i/-ក្រុមហ៊ុន-សហគ្រាសដែលបានចុះបញ្ជី (វិស័យក្នុងប្រព័ន្ធ) និង ii/-អាជីវកម្មដែលមិនបានចុះបញ្ជី (វិស័យក្រៅប្រព័ន្ធ)។ ការអង្កេតវិស័យក្នុងប្រព័ន្ធមានការចូលរួមពីក្រុមហ៊ុន-សហគ្រាសចំនួន ១០៨ នៅរាជធានីភ្នំពេញ និង ៥២៣ នៅតាមបណ្តាខេត្ត ដែលមានបុគ្គលិកចាប់ពី ១ ទៅ ១៩.៥០០ នាក់ ហើយស្ថិតក្នុងវិស័យសេដ្ឋកិច្ចចម្បងចំនួន ៧ រួមមាន៖ i/-កម្មន្តសាល ii/-អចលនទ្រព្យ iii/-សំណង់ iv/-ការដឹកជញ្ជូននិងការស្តុកទុក v/-អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ vi/-សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ និង vii/-ផ្សេងៗ។ ចំណែកឯការអង្កេតវិស័យក្រៅប្រព័ន្ធធ្វើឡើងដោយការចុះសម្ភាសន៍ដោយផ្ទាល់ជាមួយអាជីវករចំនួន ៦០៨ នាក់ នៅរាជធានីភ្នំពេញ និង ១.១៦០ នៅតាមបណ្តាខេត្ត។ បច្ចុប្បន្នធនាគារជាតិនៃកម្ពុជាកំពុងធ្វើបច្ចុប្បន្នកម្មវិធីសាស្ត្រអង្កេតទំនុកចិត្តធុរកិច្ច និងគ្រោងផ្សព្វផ្សាយលទ្ធផលនាពេលខាងមុខ។

## ៣- ស្ថានភាពអតិផរណា

បន្ទាប់ពីបានថយចុះដល់កម្រិតដ៏ទាបនាឆ្នាំ២០២៤ (ជាមធ្យម ០,៨%) អត្រាអតិផរណារួមបានហក់ឡើងនាដើមឆ្នាំ២០២៥ ដោយសារមូលដ្ឋានគណនាទាប និងកំណើនថ្លៃម្ហូបអាហារ។ នាខែមករា ឆ្នាំ២០២៥ អត្រាអតិផរណាបានកើនឡើងដល់ ៦% ប៉ុន្តែបានថយចុះជាបន្តបន្ទាប់មកវិញដល់ ១,៦% នាខែមិថុនា ដែលបណ្តាលមកពីការថយកំណើនថ្លៃម្ហូបអាហារ និងការធ្លាក់ថ្លៃប្រេងឥន្ធនៈ។ អត្រាអតិផរណារួមមានកម្រិតជាមធ្យម ៣,៥% នាឆមាសទី១នេះ។

**ក្រាហ្វ ១៨៖ ការរួមចំណែកក្នុងអតិផរណារួម**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៩៖ អតិផរណារួម និងអតិផរណាក្រុមទាំងបី**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

- កំណើនថ្លៃក្រុមម្ហូបអាហារមានកម្រិតខ្ពស់នាខែមករា ៧,៨% ដោយសារមូលដ្ឋានគណនាទាប និងការកើនឡើងតម្រូវការខ្ពស់ក្នុងអំឡុងពេលចូលឆ្នាំប្រពៃណីចិន។ ទោះយ៉ាងណាការកើនឡើងសន្សឹមៗនៃកម្រិតថ្លៃនាគ្រាដូចគ្នាឆ្នាំមុន បានធ្វើឱ្យកំណើនថ្លៃក្រុមម្ហូបអាហារថយចុះជាបន្តបន្ទាប់មក ២,៥% នាខែមិថុនាឆ្នាំ២០២៥។ អត្រាអតិផរណាមានកម្រិតជាមធ្យម ៤,៨% នាឆមាសទី១នេះ (ធៀបនឹង ០,៤% នាឆមាសទី១ ឆ្នាំ២០២៤) ដែលក្នុងនោះ ថ្លៃបន្លែកើន ៨,២% (ធៀបនឹង ២,៦%) ផ្លែឈើ ៧% (ធៀបនឹង ១,១%) ត្រីស្រស់ ៤,៧% (ធៀបនឹង -០,៣%) សាច់ជ្រូក ៣,៦% (ធៀបនឹង -០,២%) និងសាច់គោស្រស់ ៣,៩% (ធៀបនឹង -០,៤%)។

- ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបន្តថយចុះ -២,២% (ធៀបនឹង -១,១% នាឆមាសទី១ ឆ្នាំ២០២៤) ដែលជាចម្បងបណ្តាលមកពីការធ្លាក់ថ្លៃសាំង។ ថ្លៃសាំងនៅកម្ពុជាមានកម្រិតជាមធ្យម ៣.៩០៨ រៀលក្នុងមួយលីត្រ ដែលបានថយចុះ -៩,៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤ (៤.៣២៥ រៀលក្នុងមួយលីត្រ) ស្របតាមនិន្នាការថ្លៃប្រេងនៅពិភពលោក។

- អតិផរណាស្នូលបានកើនឡើងដល់ ២,៩% (ធៀបនឹង ០,៤% នាឆមាសទី១ ឆ្នាំ២០២៤) ដោយសារការកើនឡើងថ្លៃការថែរក្សានិងការជួសជុលជម្រកស្នាក់នៅ ៧,៥% (ធៀបនឹង ០,៧%) ភោជនីយដ្ឋាន ២,៣% (ធៀបនឹង -០,៣%) និងសម្លៀកបំពាក់ ៧,១% (ធៀបនឹង ១,៣%)។ ការកើនឡើងនេះបណ្តាលមកពីកម្រិតថ្លៃទាបនាគ្រាដូចគ្នាឆ្នាំមុន និងឥទ្ធិពលពីការឡើងថ្លៃក្រុមម្ហូបអាហារមកលើកន្ត្រកមុខទំនិញរបស់អតិផរណាស្នូល ជាពិសេសក្រុមភោជនីយដ្ឋាន បើទោះជាកំណើនឥណទាននៅមានភាពទន់ខ្សោយនៅឡើយ។

**ក្រាហ្វ ២០៖ អតិផរណាក្រុមម្ហូបអាហារ**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២១៖ អតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២២៖ អតិផរណាស្នូល**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ដើម្បីពង្រឹងការតាមដាន វិភាគ និងព្យាករអតិផរណា និងក្នុងនាមជាស្ថាប័នដឹកនាំការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះស្តីពីអតិផរណា ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំអន្តរក្រសួង[៥]និងបានបង្កើតក្រុមការងារបច្ចេកទេសតាមដាននិងវាយតម្លៃសូចនាករសមិទ្ធកម្មគន្លឹះស្តីពីអតិផរណា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងសហការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការធ្វើបច្ចុប្បន្នកម្មកន្ត្រកទំនិញប្រើប្រាស់ ដោយផ្អែកលើគ្រាគោលថ្មីឆ្នាំ២០១៩ (គ្រាគោលចាស់គឺ ខែតុលា-ធ្នូ ឆ្នាំ២០០៦)។

## ៤- ស្ថានភាពអត្រាប្តូរប្រាក់

ប្រាក់រៀលបន្តមានស្ថិរភាពល្អប្រសើរ ព្រមទាំងមាននិន្នាការឡើងថ្លៃទៀតផង ដោយសារកំណើនតម្រូវការប្រាក់រៀល សម្រាប់ប្រើប្រាស់នៅក្នុងវិស័យកសិកម្ម ការទូទាត់អេឡិចត្រូនិក និងការបង់ពន្ធ។ លើសពីនេះ ការប្រែប្រួលរបស់អត្រាប្តូរប្រាក់ទៅតាមកត្តារដូវកាលក៏មានកម្រិតផងដែរ ដែលកត្តានេះបានរួមចំណែកថែមទៀតលើការបង្កើនទំនុកចិត្តលើប្រាក់រៀល។ ជាក់ស្តែង អត្រាប្តូរប្រាក់នាត្រីមាសទី២ បានប្រែប្រួលត្រឹមតែ -0,៣% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២៥ ដែលជាកម្រិតទាបជាងការប្រែប្រួលមុនវិបត្តិកូវីដ-១៩ (0,៩%)។ ជាមធ្យម អត្រាប្តូរប្រាក់នៅក្នុងឆមាសទី១ នេះមានកម្រិត ៤.០១១ រៀលក្នុងមួយដុល្លារអាមេរិក ដែលប្រាក់រៀលបានឡើងថ្លៃ ១,៦% ធៀបនឹងគ្រាដូចគ្នាឆ្នាំ២០២៤ (៤.០៧៥ រៀល) និងឡើងថ្លៃ 0,៧% ធៀបនឹងគ្រាដូចគ្នាឆ្នាំ២០១៦-២០១៩ (៤.០៣៩ រៀល)។

**ក្រាហ្វ ២៣៖ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**
(គិតជារៀលក្នុងមួយដុល្លារអាមេរិក, ឆ្នាំ២០១៦- ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

[៥] រួមមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានគណនាចេញពីអត្រាប្តូរប្រាក់មធ្យមថ្លឹងរបស់ទីផ្សារប្តូរប្រាក់អន្តរធនាគារនៅលើថ្នាលធនាគារជាតិនៃកម្ពុជា (NBCP)។ ប្រតិបត្តិការប្តូរប្រាក់លើ NBCP មាន ១,៨ ប៊ីលានដុល្លារអាមេរិក (៨៦៧ ប្រតិបត្តិការ) ដែលបានកើន ៤៣,៤% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (១,២ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៩៤៨ ប្រតិបត្តិការ)។ កំណើននេះបង្ហាញថា៖ i/-អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាកាន់តែឆ្លុះបញ្ចាំងពីអត្រាប្តូរប្រាក់នៅលើទីផ្សារ ii/-ថ្នាលធនាគារជាតិនៃកម្ពុជាបាននិងកំពុងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍទីផ្សារប្តូរប្រាក់ និង iii/-គ្រឹះស្ថានធនាគារកាន់តែមានឥទ្ធិពលនៅក្នុងការកំណត់ថ្លៃនៅលើទីផ្សារប្តូរប្រាក់ធៀបនឹងអាជីវករប្តូរប្រាក់។

**ក្រាហ្វ ២៤៖ ការទិញ-លក់ប្រាក់ដុល្លារអាមេរិកតាមរយៈ NBCP**
(ឆមាសទី១ ឆ្នាំ២០២១ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥- ស្ថានភាពជញ្ជីងទូទាត់

សមតុល្យជញ្ជីងទូទាត់កម្ពុជា មានអតិរេក ២៧៥,៥ លានដុល្លារអាមេរិក ធៀបនឹងឱនភាព ១៩៩,៤ លានដុល្លារអាមេរិក គ្រាដូចគ្នាឆ្នាំមុន។ អតិរេកនេះត្រូវបានគាំទ្រដោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ បើទោះបីជាគណនីចរន្តនិងដើមទុន បានប្តូរពីអតិរេកមកឱនភាព។

**ក្រាហ្វ ២៥៖ ជញ្ជីងទូទាត់កម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា,សម្គាល់៖ ប=ប៉ាន់ស្មាន

## - គណនីចរន្តនិងដើមទុន

សមតុល្យគណនីចរន្តនិងដើមទុនមានឱនភាព ១៥៥,៦ លានដុល្លារអាមេរិក (០,៦% នៃផ.ស.ស.) ធៀបនឹងអតិរេក ៧៥ លានដុល្លារអាមេរិក (០,៣% នៃផ.ស.ស.) គ្រាដូចគ្នាឆ្នាំមុន ដែលជាចម្បងបណ្តាលមកពីការកើនឡើងនៃឱនភាពពាណិជ្ជកម្មទំនិញ និងចំណូលបឋម ខណៈដែលអតិរេកគណនីសេវា និងចំណូលបន្ទាប់បន្សំកើនឡើង។

**ក្រាហ្វ ២៦៖ គណនីចរន្ត និងគណនីដើមទុន**

(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

សមតុល្យពាណិជ្ជកម្មទំនិញមានឱនភាព ២,៥ ប៊ីលានដុល្លារអាមេរិក ដែលបានកើនឡើង ៧,៨% ដោយសារការនាំចូលកើនលឿនជាងការនាំចេញ។ ការនាំចេញមាន ១៤,៨ ប៊ីលានដុល្លារអាមេរិក (កើន ១៨,២%) ដែលក្នុងនោះការនាំចេញផលិតផលកាត់ដេរ[10] កើន ២២% ផលិតផលកសិកម្ម ៥,៥%[11] និងផលិតផលផ្សេងៗ ២០,៨% (សំបកកង់រថយន្ត កើន ៨០,៤% ទោចក្រយាន ៥១,៥% និងគ្រឿងអេឡិចត្រូនិកមិនរាប់បញ្ចូលផ្ទាំងសូឡា ១៥,៤%)។ សហរដ្ឋអាមេរិកនៅតែជាទីផ្សារនាំចេញលំដាប់ទី១របស់កម្ពុជា ដែលមានសមាមាត្រ ៣៨% នៃការនាំចេញសរុប បន្ទាប់មកសហភាពអឺរ៉ុប ១៦% វៀតណាម ១៥% ចិន ៥% ជប៉ុន ៥% និងប្រទេសផ្សេងទៀត ២១%។

**ក្រាហ្វ ២៧៖ ពាណិជ្ជកម្មទំនិញរបស់ប្រទេសកម្ពុជា**

(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

ការនាំចូលមាន ១៧,២ ប៊ីលានដុល្លារអាមេរិក (កើន ១៦,៦%) ដែលក្នុងនោះ ការនាំចូលយានយន្តកើន ៤៥,១% សម្ភារនិងបរិក្ខារសំណង់ ៤៤,១% ម្ហូបអាហារនិងភេសជ្ជៈ ១១,១% និងវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ ៩,៩%។ កម្ពុជានាំចូលទំនិញច្រើនជាងគេពីប្រទេសចិន[12] ដែលមាន សមាមាត្រ ៥២% នៃការនាំចូលសរុប បន្ទាប់មកវៀតណាម ១៣% ថៃ ១១% ឥណ្ឌូណេស៊ី ៣% និងប្រទេសផ្សេងទៀត ២១%។

[10] ក្នុងនោះ ការនាំចេញសម្លៀកបំពាក់កើន ២២% ស្បែកជើង ៣៣,១% និងសម្ភារសម្រាប់ធ្វើដំណើរនិងផលិតផលវាយនភ័ណ្ឌផ្សេងទៀត ១៤,៧%។

[11] ក្នុងនោះ អង្ករកើន ១២,៧% និងផលិតផលកសិកម្មផ្សេងៗ ៦,២% ខណៈដែលកៅស៊ូថយចុះ -៨,៨%។

[12] រាប់បញ្ចូលទាំង ហុងកុង តៃវ៉ាន់ និងម៉ាកាវ

**ក្រាហ្វ ២៨៖ ការនាំចូលទំនិញ**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ២៩៖ ការនាំចេញទំនិញ**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣០៖ សមាមាត្រការនាំចូលទំនិញបែងចែកតាមប្រទេស**
(ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

**ក្រាហ្វ ៣១៖ សមាមាត្រការនាំចេញទំនិញបែងចែកតាមប្រទេស**
(ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការប៉ាន់ស្មានរបស់មន្ត្រីធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

គណនីសេវាមានអតិរេក ៩៩៤,៣ លានដុល្លារអាមេរិក ដោយបានកើនឡើង ២០,៣% ដែលជាចម្បងគាំទ្រដោយការកើនឡើងនៃចំណូលពីសេវាធ្វើដំណើរ ៩,១%។ ទន្ទឹមនេះ គណនីចំណូលបន្ទាប់បន្សំមានអតិរេក ១,៦ ប៊ីលានដុល្លារអាមេរិក ដោយបានកើនឡើង ១,៧% ដែលក្នុងនោះ ប្រាក់បង្វែរឯកជនពីក្រៅប្រទេស[១៣]កើន ៤,៩% ខណៈជំនួយរបស់រាជរដ្ឋាភិបាលថយចុះ -១៦,៩%។ ចំណែក គណនីចំណូលបឋមមានឱនភាព ២៨៩,៣ លានដុល្លារអាមេរិក ដែលបានកើនឡើង ២,២ ដង ដោយសារការទូទាត់ផ្នែកឥណពន្ធ[១៤]កើន ៥៣,៥% ខណៈដែលការទូទាត់ផ្នែកឥណទានកើន ៧,២%។

[១៣] ក្នុងនោះ ប្រាក់បង្វែរពលករទេសន្តរប្រវេសន៍ពីក្រៅប្រទេសកើន ៩,១% (ពីប្រទេសថៃកើន ១២% ជប៉ុន ៦,៧% និងម៉ាឡេស៊ី ៣,៥% ខណៈដែលប្រទេសកូរ៉េថយ -៦,៧%) និងប្រាក់បង្វែរចូលពីក្រៅប្រទេសផ្សេងទៀតកើន ១,១%។

[១៤] ក្នុងនោះ ការបែងចែកភាគលាភនិងប្រាក់ចំណេញពីការវិនិយោគផ្ទាល់កើន ៩២,៧% និងចំណាយការប្រាក់របស់រាជរដ្ឋាភិបាលកើន ៨,១%។

- **គណនីហិរញ្ញវត្ថុ**

សមតុល្យគណនីហិរញ្ញវត្ថុបង្ហាញលំហូរចូលសុទ្ធ ៤៣១,១ លានដុល្លារអាមេរិក ធៀបនឹង លំហូរចេញសុទ្ធ ២៧៤,៤ លានដុល្លារអាមេរិក នាឆមាសទី១ ឆ្នាំមុន។ ការកើនឡើងលំហូរសុទ្ធនេះជាចម្បងបណ្តាលមកពីការកើនឡើងនៃលំហូរចូលវិនិយោគផ្ទាល់បរទេស និងការថយចុះទ្រព្យសកម្មបរទេសផ្នែកវិនិយោគលើផលបត្រ ខណៈលំហូរចេញសុទ្ធផ្នែកវិនិយោគផ្សេងទៀតបានកើនឡើង។

**ក្រាហ្វ ៣២៖ គណនីហិរញ្ញវត្ថុ**

(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

លំហូរចូលវិនិយោគផ្ទាល់បរទេសមាន ២ ប៊ីលានដុល្លារអាមេរិក ដោយបានកើន ១៣,១% ដែលគាំទ្រដោយកំណើនការវិនិយោគក្នុងវិស័យហិរញ្ញវត្ថុ ៣,៧ដង និងវិស័យមិនមែនហិរញ្ញវត្ថុ ៤,៣% ដោយក្នុងនោះ វិស័យកម្មន្តសាល[១៥]កើន ២០,៩% និងកសិកម្ម ៥,៥% ខណៈដែលវិស័យសណ្ឋាគារនិងការកម្សាន្តថយ -៤៧,៦% អចលនទ្រព្យ -២៦,២% សំណង់ -១៤,៤% ថាមពល -១៣,១% ទូរគមនាគមន៍ -៣២,៣% អាជីវកម្មធនធានរ៉ែ -៤៨% និងផ្សេងទៀត -២៤,៧%។ ប្រទេសចិន[១៦]នៅតែបន្តនាំមុខក្នុងការវិនិយោគនៅកម្ពុជា (៧៧% នៃលំហូរវិនិយោគសរុប) បន្ទាប់មកកូរ៉េ (៥,៩%) សិង្ហបុរី (៣,៩%) កាណាដា (៣,២%) ម៉ាឡេស៊ី (២,៨%) និងផ្សេងៗ (៧,២%)។

វិនិយោគផ្សេងទៀតបង្ហាញពីការកើនឡើងលំហូរចេញសុទ្ធ ១,៩ ប៊ីលានដុល្លារអាមេរិក (កើនឡើង ៦,៨%) ដែលបណ្តាលមកពីការកើនឡើងប្រាក់បញ្ញើនិងការទូទាត់បំណុលនៅក្រៅប្រទេសនៃវិស័យហិរញ្ញវត្ថុ ខណៈដែលការខ្ចីសុទ្ធរបស់រាជរដ្ឋាភិបាលកើនឡើង ៨,៣%។

**ក្រាហ្វ ៣៣៖ ការចូលរួមក្នុងកំណើនវិនិយោគផ្ទាល់បរទេស**

(គិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

**ក្រាហ្វ ៣៤៖ សមាមាត្រលំហូរចូលវិនិយោគផ្ទាល់បរទេសបែងចែកតាមប្រទេស**

(ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

---

[១៥] ក្នុងនោះ៖ ការវិនិយោគលើការផលិតឱសថៈកើន ១,៣ដង កែច្នៃផលិតផលឈើ ២៨,៤% វេចខ្ចប់ ១,១% និងផ្សេងទៀត ៧១,៦% ខណៈដែលកាត់ដេរសម្លៀកបំពាក់ថយ -១១,២% ផលិតផលធ្វើដំណើរ -៣៩,៩% ស្បែកជើង -៨,៣% និងផលិតផលចំណីអាហារ -១៦,៧%។

[១៦] រាប់បញ្ចូលទាំង ហុងកុង តៃវ៉ាន់ និងម៉ាកាវ។

## ៦- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

**ក្រាហ្វ ៣៥៖ ទុនបម្រុងអន្តរជាតិ**
(ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ ទុនបម្រុងអន្តរជាតិមាន ២៤,៨ ប៊ីលានដុល្លារអាមេរិក ដោយបានកើន ១០,៤% ធៀបនឹងចុងខែធ្នូ ឆ្នាំ២០២៤ (២២,៥ ប៊ីលានដុល្លារអាមេរិក) ដែលស្មើនឹង ៧,៥ ខែនៃការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់ ដែលជាកម្រិតខ្ពស់សម្រាប់ប្រទេសកំពុងអភិវឌ្ឍ។ ការកើនឡើងនេះជាចម្បងបណ្តាលមកពីការកើនឡើង៖ i/-តម្លៃមាស ii/-ចំណូលពីការវិនិយោគក្រៅប្រទេស iii/-ការប្រែប្រួលអត្រាប្តូរប្រាក់ និង iv/-ប្រាក់បញ្ញើពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រាក់បម្រុងកាតព្វកិច្ច។

ការវិនិយោគទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជាត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន និងមានភាពបត់បែនខ្ពស់ ហើយហានិភ័យនៃការវិនិយោគត្រូវបានគ្រប់គ្រងនិងតាមដានយ៉ាងហ្មត់ចត់ ដោយអនុលោមតាមគោលនយោបាយវិនិយោគនិងសេចក្តីណែនាំការវិនិយោគរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាបាននូវការគ្រប់គ្រងទុនបម្រុងអន្តរជាតិប្រកបដោយសុវត្ថិភាព សន្ទនីយភាព និងទទួលបានចំណូលសមស្រប។ នាដើមឆ្នាំ២០២៥នេះ ធនាគារជាតិនៃកម្ពុជាបានធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំការវិនិយោគ ដោយបានកែសម្រួលសមាសភាពរូបិយប័ណ្ណប្រភេទទ្រព្យសកម្ម និងទំហំចរិកាហានិភ័យ ដើម្បីឆ្លើយតបនឹងការប្រែប្រួលស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។ ទន្ទឹមនេះ សេចក្តីណែនាំលើការងារជ្រើសរើសនិងគ្រប់គ្រងអ្នកចាត់ការខាងក្រៅនិងភ្នាក់ងាររក្សាមូលបត្រត្រូវបានធ្វើបច្ចុប្បន្នកម្មរួចរាល់ជាស្ថាពរ ដោយបានបង្កើនតម្លាភាពនៃនីតិវិធីជ្រើសរើស និងពង្រឹងការត្រួតពិនិត្យការអនុវត្តនិងសមិទ្ធផលអ្នកចាត់ការខាងក្រៅ ព្រមទាំងបានបញ្ចូលនីតិវិធីក្នុងការជ្រើសរើស និងគ្រប់គ្រងភ្នាក់ងាររក្សាមូលបត្រ ដែលជាភាគីផ្តល់សេវាសំខាន់ក្នុងការធានាសុវត្ថិភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងទុនបម្រុងអន្តរជាតិ។

ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាបានបន្តយកចិត្តទុកដាក់លើការបង្កើនការវិនិយោគលើសញ្ញាបណ្ណបៃតង (Green bonds) និងសញ្ញាបណ្ណដែលពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលបោះផ្សាយដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ នៅប្រទេសចិន កូរ៉េខាងត្បូង ជប៉ុន និងតំបន់អឺរ៉ុប។ ជាក់ស្តែង នាពេលបច្ចុប្បន្ន ការវិនិយោគលើសញ្ញាប័ណ្ណបៃតង និង ESG មានសមាមាត្រ ៦% នៃទុនបម្រុងអន្តរជាតិសរុប ដែលសបញ្ជាក់ពីការរួមចំណែករបស់ ធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ការអនុវត្តតាមគោលនយោបាយវិនិយោគប្រកបដោយចីរភាព និងស្របតាមនិន្នាការនៃការវិនិយោគសកល ដែលកំពុងផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចបៃតង និងការអភិវឌ្ឍប្រកបដោយចីរភាព។

**ជារួម ទោះបីជាស្ថានភាពសេដ្ឋកិច្ចពិភពលោកបន្តប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ ដោយសារសង្គ្រាមនិងភាពតានតឹងភូមិសាស្ត្រនយោបាយ និងនិន្នាការគាំពារនិយមក៏ដោយ សេដ្ឋកិច្ចកម្ពុជានៅរក្សាបានភាពធន់និងបន្តសម្រេចបានកំណើនល្អ ក្នុងឆមាសទី១ ឆ្នាំ២០២៥ នេះ។ អតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបាន ជាមួយនឹងការរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបានល្អប្រសើរ។ ជញ្ជីងទូទាត់បានត្រលប់មកមានអតិរេកវិញ ដែលគាំទ្រដោយកំណើនលំហូរការវិនិយោគផ្ទាល់បរទេស។ អតិរេកជញ្ជីងទូទាត់គួបផ្សំនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបានរួមចំណែកធ្វើឱ្យទុនបម្រុងអន្តរជាតិកើនឡើងគួរឱ្យកត់សម្គាល់។**

## II- ការគ្រប់គ្រងរូបិយវត្ថុ

### ១- ការផ្គត់ផ្គង់រូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2) បន្តមានកំណើនរឹងមាំ ក្នុងកម្រិត ១៦,៨% ទោះបីជាបានថមថយល្បឿនបន្តិចធៀបនឹងឆមាសទី២ ឆ្នាំ២០២៤ (១៧,៥%) ដែលនៅតែបង្ហាញពីជំនឿទុកចិត្តមកលើប្រព័ន្ធធនាគារ គួបផ្សំនឹងភាពរីកចម្រើននៃការទូទាត់អេឡិចត្រូនិក។ ការថយល្បឿននេះបណ្តាលមកពីប្រាក់បញ្ញើជារូបិយប័ណ្ណនិងជារៀលបានថមថយកំណើនមកត្រឹម ១៧,៧% និង ៩% រៀងគ្នា ខណៈរូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើបានងើបឡើងវិញ ១៤,៧% (រូបិយវត្ថុក្នុងចរាចរណ៍មាន ១៨,១ ទ្រីលានរៀល ដែលបានកើនឡើង ៥,៣%) ដោយសារកំណើនតម្រូវការប្រាក់រៀល គួបផ្សំនឹងកម្រិតទាបស្រាប់កាលពីគ្រាដូចគ្នាឆ្នាំមុន។ ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជាបន្តមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅស្មើនឹង ៨៤,៩% ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុប ៩១,២% និងឥណទានជារូបិយប័ណ្ណធៀបនឹងឥណទានសរុប ៨៦,៦%។

**ក្រាហ្វ ៣៦៖ ការរួមចំណែកក្នុងកំណើនរូបិយវត្ថុទូទៅ**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

**ក្រាហ្វ ៣៧៖ កំណើនសមាសធាតុរូបិយវត្ថុទូទៅ**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន

### ២- អត្រាប្រាក់បម្រុងកាតព្វកិច្ច

អត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលនិងដុល្លារអាមេរិកត្រូវបានបន្តរក្សាក្នុងកម្រិត ៧%។ ជាមួយនឹងកំណើនប្រាក់បញ្ញើ ប្រាក់បម្រុងកាតព្វកិច្ចជារៀលមាន ១,៧ ទ្រីលានរៀល (៤៣៦ លានដុល្លារអាមេរិក) ដែលបានកើនឡើង ១០,៤% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន និងជាដុល្លារអាមេរិកមាន ៤,២ ប៊ីលានដុល្លារអាមេរិក (១៦,៨ ទ្រីលានរៀល) ដែលបានកើនឡើង ១០,៤%។

**ក្រាហ្វ ៣៨៖ ទំហំនិងអត្រាប្រាក់បម្រុងកាតព្វកិច្ច**
(ទិន្នន័យចុងគ្រា, ឆ្នាំ១៩៩៣ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រាក់បម្រុងលើស[17]ជារៀលមាន ៥,៧ ទ្រីលានរៀល (១,៤ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៣,៣ដង នៃប្រាក់បម្រុងកាតព្វកិច្ចជារៀល។ ប្រាក់បម្រុងលើសជាដុល្លារអាមេរិកមាន ៥,៧ ប៊ីលានដុល្លារអាមេរិក (២២,៩ ទ្រីលានរៀល) ស្មើនឹង ១,៩ដង នៃប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក។ ប្រាក់បម្រុងលើសត្រូវបានរក្សាក្នុងកម្រិតខ្ពស់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីបង្ការហានិភ័យសន្ទនីយភាព។

**ក្រាហ្វ ៣៩៖ អនុបាតប្រាក់បម្រុងលើសធៀបនឹងប្រាក់បម្រុងកាតព្វកិច្ចជារៀល និងដុល្លារអាមេរិក**
(គិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤០៖ ប្រាក់បម្រុងលើសជារៀល និងដុល្លារអាមេរិក**
(គិតជាទ្រីលានរៀល, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣- មូលបត្រអាចជួញដូរបាន

ធនាគារជាតិនៃកម្ពុជាស្រូបប្រាក់បម្រុងលើសជារៀលនិងជាដុល្លារអាមេរិកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD)។ NCD មិនទាន់ដល់ឥណប្រតិទានជារៀលបានកើនឡើង ១៥% ដល់ ១,២ ទ្រីលានរៀល បើទោះជាការបោះផ្សាយ NCD[18] ជារៀលមានចំនួន ១៦,៣ ទ្រីលានរៀល ដែលបានកើនឡើង ១,៨ ទ្រីលានរៀល (១២,៨%) ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។ តម្រូវការ NCD របស់គ្រឹះស្ថានធនាគារសម្រាប់ឥណប្រតិទាន ៧ថ្ងៃ និង ១៨២ថ្ងៃ បានកើនឡើង ខណៈឥណប្រតិទាន ៩១ថ្ងៃ បានថយចុះ។ ចំណែកឯអត្រាការប្រាក់ជារៀលជាមធ្យមបានកើនពី ០,៩១% ដល់ ១,១៥% ដែលក្នុងនោះ ឥណប្រតិទាន ៧ថ្ងៃ មានកម្រិត ១% (កើនពី ០,៥០%) ៩១ថ្ងៃ មានកម្រិត ១,១៣% (ថយពី ១,៣១%) និង ១៨២ថ្ងៃ មានកម្រិត ១,៣០% (កើនពី ០,៩៩%)។

**ក្រាហ្វ ៤១៖ NCD ជារៀល**
(គិតជាទ្រីលានរៀល, ឆមាសទី១ ឆ្នាំ២០១៣ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤២៖ អត្រាការប្រាក់ NCD ជារៀល**
(គិតជាភាគរយ, អត្រាមធ្យម, ឆមាសទី១ ឆ្នាំ២០២៤ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[17] ប្រាក់បម្រុងលើស = ប្រាក់បម្រុងសរុប - ប្រាក់បម្រុងកាតព្វកិច្ច = គណនីចរន្ត + គណនីផាត់ទាត់ + គណនីបាគង

[18] ធនាគារជាតិនៃកម្ពុជាបានផ្លាស់ប្តូរថ្ងៃដេញថ្លៃ និងទូទាត់ NCD មកក្នុងថ្ងៃតែមួយ (T+0) ចាប់ពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៥។

NCD ជាដុល្លារអាមេរិកដែលមិនទាន់ដល់ឥណប្រតិទានបានកើនឡើង ២៨% ដល់ ១,៦ ប៊ីលានដុល្លារអាមេរិក។ ការបោះផ្សាយ NCD ជាដុល្លារអាមេរិក មានចំនួន ២,៤ ប៊ីលានដុល្លារអាមេរិក ដោយបានកើន ៣០៣ លានដុល្លារអាមេរិក (១៤,៣%) ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។ តម្រូវការ NCD របស់គ្រឹះស្ថានធនាគារសម្រាប់ឥណប្រតិទាន ១៨២ថ្ងៃ បានកើនឡើង ខណៈឥណប្រតិទាន ៩១ថ្ងៃ និង ៣៦៤ថ្ងៃ បានថយចុះ។ ចំណែកឯអត្រាការប្រាក់ NCD ជាដុល្លារអាមេរិក ជាមធ្យមបានថយពី ១,១២% មក ០,៩៧% ដែលក្នុងនោះឥណប្រតិទាន ៩១ថ្ងៃ មានកម្រិត ០,៨៣% (ថយពី ១,១២%) ១៨២ថ្ងៃ មានកម្រិត ១% (ថយពី ១,១០%) និង ៣៦៤ថ្ងៃ មានកម្រិត ១,០៧% (ថយពី ១,១៦%)។

**ក្រាហ្វ ៤៣៖ NCD ជាដុល្លារអាមេរិក**
(គិតជាប៊ីលានដុល្លារអាមេរិក,
ឆមាសទី១ ឆ្នាំ២០១៣ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៤៖ អត្រាការប្រាក់ NCD ជាដុល្លារអាមេរិក**
(គិតជាភាគរយ, អត្រាមធ្យម,
ឆមាសទី១ ឆ្នាំ២០២៤ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- ប្រតិបត្តិការផ្តល់សន្ទនីយភាព

សន្ទនីយភាពជារៀលត្រូវបានផ្តល់ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) និងប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF)។ អត្រាការប្រាក់ LPCO ឥណប្រតិទាន ៧ថ្ងៃ ត្រូវបានបន្ថយពី ៣,៥០% មក ៣% ឥណប្រតិទាន ៩១ថ្ងៃ ពី ៣,៧៥% មក ៣,២៥% ឥណប្រតិទាន ១៨២ថ្ងៃ ពី ៤% មក ៣,៥០% និងអត្រាការប្រាក់ MLF ពី ៥,៥% មក ៥%[១៩]។

ការផ្តល់សន្ទនីយភាពជារៀលតាមរយៈ LPCO បានកើនឡើងដល់ ២,៤ ទ្រីលានរៀល (៦១២ លានដុល្លារអាមេរិក) នាឆមាសទី១ ឆ្នាំ២០២៥ (កើន ២៦%) ដែលក្នុងនោះ ឥណប្រតិទាន ៧ថ្ងៃ មាន ៦៨៥ ប៊ីលានរៀល ៩១ថ្ងៃ មាន ១,១ ទ្រីលានរៀល និង ១៨២ថ្ងៃ មាន ៦២០ ប៊ីលានរៀល។

LPCO មិនទាន់ដល់ឥណប្រតិទានមាន ១,១ ទ្រីលានរៀល ដែលបានកើនឡើង ៤១០ ប៊ីលានរៀល (កើន ៥៩%) ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។ អត្រាការប្រាក់ដេញថ្លៃឈ្នះ LPCO មានកម្រិតទាប ជាមធ្យម ៣,២២% (ថយពី ៣,៧២%) សម្រាប់ឥណប្រតិទាន៧ថ្ងៃ ៣,៥២% (ថយពី ៤,០៤%) សម្រាប់៩១ថ្ងៃ និង ៣,៦២% (ថយពី ៤,២៤%) សម្រាប់ ១៨២ថ្ងៃ។

[១៩] កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥។

**ក្រាហ្វ ៤៥៖ ទំហំទឹកប្រាក់ក្នុងប្រតិបត្តិការ LPCO**

(គិតជាប៊ីលានរៀល, ឆមាសទី១ ឆ្នាំ២០១៨ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៦៖ អត្រាការប្រាក់ LPCO**

(គិតជាភាគរយ, ខែកក្កដា ឆ្នាំ២០២៤ - ខែមិថុនា ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទន្ទឹមនេះ ការផ្តល់សន្ទនីយភាពតាមរយៈ MLF[២០] មាន ៥០០ លានរៀល ដែលបានថយចុះ -៩៩៩,៤ ប៊ីលានរៀលធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។

សរុបមក រូបិយវត្ថុទូទៅបានថមថយល្បឿនមកវិញបន្តិច ប៉ុន្តែបន្តមានភាពរឹងមាំ ដែលគាំទ្រជាចម្បងដោយភាពរីកចម្រើននៃការទូទាត់អេឡិចត្រូនិក។ ធនាគារជាតិនៃកម្ពុជាបានបន្តរក្សានយោបាយរូបិយវត្ថុវិត្ថារកម្ម តាមរយៈការរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចឱ្យស្ថិតនៅកម្រិតទាប។ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ធនាគារជាតិនៃកម្ពុជាបានបង្កើនការផ្តល់សន្ទនីយភាពជារៀលតាមរយៈប្រតិបត្តិការ LPCO និងកាត់បន្ថយការស្រូបយកសន្ទនីយភាពជារៀលតាមរយៈ NCD។

[២០] MLF គឺជាឧបករណ៍នយោបាយរូបិយវត្ថុសម្រាប់ផ្តល់សន្ទនីយភាពជាប្រាក់រៀលមានឥណប្រតិទានមួយថ្ងៃ (Overnight) ដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានតម្រូវការចាំបាច់រយៈពេលខ្លីដោយមានវត្ថុធានា។ យ៉ាងណាមិញឧបករណ៍នេះត្រូវបានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទទួលបានសន្ទនីយភាពនៅក្នុងថ្ងៃតែម្តង និងអាចបន្តឥណប្រតិទានដោយមិនកំណត់។

## III- ប្រព័ន្ធធនាគារនៅកម្ពុជា

### ១- ស្ថានភាពទូទៅ

ប្រព័ន្ធធនាគារកម្ពុជាមាន ធនាគារពាណិជ្ជ ៥៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) ៤ ធនាគារឯកទេស ៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFI) ៨៥ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១៣ គ្រឹះស្ថានឥណទានជនបទ ១១២ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ២៩ ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងបរទេស ៥ និងអាជីវកម្មប្តូរប្រាក់ ៣.៤០៧[២១]។

**ក្រាហ្វ ៤៧៖ ចំនួនប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**

(គិតជាទ្រីលានរៀល, ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

**ក្រាហ្វ ៤៨៖ ចំនួនគណនីប្រាក់បញ្ញើ និងគណនីឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**

(គិតជាលានគណនី, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ[២២]មានកំណើន ៧,៣% ដល់ ៣៨៨,៥ ទ្រីលានរៀល (៩៧,១ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទានអតិថិជនកើនឡើង ២,៩% ដល់ ២៤៧,៣ ទ្រីលានរៀល (៦១,៨ ប៊ីលានដុល្លារអាមេរិក)។ ប្រាក់បញ្ញើអតិថិជនមានកំណើន ១៤,៥% ដល់ ២៤៥,៩ ទ្រីលានរៀល (៦១,៥ ប៊ីលានដុល្លារអាមេរិក) និងដើមទុនមានកំណើន ៥,៣% ដល់ ៤១,២ ទ្រីលានរៀល (១០,៣ ប៊ីលានដុល្លារអាមេរិក)។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តចូលរួមលើកកម្ពស់

**ក្រាហ្វ ៤៩៖ កំណើនទ្រព្យសកម្ម ឥណទាន និងប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ**

(គិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

[២១] អាជីវកម្មប្តូរប្រាក់ដែលមានអាជ្ញាបណ្ណមាន ៤០ (រាជធានីភ្នំពេញចំនួន ៣៦ និងខេត្តចំនួន ៤) និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់មាន ៣.៣៦៧ (រាជធានីភ្នំពេញចំនួន ៥៦ និងខេត្តចំនួន ៣.៣១១)។

[២២] រួមបញ្ចូលធនាគារពាណិជ្ជ ធនាគារឯកទេស MDIs MFIs និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។

បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព រហ័ស និងទូលំទូលាយជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃចំនួនគណនីប្រាក់បញ្ញើអតិថិជនដល់ ២៨,២ លានគណនី និងគណនីឥណទានអតិថិជនដល់ ៤,៣ លានគណនី។ ទីស្នាក់ការកណ្តាល និងសាខារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានចំនួន ២.៧៥៦ ទីតាំង (និងមានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ចំនួន ៥.៩៦៦ ម៉ាស៊ីន)។ យោងតាមរបាយការណ៍ក្រេឌីតប្យូរ៉ូ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានចូលប្រើប្រាស់របាយការណ៍ឥណទានសរុបប្រមាណ ២,៤ លានប្រតិបត្តិការ ក្នុងនោះ គ្រឹះស្ថានធនាគារ ១,៥ លានប្រតិបត្តិការ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៨៥២,១ ពាន់ប្រតិបត្តិការ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ២៥,៦ ពាន់ប្រតិបត្តិការ និងគ្រឹះស្ថានឥណទានជនបទ ២៤ ពាន់ប្រតិបត្តិការ។

**ក្រាហ្វ ៥០៖ ការពិនិត្យរបាយការណ៍ឥណទានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន**

(ចំនួនរបាយការណ៍, ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ[២៣] កើនឡើង ២,៩% ដល់ ២៣៦,៤ ទ្រីលានរៀល (៥៩,១ ប៊ីលានដុល្លារអាមេរិក) និងបានផ្តល់ទៅកាន់វិស័យសំខាន់ៗដូចជា សកម្មភាពផ្នែកអចលនទ្រព្យ ២២,៨% អាជីវកម្មលក់រាយ ១៧,១% សកម្មភាពគ្រួសារ ១០,៥% កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៩,៨% សំណង់ ៩,៦% អាជីវកម្មលក់ដុំ ៨,៧% និងផ្សេងៗ ២១,៥%។

**ក្រាហ្វ ៥១៖ ឥណទានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច**

(ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

[២៣] រួមមានធនាគារពាណិជ្ជ និង MDIs។

សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ[២៤] ឥណទានកើនឡើង ២,៥% ដល់ ១១,១ ទ្រីលានរៀល (២,៧ ប៊ីលានដុល្លារអាមេរិក) និងបានផ្ដល់ទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច រួមមាន៖ អង្គភាពគ្រួសារ ៥៨% សេវាកម្ម ១៣,៩% ពាណិជ្ជកម្មនិងជំនួញ ៨,៥% សំណង់ ៨,៣% កសិកម្ម ៦,៩% កម្មន្តសាលកម្ម ៤,១% ដឹកជញ្ជូន ៣,១% និងផ្សេងៗ ៦%។

**ក្រាហ្វ ៥២៖ ឥណទានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើតាមវិស័យសំខាន់ៗក្នុងសេដ្ឋកិច្ច**

(ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

អត្រាការប្រាក់បញ្ញើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើជារៀល និងជាដុល្លារអាមេរិកបានថមថយពី ៦,១០% និង ៥,៦៦% មកត្រឹម ៥,១០% និង ៤,៦៨% រៀងគ្នា ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤។ អត្រាការប្រាក់ឥណទានជារៀលថយពី ១៣,១៦% មកត្រឹម ១២,៣១% ខណៈជាដុល្លារអាមេរិកមានស្ថិរភាពក្នុងរង្វង់ ១០,៤៥% ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤។ ចំពោះគ្រឹះស្ថានធនាគារឯកទេស អត្រាការប្រាក់ឥណទានជារៀល និងដុល្លារអាមេរិកបានថយចុះពី ១៤,៤០% និង ១៣,៤៤% រៀងគ្នានៅចុងឆ្នាំ២០២៤ មកត្រឹម ១០,៤៦% និង ១៣,៣៩% រៀងគ្នា។

**ក្រាហ្វ ៥៣៖ អត្រាការប្រាក់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**

(គិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២២ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖អត្រាការប្រាក់សម្រាប់ឥណទានមានកាលកំណត់ និងប្រាក់បញ្ញើមានកាលកំណត់ថ្មី, ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែមេសា ឆ្នាំ២០២៥)

**ក្រាហ្វ ៥៤៖ អត្រាការប្រាក់គ្រឹះស្ថានធនាគារឯកទេស**

(គិតជាភាគរយ, ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖អត្រាការប្រាក់សម្រាប់ឥណទានមានកាលកំណត់ និងប្រាក់បញ្ញើមានកាលកំណត់ថ្មី, ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែមីនា ឆ្នាំ២០២៥)

[២៤] រួមមានគ្រឹះស្ថានធនាគារឯកទេស MFIs និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។

## ២- ស្ថិរភាពហិរញ្ញវត្ថុ

គិតត្រឹមឆមាសទី១ វិស័យធនាគារនៅតែជាវិស័យសំខាន់គាំទ្រដល់កំណើនសេដ្ឋកិច្ច និងមានភាពធន់ ឆ្លុះបញ្ចាំងតាមរយៈដើមទុនរឹងមាំ និងកម្រិតសន្ទនីយភាពខ្ពស់។ ស្ថានភាពដើមទុនមានភាពរឹងមាំ ដោយអនុបាតភាពគ្រប់គ្រាន់នៃដើមទុន (CAR) របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ[២៥] មានកម្រិតជាមធ្យម ២២,៨% និង ៣១,៦% រៀងគ្នា ខ្ពស់ជាងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១៥%)។ ទន្ទឹមនេះ អនុបាតសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានកម្រិតជាមធ្យម ១៨៥% ខ្ពស់ជាងកម្រិតកំណត់នៃបទប្បញ្ញត្តិ (១០០%) ដែលបង្ហាញពីភាពគ្រប់គ្រាន់សាច់ប្រាក់សម្រាប់តម្រូវការរយៈពេលខ្លី។

ក្រាហ្វ ៥៥៖ អនុបាតភាពគ្រប់គ្រាន់នៃដើមទុន

(គិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

ក្រាហ្វ ៥៦៖ អនុបាតសន្ទនីយភាព

(គិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

ទោះយ៉ាងណា កំណើនឥណទាននៃប្រព័ន្ធធនាគារនៅមានកម្រិតទាប ២,៩% ដែលបណ្តាលមកពីតម្រូវការទាបនៃឥណទានជាពិសេសក្នុងសកម្មភាពអចលនទ្រព្យ និងការផ្តល់ឥណទានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានភាពប្រុងប្រយ័ត្នជាងមុន។ ម្យ៉ាងទៀត អនុបាតឥណទានមិនដំណើរការ[២៦] របស់ប្រព័ន្ធធនាគារមានកម្រិត ៨,៣% ធៀបនឹង ៧,៤% នាដំណាច់ឆ្នាំ២០២៤។ ការកើនឡើងនៃអត្រាអនុបាតឥណទានមិនដំណើរការនេះ ដោយសារ

ក្រាហ្វ ៥៧៖ ឥណទានមិនដំណើរការ

(គិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

[២៥] ក្នុងផ្នែកស្ថិរភាពហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ រួមមានគ្រឹះស្ថានធនាគារឯកទេស និង MFIs។

[២៦] អនុបាតឥណទានមិនដំណើរការត្រូវបានគណនាដោយយកឥណទានមិនដំណើរការដុល (Gross NPL) ដែលមិនទាន់ដកសំវិធានធនធៀបនឹងឥណទានដុល ដែលអនុបាតនេះមានកម្រិតខ្ពស់ជាងការគណនាដោយប្រើប្រាស់ឥណទានមិនដំណើរការសុទ្ធ (Net NPL) ដែលបានដកសំវិធានធនចេញរួច។

ការថយល្បឿននៃកំណើនឥណទានគួបផ្សំនឹងការកើនឡើងឥណទានមិនដំណើរការ។ ក្នុងបរិការណ៍នេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានធ្វើសំវិធានធនសម្រាប់ទប់នឹងការខាតបង់នៃឥណទានទាំងនេះ ដែលធ្វើឱ្យអនុបាតឥណទានមិនដំណើរការសុទ្ធបន្ទាប់ពីបានដកសំវិធានធន មានកម្រិតត្រឹមតែ ២,៧% ដែលបង្ហាញពីការពង្រឹងការការពារហានិភ័យឥណទានប្រកបដោយភាពប្រុងប្រយ័ត្ន។

យ៉ាងណាមិញ លទ្ធភាពស្វែងរកប្រាក់ចំណេញមានភាពប្រសើរជាងគ្រាដូចគ្នាឆ្នាំមុន ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក (ROE) របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានកម្រិត ១,២% និង ៦,៨% រៀងគ្នា ស្របពេលដែល ROA និង ROE របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានកម្រិត ១,៦% និង ៤,៥% រៀងគ្នា។

**ក្រាហ្វ ៥៨៖ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម**

(គិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

**ក្រាហ្វ ៥៩៖ អនុបាតប្រាក់ចំណេញធៀបនឹងមូលនិធិភាគទុនិក**

(គិតជាភាគរយ, ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

កន្លងមក ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នតាមរយៈឧបករណ៍មួយចំនួនដូចជា៖ i/-ប្រាក់បម្រុងកាតព្វកិច្ចដែលជាទ្រនាប់សន្ទនីយភាព ត្រូវបានអនុញ្ញាតឱ្យរក្សានៅអត្រាត្រឹម ៧% ដើម្បីធានានូវកម្រិតការផ្គត់ផ្គង់លំហូរសាច់ប្រាក់ ii/-ទ្រនាប់ដើមទុនខនស៊ើវេសិនដែលជាទ្រនាប់បន្ថែមពីលើអនុបាតភាពគ្រប់គ្រាន់នៃដើមទុន ត្រូវបានបន្តឱ្យរក្សានៅអត្រា ១,២៥% ដើម្បីពង្រឹងលទ្ធភាពក្នុងការទប់ទល់ការខាតបង់ ជាពិសេសពីហានិភ័យឥណទាន និង iii/-អនុបាតក្របខ័ណ្ឌសន្ទនីយភាពត្រូវបានកំណត់ក្នុងកម្រិត ១០០% ដើម្បីធានាបាននូវភាពគ្រប់គ្រាន់នៃសាច់ប្រាក់រយៈពេលខ្លី ចំពោះហានិភ័យសន្ទនីយភាពដែលអាចកើតមាន។ លើសពីនេះ វិធានការអនុគ្រោះបទប្បញ្ញត្តិត្រូវបានដាក់ចេញតាមរយៈការអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញ ដើម្បីសម្រួលបន្ទុកដល់

**ក្រាហ្វ ៦០៖ ឥណទានរៀបចំឡើងវិញ**

(គិតជាភាគរយ, ឆ្នាំ២០២៤ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែឧសភា ឆ្នាំ២០២៥)

អ្នកខ្ចីដែលជួបការលំបាកផ្នែកហិរញ្ញវត្ថុ ដោយឥណទានរៀបចំឡើងវិញរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានកើនដល់ ៥,៦% នៃឥណទានសរុប (២,៩% ចុងឆ្នាំ២០២៤)។

ជារួម ប្រព័ន្ធធនាគារអាចប្រឈមនឹងហានិភ័យមួយចំនួនដូចជា ការកើនឡើងនៃអនុបាតឥណទានមិនដំណើរការ កំណើនយឺតនៃឥណទាន និងការអូសបន្លាយពេលនៃការរឹតត្បិតលក្ខខណ្ឌហិរញ្ញវត្ថុសកល គួបផ្សំនឹងផលវិបាកដែលនៅសេសសល់ពីវិបត្តិកូវីដ-១៩។ ក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជាបានបង្កើនការតាមដាននិងវាយតម្លៃហានិភ័យ ក៏ដូចជាការវិភាគស៊ីជម្រៅទៅលើហានិភ័យសក្តានុពលនិងឥទ្ធិពលនៃគោលនយោបាយដែលបានដាក់ចេញ ជាពិសេសការធ្វើស្រ្តេសតេស្តជាប្រចាំ ព្រមទាំងការដាក់ចេញនូវវិធានការមីក្រូនិងម៉ាក្រូប្រុងប្រយ័ត្នទាន់ពេលវេលា។ បន្ថែមពីនេះ កិច្ចសហការសម្របសម្រួលពីគ្រប់តួអង្គនៅក្នុងវិស័យហិរញ្ញវត្ថុ គឺជាតម្រូវការចាំបាច់សម្រាប់ដោះស្រាយបញ្ហាប្រឈមនានា ក្នុងគោលបំណងរក្សាស្ថិរភាពហិរញ្ញវត្ថុនៅក្នុងវិស័យនេះ។

## ៣-ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

### ក- ការត្រួតពិនិត្យ

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាបានធ្វើបច្ចុប្បន្នភាពការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយផ្តោតលើការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។

គោលបំណងសំខាន់នៃការត្រួតពិនិត្យជាប្រចាំលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គឺដើម្បីវាយតម្លៃលើបច្ចុប្បន្នភាពនៃហានិភ័យរបស់គ្រឹះស្ថាននីមួយៗ តាមរយៈការអនុវត្តតាមវិធីសាស្រ្តត្រួតពិនិត្យ និងវាយតម្លៃស្រប (SREP)។ SREP ផ្តល់នូវព័ត៌មានសំខាន់ៗនៃស្ថានភាពរបស់គ្រឹះស្ថានពាក់ព័ន្ធនឹងហានិភ័យ ដើមទុន សន្ទនីយភាព ម៉ូឌែលអាជីវកម្ម អភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យ។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវផែនការចុះត្រួតពិនិត្យដល់ទីកន្លែង និងបានជួបប្រជុំជាមួយគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថានជាបន្តបន្ទាប់ ដើម្បីពិភាក្សាអំពីស្ថានភាពនៃអាជីវកម្ម ឥណទានមិនដំណើរការនិងវិធីសាស្រ្តដោះស្រាយ យុទ្ធសាស្រ្តអាជីវកម្ម និងស្ថានភាពឥណទានចំពោះវិស័យអចលនទ្រព្យជាដើម។ ទន្ទឹមនេះ ការធ្វើស្រ្តេសតេស្តក៏ត្រូវបានអនុវត្ត ដើម្បីវាយតម្លៃលើភាពធន់នៃសន្ទនីយភាព និងភាពគ្រប់គ្រាន់នៃដើមទុន និងត្រួតពិនិត្យលើគុណភាពឥណទាន អនុបាតឥណទានមិនដំណើរការ ឥណទានរៀបចំឡើងវិញ លទ្ធភាពស្វែងរកប្រាក់ចំណេញ ព្រមទាំងការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាដើម។

ក្នុងឆមាសទី១ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានទទួលប្រាក់បញ្ញើ ចំនួន ៦ ដោយផ្តោតលើ៖ i/-គុណភាពឥណទាន រួមទាំងការធ្វើចំណាត់ថ្នាក់ឥណទាន ការធ្វើសំវិធានធនលើអ៊ីមភែរមិន ការរៀបចំឥណទានឡើងវិញ ii/-អភិបាលកិច្ច iii/-ការត្រួតពិនិត្យលើការអនុវត្តអនុសាសន៍ និង iv/-ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ ជាលទ្ធផលនៃការត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើភាគច្រើននៅរក្សាបាននូវភាពធន់នៃដើមទុន មានសន្ទនីយភាពគ្រប់គ្រាន់ មានអភិបាលកិច្ចនិងការគ្រប់គ្រងហានិភ័យសមស្រប និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ទោះយ៉ាងណាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួន នៅមានចំណុចខ្វះខាតមួយចំនួនពាក់ព័ន្ធនឹងការត្រួតពិនិត្យ

ផ្ទៃក្នុង និងឯករាជ្យភាពនៃមុខងារប្រតិបត្តិតាមនិងសវនកម្មផ្ទៃក្នុង ការខ្វះខាតការត្រួតពិនិត្យឥណទានឡើងវិញ ការវាយតម្លៃក្នុងការផ្តល់ឥណទានមិនបានពេញលេញ និងការមិនអនុវត្តបានពេញលេញតាមអនុសាសន៍ ដែលទាមទារឱ្យមានការត្រួតពិនិត្យនិងតាមដានជាប្រចាំ និងដាក់ចេញនូវអនុសាសន៍និងវិធានការកែតម្រូវនានា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបន្តវាយតម្លៃប្រចាំត្រីមាសនីមួយៗលើការអនុវត្តតាមអនុសាសន៍នៃរបាយការណ៍ត្រួតពិនិត្យដល់ទីកន្លែង ដោយបានក្រើនរំលឹក និងដាក់វិធានការមួយចំនួនចំពោះគ្រឹះស្ថានណាដែលមិនអនុវត្តបានពេញលេញតាមអនុសាសន៍ និងច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ធនាគារជាតិនៃកម្ពុជា បន្តតាមដានជាប្រចាំលើស្ថានភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ តាមរយៈការត្រួតពិនិត្យលើឯកសារដោយប្រើប្រាស់វិធីសាស្ត្រ CAMELS។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវផែនការចុះត្រួតពិនិត្យដល់ទីកន្លែង ដោយផ្តោតលើ គុណភាពទ្រព្យសកម្ម អភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ក្នុងឆមាសទី១ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន ៣ ក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ១។ ជាលទ្ធផលនៃការត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមួយចំនួនមានការខ្វះខាតផ្នែកអភិបាលកិច្ច ការគ្រប់គ្រងឥណទាន និងមុខងារសវនកម្មផ្ទៃក្នុងនៅមានកម្រិត។ ដើម្បីពង្រឹងស្ថានភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ធនាគារជាតិនៃកម្ពុជាបានបន្តវាយតម្លៃជាប្រចាំ លើការអនុវត្តតាមអនុសាសន៍នៃរបាយការណ៍ត្រួតពិនិត្យដល់ទីកន្លែង ដោយបានក្រើនរំលឹក និងដាក់វិធានការកែតម្រូវចំពោះគ្រឹះស្ថានណាដែលមិនអនុវត្តបានពេញលេញតាមអនុសាសន៍ និងច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ស្របតាមការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យានៅកម្ពុជា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានធនាគារហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើបាននិងកំពុងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដូចជា បញ្ញាសិប្បនិម្មិត សេវាក្លោដ (Cloud) ទិន្នន័យធំ និងប្លុកឆេន (Blockchain) ជាដើម ដើម្បីផ្តល់សេវាធនាគារកាន់តែមានប្រសិទ្ធភាព និងនវានុវត្តន៍។ ក្នុងឆមាសទី១ ធនាគារជាតិនៃកម្ពុជា បានធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំស្តីពី ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យានិងសាយប័ររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រមទាំងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីប្រមូលធាតុចូលបន្ថែម។ ក្នុងក្របខណ្ឌត្រួតពិនិត្យហានិភ័យបច្ចេកវិទ្យា ធនាគារជាតិនៃកម្ពុជាបានត្រួតពិនិត្យលើឯកសារ និងចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន ៤ ដោយផ្តោតទៅលើ អភិបាលកិច្ចព័ត៌មានវិទ្យា ប្រព័ន្ធធនាគារស្នូល ឧបទ្ទវហេតុព័ត៌មានវិទ្យា (Information Technology Incident) ការគ្រប់គ្រងការផ្លាស់ប្តូរ (Change Management) សេវាក្លោដ ប្លុកឆេន ផែនការនិរន្តរភាពអាជីវកម្ម (Business Continuity Plan) និងសវនកម្មព័ត៌មានវិទ្យា។ ជាលទ្ធផល គ្រឹះស្ថានទាំងនោះបានអនុវត្តល្អនូវការគ្រប់គ្រងព័ត៌មានវិទ្យាបទដ្ឋាន ឧត្តមានុវត្ត និងអនុលោមតាមសេចក្តីណែនាំស្តីពី ការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ប៉ុន្តែជារួម គ្រឹះស្ថាននៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ការគ្រប់គ្រងសិទ្ធិអ្នកប្រើប្រាស់ប្រព័ន្ធធនាគារស្នូល ការតាមដានប្រតិបត្តិការជាមួយតតិយភាគីរបស់គ្រឹះស្ថាន ការពឹងផ្អែកលើសលប់លើក្រុមហ៊ុនផ្តល់

សេវាក្លោដតែមួយ និងការខ្វះខាតការធ្វើតេស្តជ្រៀតចូលប្រព័ន្ធ ជាដើម ដែលទាមទារនូវការតាមដាន និងត្រួតពិនិត្យជាប្រចាំលើការអនុវត្តតាមអនុសាសន៍របស់ធនាគារជាតិនៃកម្ពុជា។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្តធ្វើទំនើបកម្មប្រព័ន្ធត្រួតពិនិត្យ ដើម្បីបង្កើនប្រសិទ្ធភាពការងារត្រួតពិនិត្យ និងការធ្វើស្វ័យប្រវត្តិកម្មការងារ ដូចជាប្រព័ន្ធរបាយការណ៍ត្រួតពិនិត្យ ប្រព័ន្ធវិភាគទិន្នន័យ និងប្រព័ន្ធគ្រប់គ្រងលំហូរការងារ ជាដើម។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងប្រើប្រាស់ទាំងធនធានផ្ទៃក្នុង និងបានទំនាក់ទំនងជាមួយក្រុមហ៊ុនផ្គត់ផ្គង់បច្ចេកវិទ្យាត្រួតពិនិត្យ ដើម្បីសិក្សាកាលានុវត្តភាពពីបច្ចេកវិទ្យាថ្មីៗផងដែរ។

### ខ- ការរៀបចំបទប្បញ្ញត្តិ

ដើម្បីជាជំនួយដល់ការងារត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងស្របតាមនិន្នាការតំបន់ និងអន្តរជាតិ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញបទប្បញ្ញត្តិថ្មី និងកែសម្រួលបទប្បញ្ញត្តិដែលមានស្រាប់ជាបន្តបន្ទាប់។ គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០២៥ នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយបន្ថយកម្រិតកំណត់កាតព្វកិច្ចប្រចាំថ្ងៃយ៉ាងតិចពី ៥០% មក ៣០% នៃប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាជាប្រាក់រៀល ដើម្បីអាចបង្កើនសន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងជំរុញលទ្ធភាពប្រើប្រាស់ប្រាក់រៀល។

លើសពីនេះ ប្រកាស និងសេចក្តីណែនាំមួយចំនួនទៀតត្រូវបាននិងកំពុងរៀបចំ រួមមាន៖ i/-ប្រកាសស្តីពីវិធានបុរេសកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ii/-ប្រកាសស្តីពីការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iii/-ប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iv/-ប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ v/-ប្រកាសពាក់ព័ន្ធនឹងក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ vi/-ប្រកាសស្តីពីការគួបសរុបផ្នែកបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង vii/-សេចក្តីណែនាំស្តីពីការវាយតម្លៃទ្រព្យធានាក្នុងគោលបំណងវាយតម្លៃលើអ៊ីមភែរមិន។

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងរៀបចំសេចក្តីព្រាងប្រកាស ស្តីពីកិច្ចការពារប្រាក់បញ្ញើ ដើម្បីមានមូលដ្ឋានក្នុងការអនុវត្តយន្តការកិច្ចការពារប្រាក់បញ្ញើសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញ-វត្ថុទទួលប្រាក់បញ្ញើ ក្នុងគោលដៅរួមចំណែកការពារអ្នកដាក់ប្រាក់បញ្ញើ រក្សាទំនុកចិត្តសាធារណជន និងរក្សាស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ។

ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងរៀបចំបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងគោលបំណងផ្តល់អាជ្ញាបណ្ណដល់គ្រឹះស្ថានគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលការរៀបចំបទប្បញ្ញត្តិនេះជាជំហានដ៏សំខាន់មួយក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់កម្ពុជា ដោយគាំទ្រដល់ការដោះស្រាយការកើនឡើងនៃឥណទានមិនដំណើរការនៅក្នុងប្រព័ន្ធធនាគារ។

### គ- ការកែលម្អទម្រង់របាយការណ៍ត្រួតពិនិត្យ

ទម្រង់របាយការណ៍ត្រួតពិនិត្យចំនួន ៥០ ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកំពុងរាយការណ៍មកធនាគារជាតិនៃកម្ពុជាត្រូវបានធ្វើបច្ចុប្បន្នកម្ម និងដាក់ឱ្យអនុវត្តពេញលេញស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ-ទទួលប្រាក់បញ្ញើ ដើម្បីបន្តពង្រឹងភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ សង្គតិភាព និងអត្ថប្រយោជន៍នៃទិន្នន័យផ្នែកត្រួតពិនិត្យ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាស្តីពីរបាយការណ៍ត្រួតពិនិត្យទម្រង់ថ្មី ដើម្បីណែនាំអំពីការអនុវត្ត និងប្រមូលធាតុចូលអំពីបញ្ហាប្រឈមដែលគ្រឹះស្ថានបានជួបប្រទះក្នុងអំឡុងពេលនៃការរាយការណ៍ដូចជា ចែករំលែកអំពីកំហុសឆ្គងកើតឡើងជាញឹកញាប់ក្នុងការរៀបចំរបាយការណ៍ទាំងនេះ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានពិនិត្យ ផ្ទៀងផ្ទាត់ និងរៀបចំរបាយការណ៍គួបសរុបរបស់ប្រព័ន្ធធនាគារទាំងមូល ព្រមទាំងបានសហការក្នុងការឆ្លើយតបនឹងសំណើសុំផ្តល់ទិន្នន័យ សម្រាប់ការសិក្សាស្រាវជ្រាវ ការវិភាគការរៀបចំគោលនយោបាយ និងការប្រើប្រាស់ផ្សេងៗដល់ភាគីពាក់ព័ន្ធ ដែលរួមមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងស្ថាប័នអន្តរជាតិដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ និងធនាគារពិភពលោក ជាដើម។

ទន្ទឹមនេះ ដើម្បីបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងអនុវត្តស្របតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ធនាគារជាតិនៃកម្ពុជា បាននិងកំពុងដាក់បញ្ចូលទម្រង់របាយការណ៍ត្រួតពិនិត្យថ្មីចំនួន ២៣ ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើរាយការណ៍មកធនាគារជាតិនៃកម្ពុជាទៅក្នុងប្រព័ន្ធរាយការណ៍របាយការណ៍ត្រួតពិនិត្យ។

### ៤- ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ

បរិយាបន្នហិរញ្ញវត្ថុ នៅតែជាការងារអាទិភាពមួយរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ទាន់ពេលវេលា តម្លៃសមរម្យ និងមានកិច្ចការពារតាមផ្លូវច្បាប់សម្រាប់ប្រជាជនគ្រប់រូប ជាពិសេសជនក្រីក្រ ប្រជាជននៅតាមទីជនបទ ស្ត្រី និងសហគ្រាសធុនមីក្រូ តូច និងមធ្យម។ ផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ត្រូវបានបន្តអនុវត្តយ៉ាងសកម្មតាមរយៈយុទ្ធនាការផ្សព្វផ្សាយ កម្មវិធីអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងយន្តការនានាជាច្រើនទៀត ដូចជា ការពង្រឹងក្របខ័ណ្ឌច្បាប់ នវានុវត្តន៍ឌីជីថល និងកិច្ចសហប្រតិបត្តិការអន្តរវិស័យជាមួយដៃគូសំខាន់ៗជាច្រើនរួមមាន ក្រសួង-ស្ថាប័នវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ ដើម្បីធានាឱ្យបាននូវវិស័យហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន និងនិរន្តរភាព។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ ការងារលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងតាមរយៈ i/-កំណើនចំនួនអ្នកដាក់ប្រាក់បញ្ញើ ១៣,៩% ដល់ ១៥,៧ លាននាក់ ធៀបនឹងដំណាច់ឆ្នាំ ២០២៤ និងចំនួនអ្នកប្រើប្រាស់សេវាឥណទានកើន ២២,៧% ដល់ ៤,៥ លាននាក់ ii/-ចំនួនប្រតិបត្តិការបាគងកើន ៣៥,៩% ដល់ ៥១៤,៧ លានប្រតិបត្តិការ iii/-ចំនួនពាណិជ្ជករដែលបានចុះឈ្មោះប្រើប្រាស់ខេអេចឃ្យូអរកូតបានកើនដល់ប្រមាណ ៤,៩ លានគណនី និង iv/-គណនីអ៊ីវ៉ាឡេតកើនដល់ប្រមាណ ២២,៩ លានគណនី។

**ក្រាហ្វ ៦១ ៖ ចំនួនអ្នកដាក់ប្រាក់បញ្ញើ និងអ្នកប្រើប្រាស់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**
(គិតជាលាន, ឆ្នាំ២០២៤ - ឆមាសទី១ ឆ្នាំ២០២៥ប)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា, សម្គាល់៖ ប=ប៉ាន់ស្មាន (ទិន្នន័យជាក់ស្តែងគិតត្រឹមខែមីនាឆ្នាំ២០២៥)

## ក- កិច្ចការពារអតិថិជន

ដើម្បីរួមចំណែកបង្កើនជំនឿទុកចិត្តរបស់សាធារណជន ក៏ដូចជាចូលរួមដោះស្រាយបញ្ហារបស់អ្នកប្រើប្រាស់សេវានិងផលិតផលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឱ្យកាន់តែមានប្រសិទ្ធភាពទាន់ពេលវេលា និងមានសង្គតិភាព ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធទូរស័ព្ទហតឡាញចំនួន ២៦ ខ្សែ (ទីស្នាក់ការកណ្តាលចំនួន ៥ ខ្សែ និងសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្តចំនួន ២១ ខ្សែ) ដើម្បីផ្តល់លទ្ធភាពបន្ថែមដល់អ្នកប្រើប្រាស់អាចដាក់ពាក្យបណ្តឹង ស្នើសុំអន្តរាគមន៍ ឬសាកសួរព័ត៌មានផ្សេងៗពាក់ព័ន្ធការប្រើប្រាស់សេវា និងផលិតផលហិរញ្ញវត្ថុ។

ធនាគារជាតិនៃកម្ពុជា បានទទួលបណ្តឹង និងការសាកសួរតាមរយៈប្រព័ន្ធហតឡាញសរុបចំនួន ២៨៩ ករណី ដែលបណ្តឹងនៅទីស្នាក់ការកណ្តាលមានចំនួន ២១៥ ករណី និងនៅតាមសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្តមានចំនួន ៧៤ ករណី។ បណ្តឹងនិងការសាកសួរទាំងនេះពាក់ព័ន្ធនឹង i/-ការស្នើសុំបង់ផ្តាច់មុនកាលកំណត់ ii/-ការស្នើសុំរៀបចំឥណទានឡើងវិញ iii/-ការដកទ្រព្យធានាឥណទាន iv/-ការស្នើសុំកែតម្រូវព័ត៌មានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន v/-ការស្នើសុំបន្ធូរបន្ថយប្រាក់ពិន័យ និង vi/-ការឆបោកតាមប្រព័ន្ធឌីជីថល។

បន្ថែមលើនេះ យន្តការគ្រប់គ្រងនិងដោះស្រាយបណ្តឹងអតិថិជនត្រូវបានពង្រឹងជាបន្តបន្ទាប់តាមរយៈការពិនិត្យនិងកែសម្រួលឡើងវិញនូវប្រកាសស្តីពី ការដោះស្រាយបណ្តឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីឱ្យស្របនឹងការវិវត្តនៃប្រព័ន្ធធនាគារ។

## ខ- ចំណេះដឹងផ្នែកហិរញ្ញវត្ថុ

កម្មវិធីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងយុទ្ធនាការផ្សព្វផ្សាយជាច្រើន ត្រូវបានរៀបចំឡើងជាប្រចាំ ដើម្បីផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ កិច្ចការពារអតិថិជន និងហានិភ័យនៃកម្ចីក្រៅផ្លូវការដល់អាជ្ញាធរពាក់ព័ន្ធនិងប្រជាពលរដ្ឋ ព្រមទាំងប្រមូលធាតុចូលពាក់ព័ន្ធនឹងការប្រើប្រាស់កម្ចីក្រៅផ្លូវការ។ កម្មវិធីទាំងនេះរួមមាន៖ i/-សិក្ខាសាលាស្តីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន" នៅខេត្តតាកែវ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ii/-សិក្ខាសាលា

ផ្សព្វផ្សាយ និងប្រមូលធាតុចូល ស្តីពី "ការប្រើប្រាស់ផលិតផល និងសេវាហិរញ្ញវត្ថុ" នៅឃុំឈូក និងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ iii/-កម្មវិធី "តោះ ! និយាយអំពីហិរញ្ញវត្ថុ និងឌីជីថល" លើកទី៣ ក្រោមប្រធានបទ "ស្ថិរភាពហិរញ្ញវត្ថុ និងការរីកចម្រើនរយៈពេលវែង" ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី (WEDC) នៃក្រសួងកិច្ចការនារី iv/-គម្រោង "រៀនពីលុយ ៣.០" ដែលផ្តួចផ្តើមឡើងដោយសភាយុវជននៃសហភាពសហព័ន្ធយុវជនកម្ពុជា ខេត្តស្វាយរៀង សម្រាប់សិស្សានុសិស្សនៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តតាកែវ v/-សិក្ខាសាលាស្តីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងសហគ្រិនភាពដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ" ដែលសហការរៀបចំដោយធនាគារជាតិនៃកម្ពុជា និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីផ្សព្វផ្សាយ និងគាំទ្រការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ និង vi/-កម្មវិធីចែករំលែកចំណេះដឹងស្តីពី ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធនាគារ និងបរិយាបន្នហិរញ្ញវត្ថុ នៅតាមសាកលវិទ្យាល័យ និងសាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ចាម និងខេត្តបាត់ដំបង។ អ្នកចូលរួមក្នុងកម្មវិធីខាងលើនេះ មានចំនួនសរុបប្រមាណ ២.៨០០ នាក់។



សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងសហគ្រិនភាព ដល់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ" នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៥ នៅ IBS



សិក្ខាសាលា ស្តីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន" នាថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥ នៅខេត្តតាកែវ

## គ- ហិរញ្ញវត្ថុប្រកបដោយចីរភាព

នៅក្នុងបរិបទការប្រែប្រួលដ៏លឿននៃសេដ្ឋកិច្ច បរិស្ថាន និងសង្គម ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ ត្រូវបានផ្សាភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការអភិវឌ្ឍប្រកបដោយចីរភាព។ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាធនាគារកណ្តាល មានតួនាទីសំខាន់ក្នុងការធានាថាប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជាមានស្ថិរភាព និងមានសមត្ថភាពឆ្លើយតបនឹងហានិភ័យបច្ចុប្បន្ន និងអនាគត។ ការងារហិរញ្ញវត្ថុប្រកបដោយចីរភាពជាការងារចម្បងថ្មីមួយដែលធនាគារជាតិនៃកម្ពុជា តែងតែយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាភាពធន់ និងបង្ការហានិភ័យផ្សេងៗដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុមកលើប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ក៏ដូចជាចូលរួមអនុវត្តគោលនយោបាយ និងគំនិតផ្តួចផ្តើមនានាពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន សង្គម និងអភិបាលកិច្ច។

សមិទ្ធផលសំខាន់ៗនៅក្នុងការងារហិរញ្ញវត្ថុប្រកបដោយចីរភាព ត្រូវបានសម្រេចបានជោគជ័យតាមរយៈការខិតខំប្រឹងប្រែង និងកិច្ចសហការយ៉ាងល្អពីគ្រប់ភាគីពាក់ព័ន្ធ។ ជាក់ស្តែង ក្រុមការងារហិរញ្ញវត្ថុបៃតងអន្តរក្រសួង ត្រូវបានបង្កើតឡើងដោយមានសមាជិកពីក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន ១៣ ដើម្បីទទួលបន្ទុកផ្តល់អនុសាសន៍ និងប្រឹក្សាយោបល់លើការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមថ្មីៗ ដើម្បីជំរុញការអនុវត្តការងារហិរញ្ញវត្ថុបៃតងនៅកម្ពុជា។ ទន្ទឹមនេះ

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងនៃប្រព័ន្ធវដ្តករសាស្ត្រហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា ត្រូវបានរៀបចំដើម្បីប្រមូលធាតុចូលពីអ្នកប្រើប្រាស់ពាក់ព័ន្ធដើម្បីធានាថាប្រព័ន្ធវដ្តករសាស្ត្រនេះមានភាពសមស្របអាចអនុវត្តបាននៅក្នុងបរិបទប្រទេសកម្ពុជា។ ផែនទីចង្អុលទិសសម្រាប់ហិរញ្ញវត្ថុបៃតងនៅកម្ពុជា ក៏កំពុងស្ថិតនៅក្នុងការសិក្សាពិគ្រោះយោបល់ ដែលមានសសរស្តម្ភចំនួន ៣ រួមមាន៖ i/-ការបង្កបរិយាយកាសអំណោយផលដល់ហិរញ្ញវត្ថុប្រកបដោយចីរភាព ii/-ផ្នែកផ្គត់ផ្គង់ហិរញ្ញវត្ថុប្រកបដោយចីរភាព និង iii/-ផ្នែកតម្រូវការហិរញ្ញវត្ថុប្រកបដោយចីរភាព។

ជារួម ប្រព័ន្ធធនាគារនៅកម្ពុជាបន្តរក្សាបានភាពរឹងមាំតាមរយៈភាពធន់នៃដើមទុន និងកម្រិតសន្ទនីយភាពខ្ពស់ បើទោះបីជាឥណទាននៅមានកំណើនទាប និងការកើនឡើងនៃឥណទានមិនដំណើរការក៏ដោយ។ ដើម្បីរក្សាបានភាពធន់និងទប់ស្កាត់ហានិភ័យទាំងនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងពង្រឹងជាបន្តបន្ទាប់លើ៖ i/-ការតាមដាន ការវិភាគ និងវាយតម្លៃហានិភ័យជាពិសេសហានិភ័យជាប្រព័ន្ធ ដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ ii/-ការធ្វើស្រ្តេសតេស្ត iii/-ការអនុវត្តក្របខ័ណ្ឌនៃការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្អែកលើហានិភ័យនិងទស្សនៈអនាគត iv/-ការដាក់ចេញនូវវិធានការម៉ាក្រូប្រុងប្រយ័ត្ន និងវិធានការកែតម្រូវ v/-ការរៀបចំប្រព័ន្ធព្រមាននិងឧបករណ៍ម៉ាក្រូប្រុងប្រយ័ត្នផ្សេងៗទៀត vi/-ការអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យផ្អែកហានិភ័យបច្ចេកវិទ្យា vii/-ការអនុវត្តតាមស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និង viii/-ការបង្កើនប្រសិទ្ធភាពប្រព័ន្ធរាយការណ៍នានា។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបន្តកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិ ដូចជា សមាគមធនាគារ សមាគមមីក្រូហិរញ្ញវត្ថុ មូលនិធិរូបិយវត្ថុអន្តរជាតិ អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារវាយតម្លៃឥណទានអន្តរជាតិ (SP Global) ដើម្បីពង្រឹងប្រសិទ្ធភាពនិងបង្កើនសមិទ្ធផលការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ក៏ដូចជាឆ្លើយតបនឹងបញ្ហាប្រឈមថ្មីៗ។ ជាមួយគ្នានេះដែរ ការងារលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ កិច្ចការពារអតិថិជននិងកិច្ចការពារប្រាក់បញ្ញើ ត្រូវបានបន្តអនុវត្តយ៉ាងសកម្មដោយផ្តោតលើការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងនវានុវត្តន៍ឌីជីថល។ ជាងនេះទៀត ធនាគារជាតិនៃកម្ពុជាបានដឹកនាំក្រុមការងារហិរញ្ញវត្ថុបៃតងអន្តរក្រសួង និងបង្កើតក្រុមការងារហិរញ្ញវត្ថុប្រកបដោយចីរភាព ផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ដើម្បីជំរុញការចូលរួមនិងការអនុវត្តយុទ្ធសាស្ត្រថ្មីៗនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាប្រកបដោយចីរភាព។

## IV- ការផ្តល់ផ្តល់សេវាធនាគារកណ្តាល

### ១- ប្រព័ន្ធទូទាត់សងប្រាក់

#### ក- ស្ថានភាពទូទៅនៃប្រព័ន្ធទូទាត់សងប្រាក់

ក្នុងគោលបំណងបង្កើនការប្រើប្រាស់មធ្យោបាយទូទាត់ជាឌីជីថល សម្រួលដល់សាធារណជនឱ្យមានភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់សងប្រាក់អន្តរគ្រឹះស្ថាន កាត់បន្ថយចំណាយប្រតិបត្តិការ និងចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួម កាលពីខែឧសភា ឆ្នាំ២០២៤ ដែលធ្វើសមាហរណកម្មប្រព័ន្ធទូទាត់សងប្រាក់ចម្បងៗទៅជាប្រព័ន្ធតែមួយ។ ប្រព័ន្ធទូទាត់សងប្រាក់រួមនេះ ត្រូវបានប្រើប្រាស់ជាហេដ្ឋារចនាសម្ព័ន្ធគ្រឹះ ដែលរួមមានម៉ូឌុលបាគង និងម៉ូឌុលទូទាត់សុទ្ធ ក្នុងនោះម៉ូឌុលបាគងរួមមានសេវាទូទាត់បាគង និងសេវាទូទាត់បាគងតម្លៃធំ ហើយម៉ូឌុលទូទាត់សុទ្ធរួមមាន សេវាប័ណ្ណទូទាត់ និងសេវាទូទាត់មូលប្បទានបត្រ។ បច្ចុប្បន្ន គ្រឹះស្ថានចំនួន ៥៥ បានដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់សងប្រាក់រួម និង ១៨ គ្រឹះស្ថានផ្សេងទៀតកំពុងតភ្ជាប់ប្រព័ន្ធ។ ទន្ទឹមនេះ វិធាននិងនីតិវិធី ព្រមទាំងឯកសារគតិយុត្តផ្សេងៗក៏បាននិងកំពុងរៀបចំក្នុងគោលបំណងគាំទ្រកិច្ចដំណើរការប្រព័ន្ធនិងទុកជាចំណងផ្លូវច្បាប់សម្រាប់គ្រប់គ្រឹះស្ថានជាសមាជិក។ វិធាននិងនីតិវិធីនេះនឹងកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធ ក៏ដូចជាគោលការណ៍ណែនាំផ្សេងៗ ដើម្បីកាត់បន្ថយហានិភ័យនៅក្នុងប្រព័ន្ធ និងទទួលបានទំនុកចិត្តពីសាធារណជន។ ប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់រួមមាន ៥៩៩,៧ លានប្រតិបត្តិការ ដែលស្មើនឹងទំហំទឹកប្រាក់ ៣,៣ ដង នៃផ.ស.ស. ស្របពេលដែលប្រតិបត្តិការប្រព័ន្ធធនាគារអេឡិចត្រូនិកមាន ៩៩,៩ ពាន់ប្រតិបត្តិការ ដែលស្មើនឹងទំហំទឹកប្រាក់ ១,៦ ដង នៃផ.ស.ស.។

សេវាទូទាត់សងប្រាក់ឌីជីថលបន្តចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការទូទាត់ទំនិញ និងសេវាបានយ៉ាងងាយស្រួល រហ័ស និងមានកម្រៃសេវាសមរម្យ។ គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ បាននិងកំពុងដាក់ឱ្យប្រើប្រាស់សេវាទូទាត់សងប្រាក់យ៉ាងសម្បូរបែបលើថ្នាលឌីជីថលដូចជា សេវាធនាគារចល័ត សេវាធនាគារអ៊ីនធឺណេត គណនីអ៊ីវ៉ាឡេត ដែលអនុញ្ញាតឱ្យធ្វើប្រតិបត្តិការផ្ទេរប្រាក់ ដាក់/ដកប្រាក់ ទូទាត់វិក្កយបត្រ ផ្ទេរប្រាក់ឆ្លងដែន និងការទូទាត់តាមរយៈឃ្យូអរកូតជាដើម។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥ គ្រឹះស្ថានទទួលបានអាជ្ញាបណ្ណផ្តល់សេវាទូទាត់សងប្រាក់មាន ៣០ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលបានលិខិតអនុញ្ញាតផ្តល់សេវាទូទាត់សងប្រាក់មាន ៣ ដោយមានគណនីអ៊ីវ៉ាឡេតសរុប ២០,៥ លានគណនី។ ទន្ទឹមនេះ ប្រតិបត្តិការនៃសេវាទូទាត់សងប្រាក់ជារៀលសរុបមានចំនួន ៦៦០,៦ លានប្រតិបត្តិការ (កើនឡើង ១,២៥ ដង) ដែលស្មើនឹង ២៣៥,៩ ទ្រីលានរៀល (កើនឡើង ៣៦%) និងប្រតិបត្តិការជាដុល្លារអាមេរិកមាន ១,១ ប៊ីលានប្រតិបត្តិការ (កើនឡើង ៣៣%) ដែលស្មើនឹង ១៧៧,៥ ប៊ីលានដុល្លារអាមេរិក (កើនឡើង ២៨%)។

#### ខ- ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់

ក្នុងគោលបំណងកាត់បន្ថយហានិភ័យចម្បងៗ ដែលអាចនឹងកើតមានលើប្រព័ន្ធទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានអនុវត្តការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ជាប្រចាំ។ ក្នុងឆមាសទី១ ឆ្នាំ២០២៥នេះ ប្រព័ន្ធបាគងត្រូវបានត្រួតពិនិត្យ និងវាយតម្លៃធៀបជាមួយគោលការណ៍សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ក្នុងនោះមានគោលការណ៍ចំនួន ១៦ ក្នុងចំណោមគោលការណ៍ទាំងអស់ដែលមានភាពសមស្រប និងត្រូវបានជ្រើសរើសមកវាយតម្លៃប្រព័ន្ធបាគង។

ក្រោយពីការត្រួតពិនិត្យ ជាលទ្ធផល ប្រព័ន្ធបាគងបានអនុលោមតាមគោលការណ៍ PFMI បានល្អ ធានាបាននូវប្រសិទ្ធភាព និងសុវត្ថិភាពប្រព័ន្ធ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានអង្កេត និងតាមដានត្រួតពិនិត្យលើប្រតិបត្តិការ និងឧប្បត្តិហេតុប្រព័ន្ធទូទាត់សងប្រាក់ជាប្រចាំ និងបាន រៀបចំគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងផែនការនិរន្តរភាពសម្រាប់ប្រព័ន្ធទូទាត់ និងបន្ត រៀបចំឯកសារផែនការនិរន្តរភាពសម្រាប់ប្រព័ន្ធទូទាត់នៅកម្ពុជា ដើម្បីការពារនិងពង្រឹងបន្ថែមលើ ប្រតិបត្តិការប្រចាំថ្ងៃនៃដំណើរការប្រព័ន្ធទូទាត់សងប្រាក់។

### គ- ការទូទាត់ និងផ្ទេរប្រាក់ឆ្លងដែន

គម្រោងទូទាត់ឆ្លងដែនទ្វេភាគី[២៧]តាមយ្យូអរកូតត្រូវបានដាក់ឱ្យដំណើរការដំណាក់កាលទី២[២៨] ជាមួយក្រុមហ៊ុនអន្តរជាតិយូញៀនផេ (UPI) និង ប្រទេសម៉ាឡេស៊ី ព្រមទាំងបានចុះអនុស្សរណៈ យោគយល់ជាមួយប្រទេសហ្វីលីពីន និងឥណ្ឌូណេស៊ី ហើយគ្រោងនឹងដាក់ឱ្យដំណើរការជាមួយ ប្រទេសសិង្ហបុរី ជប៉ុន និងឥណ្ឌា ក្នុងពេលឆាប់ៗខាងមុខ។

ដើម្បីជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពង្រឹងសុវត្ថិភាពនិងប្រសិទ្ធភាពប្រតិបត្តិការ ទូទាត់ឆ្លងដែន ជាពិសេសចូលរួមក្នុងការដោះស្រាយវិវាទប្រតិបត្តិការទូទាត់ឆ្លងដែនជាមួយភាគី ពាក់ព័ន្ធឱ្យទាន់ពេលវេលា សេចក្តីណែនាំស្តីពី ការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការទូទាត់សងប្រាក់ នៅកម្ពុជា និងប្រតិបត្តិការទូទាត់សងប្រាក់ឆ្លងដែន ត្រូវបានដាក់ចេញនាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥។



ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយ្យូអរកូត ដំណាក់កាលទី២ រវាងធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនអន្តរជាតិ យូញៀនផេ (បាគងស្កេនUnionPay) នាថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ



ពិធីដាក់ឱ្យដំណើរការជាផ្លូវការការទូទាត់ឆ្លងដែនតាមយ្យូអរកូត ដំណាក់កាលទី២រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសម៉ាឡេស៊ី (កម្ពុជាស្កេនម៉ាឡេស៊ី) នាព្រឹកថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

ធនាគារជាតិនៃកម្ពុជាបានចូលជាសមាជិកអង្កេតការណ៍ពិសេសក្នុងគម្រោង NEXUS ដែលផ្តួចផ្តើមអភិវឌ្ឍដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ក្នុងគោលដៅពន្លឿនការតភ្ជាប់ ការទូទាត់ឆ្លងដែន និងបង្កើនប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែនពហុភាគីដោយប្រើប្រាស់រូបិយប័ណ្ណ ចម្រុះ និងរូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាល (CBDCs)។

---

[២៧] ការទូទាត់ឆ្លងដែន បានធ្វើឡើងជាមួយប្រទេសថៃ ឡាវ វៀតណាម កូរ៉េខាងត្បូង ម៉ាឡេស៊ី និងចិនតាមរយៈក្រុមហ៊ុនអាលីផេ (Alipay Connect Pte. Ltd.)ព្រមទាំងក្រុមហ៊ុនអន្តរជាតិយូញៀនផេ (UPI)។ លើសពីនេះ ធនាគារជាតិនៃកម្ពុជា បានចុះអនុស្សរណៈយោគយល់ជាមួយ ប្រទេសទីម័រខាងកើត វ៉ាន់ដា កោះសូឡូម៉ូន ហ្វីជី ម៉ាដាហ្គាស្កា បូតង់ ឡេសូតូ និងប៉ាគីស្ថាន ដើម្បីចែករំលែកបទពិសោធន៍និងផ្លាស់ប្តូរ ចំណេះដឹងពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់។

[២៨] គម្រោងទូទាត់ឆ្លងដែនទ្វេភាគីតាមយ្យូអរកូតចែកចេញជាពីរដំណាក់កាល ដែលក្នុងដំណាក់កាលទី១ ប្រជាជនកម្ពុជាដែលប្រើប្រាស់ ប្រព័ន្ធបាគងអាចធ្វើការស្កេនទូទាត់នៅប្រទេសដៃគូ និងដំណាក់កាលទី២ ប្រជាជនប្រទេសដៃគូអាចធ្វើការស្កេនទូទាត់នៅប្រទេសកម្ពុជា។

### ឃ- នវានុវត្តន៍ហិរញ្ញវត្ថុ

ប្រព័ន្ធបាគងត្រូវបានបន្តជំរុញ និងអភិវឌ្ឍប្រកបដោយនវានុវត្តន៍ តាមរយៈ៖ i/-ការអភិវឌ្ឍ និងដាក់ឱ្យដំណើរការសាកល្បងសេវាទូទាត់តម្លៃធំបាគង ii/-ការពង្រីកលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធបាគងសម្រាប់សេវាសាធារណៈនៅតាមបញ្ជរច្រកចេញចូលតែមួយ iii/-ការអភិវឌ្ឍមុខងារបន្ថែមក្នុងប្រព័ន្ធបាគងដូចជា ការបញ្ចូលប្រាក់តាមបណ្ណទូទាត់ សេវាបន្ថែមក្នុងកម្មវិធីទូទាត់បាគងទេសចរ ការបង្កើតបណ្ណទូទាត់និម្មិតបាគង និងការតភ្ជាប់គណនីបាគង (គ្រឹះស្ថានសមាជិក ២៧ បានដាក់ឱ្យដំណើរការជាផ្លូវការនិងមួយចំនួនទៀតកំពុងធ្វើសន្ទានកម្ម) iv/-ការពិនិត្យលទ្ធភាពស្នើសុំក្រសួងមហាផ្ទៃ (ម្ចាស់ទិន្នន័យអត្តសញ្ញាណកម្ម) ប្រើប្រាស់ការផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនជាអេឡិចត្រូនិក សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ v/-ការអភិវឌ្ឍនិងគ្រោងដាក់ឱ្យដំណើរការកម្មវិធីបាគងយុវជន ដើម្បីសម្រួលដល់អនីតិជន ដែលពុំទាន់មានអត្តសញ្ញាណបណ្ណ អាចប្រើប្រាស់បណ្ណសម្គាល់ខ្លួនសិស្សក្នុងការចុះឈ្មោះប្រើប្រាស់កម្មវិធីបាគងយុវជនសម្រាប់ទូទាត់ និង vi/-ការពង្រីកលទ្ធភាពក្នុងការប្រើប្រាស់កម្មវិធីទូទាត់បាគងទេសចរឱ្យកាន់តែទូលំទូលាយនិងងាយស្រួល ដោយតភ្ជាប់កម្មវិធីទូទាត់បាគងទេសចរជាមួយបណ្ណទូទាត់អន្តរជាតិផ្សេងទៀត បន្ថែមលើ Mastercard និង VISA។ សេចក្តីណែនាំស្តីពី “ការលើកកម្ពស់ការទូទាត់តាមខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ពាណិជ្ជករ” ក៏ត្រូវបានដាក់ចេញ ដើម្បីផ្តល់ភាពងាយស្រួលដល់អាជីវករដែលទទួលការទូទាត់ពីភ្ញៀវទេសចរ។ លើសពីនេះ ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ត្រូវបាននិងកំពុងសិក្សារៀបចំធ្វើបច្ចុប្បន្នកម្ម ដើម្បីជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ។






ពិធីដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរ ជាមួយក្រុមហ៊ុនបណ្តាញបណ្ណទូទាត់អន្តរជាតិ VISA
នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា






ពិធីដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរ ជាមួយក្រុមហ៊ុនបណ្តាញបណ្ណទូទាត់អន្តរជាតិ Mastercard
នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅធនាគារជាតិនៃកម្ពុជា

## ២- សេវាទូទាត់សងប្រាក់

ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ដែលអភិវឌ្ឍដោយធនាគារជាតិនៃកម្ពុជាចែកជា ២ គឺ ប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS) និងប្រព័ន្ធទូទាត់សងប្រាក់រួម។

**i/- ប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS)៖** ប្រព័ន្ធ OBS មានសមាជិកចំនួន ៨៦ ដែលក្នុងនោះមានធនាគារពាណិជ្ជ ៥៧ ធនាគារឯកទេស ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ១៧ និងស្ថាប័នរដ្ឋ ២ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។ ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS សរុបមាន ៩៤,៤ ពាន់ប្រតិបត្តិការ ដែលស្មើនឹង ២៩៧ ទ្រីលានរៀល (កើន ២៣% ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤)។ ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាលជារៀលតាមប្រព័ន្ធ OBS មាន ២៧,៩ ពាន់ប្រតិបត្តិការ ដែលស្មើនឹង ៧៨,២ ទ្រីលានរៀល (កើន ២០%) និងជាដុល្លារអាមេរិកមាន ១៦ ពាន់ប្រតិបត្តិការ ដែលស្មើនឹង ៥១,២ ប៊ីលានដុល្លារអាមេរិក (កើន ២១%)។ ទន្ទឹមនេះ ការផ្ទេរប្រាក់ជាមួយសាខាធនាគារជាតិនៃកម្ពុជាជារៀលតាមប្រព័ន្ធ OBS មាន ២៧១ ប្រតិបត្តិការ ដែលស្មើនឹង ៤,៨ ទ្រីលានរៀល (កើន ៤៣%) និងជាដុល្លារអាមេរិកមាន ១៥៨ ប្រតិបត្តិការ ដែលស្មើនឹង ២,៣ ប៊ីលានដុល្លារអាមេរិក (កើន ២,៦ ដង)។

**ក្រាហ្វ ៦២៖ ការផ្ទេរប្រាក់រៀលតាមប្រព័ន្ធ OBS**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦៣៖ ការផ្ទេរប្រាក់ដុល្លារអាមេរិកតាមប្រព័ន្ធ OBS**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ii/- ប្រព័ន្ធទូទាត់សងប្រាក់រួម៖** ប្រព័ន្ធនេះចែកចេញជា ២ម៉ូឌុល គឺ ម៉ូឌុលបាគង និង ម៉ូឌុលទូទាត់សុទ្ធ។

**- ម៉ូឌុលបាគង** មានសេវាទូទាត់បាគង និងសេវាទូទាត់បាគងតម្លៃធំ (Bakong LVPs)។

សេវាទូទាត់បាគង មានសមាជិកចំនួន ៦២ ដែលកំពុងដំណើរការជាផ្លូវការ និងចំនួន ៩ ដែលកំពុងធ្វើសន្ទានកម្មប្រព័ន្ធ។ សេវាទូទាត់បាគងមានប្រតិបត្តិការជារៀល ៣០៣,៣ លានប្រតិបត្តិការ (កើន ២ ដង ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤) ដែលស្មើនឹង ១២៨,៦ ទ្រីលានរៀល (កើន ៦២,២%) និងប្រតិបត្តិការជាដុល្លារអាមេរិក ២៤០,៨ លានប្រតិបត្តិការ (កើន ៨៨,១%) ដែលស្មើនឹង ៦៨,៩ ប៊ីលានដុល្លារអាមេរិក (កើន ៥៤,៩%)។

**ក្រាហ្វ ៦៤៖ ការទូទាត់ជារៀលតាមសេវាទូទាត់បាគង**

(ឆមាសទី២ ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦៥៖ ការទូទាត់ជាដុល្លារអាមេរិកតាមសេវាទូទាត់បាគង**

(ឆមាសទី២ ឆ្នាំ២០១៩ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សេវាទូទាត់បាគងតម្លៃធំត្រូវបានដាក់ឱ្យដំណើរការសាកល្បងនាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ហើយបច្ចុប្បន្នមានគ្រឹះស្ថានចំនួន ៤៦ កំពុងប្រើប្រាស់។ ក្នុងឆមាសទី១ ឆ្នាំ ២០២៥នេះ ប្រតិបត្តិការទូទាត់តាមសេវាទូទាត់បាគងតម្លៃធំមាន ៥.៣៦៨ ប្រតិបត្តិការ ក្នុងនោះ ៥៦៩ ប្រតិបត្តិការជារៀល (ថយ -១៣,៤%) ស្មើនឹង ៣០៥,១ ប៊ីលានរៀល (ថយ -៩,២%) និង ៤.៧៩៩ ប្រតិបត្តិការជាដុល្លារអាមេរិក (កើន ៥២,២%) ស្មើនឹង ៧៨៣,៩ លានដុល្លារអាមេរិក (កើន ៤៤,១%)។

**ក្រាហ្វ ៦៦៖ ការទូទាត់ប្រាក់រៀលតាមសេវាទូទាត់បាគងតម្លៃធំ**

(ឆមាសទី២ ឆ្នាំ២០២៤ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦៧៖ ការទូទាត់ប្រាក់ដុល្លារអាមេរិកតាមសេវាទូទាត់បាគងតម្លៃធំ**

(ឆមាសទី២ ឆ្នាំ២០២៤ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- **ម៉ូឌុលទូទាត់សុទ្ធ** មានសេវាទូទាត់មូលប្បទានប័ត្រ និងសេវាបណ្តូទូទាត់។

សេវាទូទាត់មូលប្បទានប័ត្រមានសមាជិកសរុបចំនួន ៦១ ដែលក្នុងនោះសមាជិកផ្ទាល់ ៤៩ និងសមាជិកមិនផ្ទាល់ ១២។ ការទូទាត់មូលប្បទានប័ត្រចារឹកជារៀលមាន ១៥ ពាន់សន្លឹក (ថយ -៩,១% ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤) ដែលស្មើនឹង ១៤,៤ ទ្រីលានរៀល (កើន ៣៩,៨%) ស្របពេលដែលជាដុល្លារអាមេរិកមាន ៤៩០,២ ពាន់សន្លឹក (ថយ -២,៤%) ដោយស្មើនឹង ២៥,៥ ប៊ីលានដុល្លារអាមេរិក (កើន ១១,៤%)។

**ក្រាហ្វ ៦៨៖ ការទូទាត់ជារៀលតាមសេវាទូទាត់មូលប្បទានប័ត្រ**
(ឆមាសទី១ ឆ្នាំ២០២០-ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៦៩៖ ការទូទាត់ជាដុល្លារអាមេរិកតាមសេវាទូទាត់មូលប្បទានប័ត្រ**
(ឆមាសទី១ ឆ្នាំ២០២០-ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សេវាបណ្ណទូទាត់មានសមាជិកចំនួន ៤៩ (សមាជិកផ្ទាល់ ៤៥ និងសមាជិកមិនផ្ទាល់ ៤) ដែលកំពុងប្រើប្រាស់សេវាបណ្ណទូទាត់ និងគ្រឹះស្ថានចំនួន ១២ កំពុងធ្វើសន្ទានកម្មប្រព័ន្ធ។ សេវាបណ្ណទូទាត់បានដំណើរការទូទាត់ប្រតិបត្តិការជាប្រាក់រៀលចំនួន ៤៦,៣ ពាន់ប្រតិបត្តិការ (ថយ-៥២,៧% ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤) ដែលស្មើនឹង ១១,២ ប៊ីលានរៀល (ថយ -៤៨,៩%) ស្របពេលដែលជាដុល្លារអាមេរិកមាន ៨,៦ ពាន់ប្រតិបត្តិការ (ថយ-៥៨,៥%) ដោយស្មើនឹង ១,២ លានដុល្លារអាមេរិក (ថយ -៥៧,១%)។

**ក្រាហ្វ ៧០៖ ការទូទាត់ជារៀលតាមសេវាបណ្ណទូទាត់**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧១៖ ការទូទាត់ជាដុល្លារអាមេរិកតាមសេវាបណ្ណទូទាត់**
(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣- សេវាគ្រប់គ្រងគណនី

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីសរុបចំនួន ២.៩៣៣ ដែលក្នុងនោះ នៅស្នាក់ការកណ្តាលមាន ២.២១៥ គណនី និងតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជាមាន ៧១៨ គណនី។ គណនីសរុបបានកើនឡើង ៦៤[២៩] គណនី (គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ២៥ គណនី និងស្ថាប័នរដ្ឋ ៣៩ គណនី) ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤។

**ក្រាហ្វ ៧២៖ ចំនួនគណនីតាមប្រភេទគ្រឹះស្ថាន**

(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)[៣០]




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៣៖ ចំនួនគណនីសរុបនៅស្នាក់ការកណ្តាល និងតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជា**

(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)[៣០]




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើរបស់ស្ថាប័នរដ្ឋ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអង្គភាពផ្សេងៗនៅធនាគារជាតិនៃកម្ពុជា ទាំងនៅស្នាក់ការកណ្តាល និងតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជា មានការកើនឡើងធៀបនឹងឆមាសទី១ ឆ្នាំ២០២៤ ដែលក្នុងនោះប្រាក់បញ្ញើជារៀលកើនឡើង ២,៣ ទ្រីលានរៀល (កើន ២១%) និងប្រាក់បញ្ញើជាដុល្លារអាមេរិកកើនឡើង ១,៨ ប៊ីលានដុល្លារអាមេរិក (កើន ១៥%)។

**ក្រាហ្វ ៧៤៖ ប្រាក់បញ្ញើជារៀល នៅធនាគារជាតិនៃកម្ពុជា**

(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)[៣១]




**ក្រាហ្វ ៧៥៖ ប្រាក់បញ្ញើជាដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា**

(ឆមាសទី១ ឆ្នាំ២០២០ - ឆមាសទី១ ឆ្នាំ២០២៥)[៣១]




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

[២៩] បានបើកសរុប ១៨៦ គណនី និងបិទសរុប ១២២ គណនី។
[៣០] ចំនួនគណនី មានរួមបញ្ចូលទាំងស្នាក់ការកណ្តាល និងតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជា។
[៣១] ប្រាក់បញ្ញើ មានរួមបញ្ចូលទាំងស្នាក់ការកណ្តាល និងតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជា។

ការផ្ទេរប្រាក់សរុបមានចំនួន ៣២៧,៧ ទ្រីលានរៀល ក្នុងនោះការផ្ទេរប្រាក់ក្រៅប្រទេសមានចំនួន ៤,៦ ប៊ីលានដុល្លារអាមេរិក (ប្រមាណ ១៨,៤ ទ្រីលានរៀល) និងការផ្ទេរប្រាក់ក្នុងប្រទេសមានចំនួន ៣០៩,៣ ទ្រីលានរៀល។ ការផ្ទេរប្រាក់ចេញក្រៅប្រទេសមានចំនួន ៤,៤ ប៊ីលានដុល្លារអាមេរិក (ប្រមាណ ១៧,៧ ទ្រីលានរៀល) និងការផ្ទេរប្រាក់ចូលមានចំនួន ០,២ ប៊ីលានដុល្លារអាមេរិក (ប្រមាណ ០,៧ ទ្រីលានរៀល)។ ចំពោះការផ្ទេរក្នុងប្រទេសជារៀលមានចំនួន ៨៧,៦ ទ្រីលានរៀល និងការផ្ទេរប្រាក់ជាដុល្លារអាមេរិកមានចំនួន ៥៥,៤ ប៊ីលានដុល្លារអាមេរិក (ប្រមាណ ២២១,៧ ទ្រីលានរៀល។

**ក្រាហ្វ ៧៦៖ ការផ្ទេរប្រាក់ក្នុងនិងក្រៅប្រទេស**
(ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- សេវាគ្រប់គ្រងមូលបត្រ

### - តួនាទីជាអាណត្តិគាហកសម្រាប់ការបោះផ្សាយមូលបត្ររដ្ឋ

ធនាគារជាតិនៃកម្ពុជា បានសម្របសម្រួលដល់ការបោះផ្សាយមូលបត្ររដ្ឋសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលក្នុងឆមាសនេះ មូលបត្ររដ្ឋត្រូវបានដាក់ឱ្យដេញថ្លៃចំនួន ៦ លើក ក្នុងទំហំទឹកប្រាក់បោះផ្សាយសរុបចំនួន ១៦០ ប៊ីលានរៀល។ ការបោះផ្សាយបានថយ -៣៧% ធៀបនឹងឆមាសទី១ ឆ្នាំ២០២៤ និងសម្រេចបានប្រមាណ ៣២% នៃផែនការប្រចាំឆ្នាំ២០២៥ (៥០០ ប៊ីលានរៀល)។ ទន្ទឹមនេះ ការទូទាត់គូប៉ុងសរុបមានចំនួន ២០ លើក ស្មើនឹង ៩,៨ ប៊ីលានរៀល និងការទូទាត់ប្រាក់ដើមមានចំនួន ៤ លើក ស្មើនឹង ១០៨ ប៊ីលានរៀល។

**ក្រាហ្វ ៧៧៖ មូលបត្ររដ្ឋ**
(គិតជាប៊ីលានរៀល, ឆមាសទី២ ឆ្នាំ២០២២-ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

| តារាង ១៖ ការបោះផ្សាយមូលបត្ររដ្ឋតាមរយៈការដេញថ្លៃ | | | | | |
|---|---|---|---|---|---|
| លើកទី | កាលបរិច្ឆេទ | ទំហំប្រាក់សរុប (ប៊ីលានរៀល) | ឥណប្រតិទាន | អត្រាគូប៉ុង | អត្រាចំណូលដេញថ្លៃឈ្នះ |
| ៣០ | ២២-មករា-២៥ | ២៤ | ១ឆ្នាំ | ២,៨០% | ៣% - ៣,២៥% |
| ៣១ | ១៩-កុម្ភៈ-២៥ | - | ២ឆ្នាំ | ៣,២០% | - |
| ៣២ | ១៩-មីនា-២៥ | ៩០ | ៣ឆ្នាំ | ៣,៥០% | ៤,២០% - ៤,៣០% |
| ៣៣ | ២៣-មេសា-២៥ | ៣៤ | ១ឆ្នាំ | ២,៧០% | ៣% - ៣,២៥% |
| ៣៤ | ២១-ឧសភា-២៥ | - | ២ឆ្នាំ | ៣,២០% | - |
| ៣៥ | ២៥-មិថុនា-២៥ | ១២ | ៣ឆ្នាំ | ៣,៥០% | ៣,៥០% |

មូលបត្ររដ្ឋឥណប្រតិទាន ១ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ២,៧៥% និងអត្រាចំណូលដេញថ្លៃឈ្នះជាមធ្យម ៣,១៥% ហើយមូលបត្ររដ្ឋឥណប្រតិទាន ២ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ៣,២០% ស្របពេលដែលមូលបត្ររដ្ឋឥណប្រតិទាន ៣ឆ្នាំ មានអត្រាគូប៉ុងជាមធ្យម ៣,៥០% និងអត្រាចំណូលដេញថ្លៃឈ្នះជាមធ្យម ៤,០៦%។ បច្ចុប្បន្ន វិនិយោគិនស្ថាប័ន និងវិនិយោគិនបុគ្គលអាចវិនិយោគលើមូលបត្ររដ្ឋបាន តាមរយៈអន្តរការីមូលបត្ររដ្ឋ ដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា និងធនាគារជាតិនៃកម្ពុជា។

**ក្រាហ្វ ៧៨៖ អត្រាគូប៉ុងជាមធ្យម**

(គិតជាភាគរយ, ឆមាសទី២ ឆ្នាំ២០២២ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧៩៖ អត្រាចំណូលដេញថ្លៃឈ្នះជាមធ្យម**

(គិតជាភាគរយ, ឆមាសទី២ ឆ្នាំ២០២២ - ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា បានសម្របសម្រួលដល់ការស្នើសុំធ្វើជាអន្តរការីមូលបត្ររដ្ឋរបស់គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ដោយបានផ្តល់ការអនុញ្ញាតជាគោលការណ៍ដល់ក្រុមហ៊ុនមូលបត្រចំនួន ២ និងការអនុញ្ញាតជាផ្លូវការដល់ក្រុមហ៊ុនមូលបត្រចំនួន ១ ក្នុងការតភ្ជាប់ថ្នាលធនាគារជាតិនៃកម្ពុជា (NBCP) សម្រាប់ធ្វើប្រតិបត្តិការមូលបត្ររដ្ឋ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា

បានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារចំនួន ៥ ធ្វើជាគ្រឹះស្ថានទូទាត់សាច់ប្រាក់សម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារដែលធ្វើប្រតិបត្តិការមូលបត្ររដ្ឋក្នុងថ្នាល NBCP។ លើសពីនេះ ក្រុមការងារមូលបត្ររដ្ឋធនាគារជាតិនៃកម្ពុជាក៏បានបន្តចូលរួមពិភាក្សា និងផ្តល់យោបល់លើការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋដោយបានជួបជាមួយអន្តរការីមូលបត្ររដ្ឋចំនួន ១ ដើម្បីស្វែងយល់ពីបញ្ហាប្រឈម និងការលើកឡើងនូវសំណូមពររបស់វិនិយោគិនសក្តានុពល។

- **ការគ្រប់គ្រងប័ណ្ណសងតាមបញ្ជា** ប័ណ្ណសងតាមបញ្ជាដែលរាជរដ្ឋាភិបាល បានចេញផ្សាយជូនធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកត្រូវបានរក្សាទុកក្នុងគណនីបញ្ញើប័ណ្ណសងតាមបញ្ជា (Custodian Account) នៅធនាគារជាតិនៃកម្ពុជា។ ការគ្រប់គ្រងប័ណ្ណសងតាមបញ្ជា រួមមានការតាមដានព័ត៌មានគណនី និងសម្របសម្រួលការទូទាត់តាមការស្នើសុំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក។ ក្នុងឆមាសនេះ ពុំមានការទូទាត់លើប័ណ្ណសងតាមបញ្ជានោះទេ។

## ៥- ការគ្រប់គ្រងចរាចរណ៍ធនបត្រ

ដើម្បីបំពេញតម្រូវការរបស់សេដ្ឋកិច្ច សាធារណជន និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍ និងផ្គត់ផ្គង់ធនបត្រថ្មីគ្រប់ប្រភេទទៅក្នុងទីផ្សារ និងប្រមូលក្រដាសប្រាក់ចាស់ ទក់ រហែកជាប្រចាំ។

ក្នុងឆមាសទី១ ឆ្នាំ២០២៥ ការទទួលប្រាក់រៀល និងការបើកប្រាក់រៀលមាន ៩,៨ ទ្រីលានរៀល (ថយ -១%) និង ១០,៨ ទ្រីលានរៀល (កើន ១១,៨%) រៀងគ្នា។ ចំណែកឯការទទួល និងការបើកប្រាក់ដុល្លារអាមេរិកមាន ៨,៧ ប៊ីលានដុល្លារអាមេរិក (កើន ៣%) និង ៤ ប៊ីលានដុល្លារអាមេរិក (កើន ២១,២%) រៀងគ្នា។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំយុទ្ធនាការប្តូរប្រាក់ចាស់ ទក់ រហែក នៅទូទាំងប្រទេស ដែលបានផ្ទេរប្រាក់ចូលគណនីបាគងរបស់ប្រជាពលរដ្ឋចំនួន ៤.១៥១ ប្រតិបត្តិការ ដែលស្មើនឹង ៣,៤ ប៊ីលានរៀល និងប្តូរក្រដាសប្រាក់ថ្មីជូនប្រជាពលរដ្ឋចំនួន ៦,៩ ប៊ីលានរៀល។

**ក្រាហ្វ ៨០៖ ការទទួលនិងការបើកប្រាក់រៀល**
(គិតជាប៊ីលានរៀល, ឆមាសទី១ ឆ្នាំ២០២៣-ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨១៖ ការទទួលនិងការបើកប្រាក់ដុល្លារអាមេរិក**
(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០២៣-ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ការផ្គត់ផ្គង់ប្រាក់រៀលទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តបានកើនឡើង ២៨,៣% រីឯការដឹកជញ្ជូនប្រាក់រៀលចាស់ ទក់ រហែក និងសាច់ប្រាក់លើសពីតម្រូវការមកស្នាក់ការកណ្តាលវិញបានថយចុះ -៨,២%។ ការផ្គត់ផ្គង់ប្រាក់ដុល្លារអាមេរិកទៅឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និងការដឹកជញ្ជូនប្រាក់ដុល្លារអាមេរិកមកស្នាក់ការកណ្តាលវិញបានកើនឡើង ២៨,៨% និង ១៥,៨% រៀងគ្នា។

**ក្រាហ្វ ៨២៖ ប្រាក់រៀលដឹកទៅ-មក សាខាធនាគារជាតិនៃកម្ពុជា**

(គិតជាប៊ីលានរៀល, ឆមាសទី១ ឆ្នាំ២០២៣-ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៨៣៖ ប្រាក់ដុល្លារអាមេរិកដឹកទៅ-មក សាខាធនាគារជាតិនៃកម្ពុជា**

(គិតជាលានដុល្លារអាមេរិក, ឆមាសទី១ ឆ្នាំ២០២៣-ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ជារួម សេវាធនាគារកណ្តាលត្រូវបានបន្តពង្រឹងប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រដល់អន្តរការិយកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការគ្រប់គ្រងសាច់ប្រាក់របស់រាជរដ្ឋាភិបាល ព្រមទាំងបានសម្រួលដល់ការទូទាត់ទំនិញនិងសេវា។ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានបន្តធ្វើទំនើបកម្មជាលំដាប់ និងពង្រីកវិសាលភាពនៃការតភ្ជាប់ទាំងក្នុងតំបន់និងអន្តរជាតិ។ ចំណែកចរាចរណ៍សាច់ប្រាក់ក៏ត្រូវបានគ្រប់គ្រងដោយយកចិត្តទុកដាក់ ដើម្បីគាំទ្រដល់ការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច។ ទន្ទឹមនេះ អាជីវកម្មប្តូរប្រាក់ និងការនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ បន្តមានវឌ្ឍនភាពយ៉ាងប្រសើរ។

## V- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ស.ហ.ក. បានបន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ប្រកបដោយការទទួលខុសត្រូវ តាមរយៈការអនុវត្តការងារស្នូល ដូចជា ការងារវិភាគប្រតិបត្តិការ ការត្រួតពិនិត្យបុគ្គលរាយការណ៍ កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ និងការពង្រឹងសមត្ថភាពនិងលើកកម្ពស់ការយល់ដឹងដល់ភាគីពាក់ព័ន្ធ។

ក្រុមប្រឹក្សាភិបាលនៃ ស.ហ.ក. បានបើកកិច្ចប្រជុំចំនួន ២ លើក ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ណែនាំដល់ ស.ហ.ក. អំពីវឌ្ឍនភាពការងារ និងការត្រៀមលក្ខណៈរបស់កម្ពុជាសម្រាប់ការវាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០២៨-២០២៩។

ចំពោះការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មលើកទី២ គឺស្ថិតក្នុងដំណាក់កាលទី៣ ដែលជាការប្រមូលសរុបរបាយការណ៍ និងការរៀបចំរបាយការណ៍សង្ខេប។



កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
លើកទី៥៩ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥
នៅអគារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា



កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
លើកទី៦០ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥
នៅអគារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

### ១- ការងារត្រួតពិនិត្យបុគ្គលរាយការណ៍

ស.ហ.ក. បន្តពង្រឹងការត្រួតពិនិត្យបុគ្គលរាយការណ៍អំពីការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ។ នៅក្នុងឆមាសទី១ ឆ្នាំ២០២៥ ស.ហ.ក. បានត្រួតពិនិត្យដល់ទីកន្លែងចំពោះបុគ្គលរាយការណ៍សរុបចំនួន ២៤ ដោយបានរកឃើញចំណុចខ្វះខាតមួយចំនួន និងបានផ្តល់អនុសាសន៍កែតម្រូវ។

ស.ហ.ក. ក៏បានតាមដានជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ការអនុវត្តតាមអនុសាសន៍ត្រួតពិនិត្យដល់ទីកន្លែង លទ្ធផលនៃការត្រួតពិនិត្យផ្ទៃក្នុង និងសវនកម្មផ្ទៃក្នុងស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ទន្ទឹមនេះ ស.ហ.ក. បានបន្តវាយតម្លៃគុណវុឌ្ឍិរបស់មន្ត្រីប្រតិបត្តិ ដោយបានទទួលស្គាល់មន្ត្រីប្រតិបត្តិចំនួន ៧៧ រូប មកពីធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនអចលនវត្ថុ ក្រុមហ៊ុនបរធនបាលកិច្ច និងកាស៊ីណូ។

ជាមួយគ្នាផងដែរ ក្រោមជំនួយបច្ចេកទេសពីធនាគារពិភពលោក ស.ហ.ក. បាននិងកំពុងអភិវឌ្ឍឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់វិស័យអចលនវត្ថុ កាស៊ីណូ និងមេធាវី។ ឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យនេះនឹងជួយ ស.ហ.ក. អាចកំណត់កម្រិតហានិភ័យរបស់បុគ្គលរាយការណ៍ រៀបចំផែនការត្រួតពិនិត្យដល់ទីកន្លែង និងកំណត់ទិសដៅក្នុងការអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឱ្យបានកាន់តែប្រសើរនិងមានប្រសិទ្ធភាព។

## ២- ការងារវិភាគប្រតិបត្តិការ

ស.ហ.ក. បានបន្តតាមដានជាប្រចាំនូវការអនុវត្តកាតព្វកិច្ចរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យពីបុគ្គលរាយការណ៍ ដោយប្រតិបត្តិការទាំងនេះបានកើនឡើង ១៣,១% និង ២១,៨% រៀងគ្នា[៣២]។ ស.ហ.ក. បានបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុទៅអាជ្ញាធរអនុវត្តច្បាប់ដូចជា អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ព្រមទាំងទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសជាដៃគូ។

ទន្ទឹមនេះ ស.ហ.ក. បានភ្ជាប់ប្រព័ន្ធរាយការណ៍ដល់បុគ្គលរាយការណ៍ចំនួន ៣៧ ព្រមទាំងបានណែនាំគ្រឹះស្ថានទាំងនោះ ឱ្យយកចិត្តទុកដាក់អនុវត្តកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពិសេសការរាយការណ៍ប្រតិបត្តិការឱ្យបានទាន់ពេលវេលា និងមានគុណភាពខ្ពស់។

## ៣- កិច្ចសហប្រតិបត្តិការ

### ក. កិច្ចសហប្រតិបត្តិការក្នុងស្រុក

ស.ហ.ក. បាននិងកំពុងពិភាក្សាជាមួយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) អំពីកិច្ចសហប្រតិបត្តិការនៃការអនុវត្តការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងពិភាក្សាពីលទ្ធភាពនៃការចុះអនុស្សរណៈយោគយល់រួមគ្នាស្តីពីការផ្លាស់ប្តូរព័ត៌មាន។ ជាមួយគ្នានេះ ស.ហ.ក. ក៏បាននិងកំពុងពិភាក្សាជាមួយអគ្គលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា (អ.គ.ល.ក.) អំពីការងាររៀបចំអនុស្សរណៈយោគយល់ ផងដែរ។

### ខ. កិច្ចសហប្រតិបត្តិការអន្តរជាតិ

**- ក្រុមការងារហិរញ្ញវត្ថុ (FATF) និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG)**

ស.ហ.ក. បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរៀបចំរបាយការណ៍វឌ្ឍនភាពលើកទី៧ ស្តីពីការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ប្រទេសកម្ពុជាជូនលេខាធិការដ្ឋាន APG ពាក់ព័ន្ធនឹងការអនុវត្តតាមអនុសាសន៍របស់ FATF ព្រមទាំងផ្តល់ធាតុចូលលើស្ថានភាពហានិភ័យ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។



**កិច្ចប្រជុំគណៈកម្មការវាយតម្លៃអញ្ញមញ្ញ (Mutual Evaluation Committee – MEC) របស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ នាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥ តាមប្រព័ន្ធអនឡាញ**

លើសពីនេះ ដើម្បីទទួលបានបទពិសោធ និងឧត្តមានុវត្តន៍ល្អៗ ស.ហ.ក. បានចូលរួមជាមួយក្រុមការងារនានា និងផ្តល់ធាតុចូល

---

[៣២] ជាទិន្នន័យព្យាករណ៍ ដោយគណនាមធ្យមភាគនៃរបាយការណ៍ CTR និង STR ក្នុងរយៈពេល ៥ខែ ដើមឆ្នាំ២០២៥ និងយកទិន្នន័យមធ្យមភាគនោះធ្វើជាទិន្នន័យ ខែមិថុនា។

ដល់ក្រុមលេខាធិការដ្ឋាន APG និង FATF ដែលរួមមាន៖ i/-កិច្ចប្រជុំគណៈកម្មការវាយតម្លៃអញ្ញមញ្ញ ii/-កិច្ចប្រជុំគណៈកម្មការប្រតិបត្តិការ iii/-ប្រទេសមានហានិភ័យខ្ពស់ដែលតម្រូវឱ្យមានវិធានការប្រឆាំង និងប្រទេសដែលត្រូវបង្កើនការតាមដាន iv/-កិច្ចប្រជុំរបស់ក្រុមការងារត្រួតពិនិត្យរួមស្តីពីក្រុមការងារត្រួតពិនិត្យអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ v/-កិច្ចប្រជុំស្តីពី ការចូលរួមរបស់ស្ត្រីនៅក្នុងក្រុមការងារហិរញ្ញវត្ថុ និងបណ្តាញភាពជាអ្នកដឹកនាំជាសកល និង vi/-កិច្ចប្រជុំពាក់ព័ន្ធផ្សេងៗ។

**- ក្រុមអ៊ិកម៉ុង (The Egmont Group)**

តាមរយៈតួនាទីជាសមាជិកក្រុមអ៊ិកម៉ុង ស.ហ.ក. បានចូលរួមកិច្ចប្រជុំក្រុមការងាររបស់ក្រុមអ៊ិកម៉ុង ដើម្បីពិភាក្សាអំពីវឌ្ឍនភាពនៃគម្រោងពាក់ព័ន្ធនឹងក្រុមការងារទាំង៤ របស់ក្រុមអ៊ិកម៉ុង ដែលរួមមាន៖ i/-ក្រុមការងារផ្លាស់ប្តូរព័ត៌មាន ii/-ក្រុមការងារជំនួយបច្ចេកទេសនិងបណ្តុះបណ្តាល iii/-ក្រុមការងារសមាជិកភាព ការគាំទ្រ និងអនុលោមភាព និង iv/-ក្រុមការងារគោលនយោបាយ និងនីតិវិធី ព្រមទាំងក្រុមប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក។

ស.ហ.ក. បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញចំនួន ២ លើក ដែលរួមមាន៖ i/-ការប្រមូលធាតុចូលពាក់ព័ន្ធនឹងការអភិវឌ្ឍវគ្គបណ្តុះបណ្តាលស្តីពី កម្មវិធីសិក្សា Egmont Certificate of FIU Excellence and Leadership (ECOFEL) និង ECOFEL Certificate Program (ECP) និង ii/-កិច្ចប្រជុំរបស់ក្រុមការងារសមាជិកភាព ការគាំទ្រ និងអនុលោមភាព។ ជាមួយគ្នានេះ ស.ហ.ក. បានសិក្សា និងផ្តល់ធាតុចូល ដើម្បីឆ្លើយតបលើកម្រងសំណួរស្តីពី បច្ចេកវិទ្យាថ្មីៗ និងវឌ្ឍនភាពការងារផ្សេងៗរបស់ក្រុមអ៊ិកម៉ុង ដូចជា៖ i/-ប្រព័ន្ធ Egmont Secure Web (ESW) និង ii/-កម្មវិធី TrackAML Hackathon ២.០ ប្រចាំឆ្នាំ២០២៥ ជាដើម។

**- ក្រុមប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ (Financial Intelligence Consultative Group – FICG)**

ស.ហ.ក. បានចូលរួមកិច្ចប្រជុំរបស់ FICG ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មថ្នាក់តំបន់ សម្រាប់រាយការណ៍ក្នុងមហាសន្និបាតរបស់ FICG។ ជាមួយគ្នានេះ ស.ហ.ក. បានចូលជាសមាជិកប្រើប្រាស់ថ្នាលផ្លាស់ប្តូរព័ត៌មាន CLEO (CLEO Platform) ដែលជាថ្នាលមួយត្រូវបានប្រើប្រាស់ក្នុងគោលបំណងសំខាន់ៗរួមមាន៖ i/-ការពង្រឹងការទំនាក់ទំនងរវាងសមាជិក FICG ii/-ការផ្លាស់ប្តូរ ព័ត៌មាន និង iii/- ការចែករំលែកឯកសារសម្រាប់វគ្គបណ្តុះបណ្តាលរវាងសមាជិក FICG។ ក្រៅពីនេះ ស.ហ.ក. បានចូលរួមកិច្ចប្រជុំជាមួយក្រុមការងារផ្លាស់ប្តូរព័ត៌មាន (CPWG) អំពីការរក្សាសុវត្ថិភាពទិន្នន័យ និងបានផ្តល់ធាតុចូលក្នុងគម្រោងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (Child Sexual Exploitation – CSE) ដើម្បីបង្កើនការយល់ដឹងអំពីនិន្នាការ វិធីសាស្ត្រទប់ស្កាត់សកម្មភាពកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងបង្កើនសមត្ថភាពរបស់ស្ថាប័នហិរញ្ញវត្ថុក្នុងការកំណត់សញ្ញាព្រមាន (Red Flag) និងកំណត់អត្តសញ្ញាណប្រតិបត្តិការសង្ស័យ។

ទន្ទឹមនេះ ស.ហ.ក. ក៏បានជួបប្រជុំជាមួយតំណាងមជ្ឈមណ្ឌលវិភាគនិងរាយការណ៍ប្រតិបត្តិការអូស្ត្រាលី (Australian Transaction Reports and Analysis Center – AUSTRAC) ក្នុងគោលបំណងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ និងទិសដៅការងារ ផងដែរ។

## ៤. ការពង្រឹងសមត្ថភាព

ស.ហ.ក. បានបន្តយកចិត្តទុកដាក់ពង្រឹងសមត្ថភាពមន្ត្រីជាប្រចាំ។ ក្នុងន័យនេះ ស.ហ.ក. បានចូលរួមវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស ដែលរៀបចំដោយស្ថាប័នជាតិនិងអន្តរជាតិ តាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់លើប្រធានបទសំខាន់ៗ ដូចជា៖ i/- ការចូលរួមរបស់ស្ត្រីនៅក្នុងក្រុមការងារហិរញ្ញវត្ថុ និងបណ្តាញភាពជាអ្នកដឹកនាំជាសកល ii/-ការវិភាគជាយុទ្ធសាស្ត្រ iii/-ការត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់វិស័យអចលនវត្ថុ កាស៊ីណូ និងមេធាវី iv/-ការប្រមូលត្រលប់មកវិញនូវផលនៃបទល្មើស v/-វិធីសាស្ត្រនៃការវាយតម្លៃអញ្ញមញ្ញ vi/-បច្ចេកវិទ្យាហិរញ្ញវត្ថុ និងរូបិយប័ណ្ណឌីជីថល vii/-ហានិភ័យហិរញ្ញប្បទានភេរវកម្មពាក់ព័ន្ធទ្រព្យសកម្មនិម្មិត បច្ចេកវិទ្យាទូទាត់ថ្មីៗ និងបច្ចេកវិទ្យាហិរញ្ញវត្ថុ viii/-ការវិភាគ ការស៊ើបអង្កេត និងការចោទប្រកាន់បទសម្អាតប្រាក់ ix/-ការត្រៀមខ្លួនសម្រាប់ការវាយតម្លៃអញ្ញមញ្ញ និង x/-ស្តង់ដា FATF ពាក់ព័ន្ធនឹងអត្ថគាហកចុងក្រោយ។



វគ្គបណ្តុះបណ្តាលផ្ទៃក្នុងសម្រាប់មន្ត្រី ស.ហ.ក. ស្តីពី វិធីសាស្ត្រវាយតម្លៃរបស់ក្រុមការងារហិរញ្ញវត្ថុ និងច្បាប់និងបទប្បញ្ញត្តិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ចាប់ពីថ្ងៃទី១-៤ ខែមេសា ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

ស.ហ.ក. បានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល អំពីច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងវិធីសាស្ត្រវាយតម្លៃអនុសាសន៍និងលទ្ធផលជាក់ស្តែងរបស់ FATF ចំនួន ៣ លើក ជូនមន្ត្រី ស.ហ.ក. និងមន្ត្រីធនាគារជាតិនៃកម្ពុជា។ ជាមួយគ្នានេះ ស.ហ.ក. បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ អំពីច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងអនុលោមភាព ជូនគណៈគ្រប់គ្រងរបស់បុគ្គលរាយការណ៍ស្ថិតក្រោមធនាគារជាតិនៃកម្ពុជាចំនួន ១ លើក។ បន្ថែមពីនេះ ស.ហ.ក. បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលា ដែលសហការរៀបចំដោយអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករសន្តិសុខសង្គម និយ័តករធានារ៉ាប់រងកម្ពុជា និយ័តករបរធនបាលកិច្ច គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ និងក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ សរុបចំនួន ៨ លើក។

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានបន្តបំពេញមុខងារ-ភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ក្នុងការពង្រឹងសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា។ ស.ហ.ក. បានបន្តទទួលរបាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងរបាយការណ៍ប្រតិបត្តិការសង្ស័យពីបុគ្គលរាយការណ៍ ដោយមានការកើនឡើង ១៣,១% និង ២១,៨% រៀងគ្នា និងបានភ្ជាប់ប្រព័ន្ធរាយការណ៍ដល់បុគ្គលរាយការណ៍ចំនួន ៣៧។ ស.ហ.ក. បានចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះបុគ្គលរាយការណ៍ចំនួន ២៤ ផ្តល់អនុសាសន៍កែតម្រូវចំណុចខ្វះខាត និងទទួលស្គាល់មន្ត្រីប្រតិបត្តិចំនួន ៧៧ រូប ព្រមទាំងពង្រឹងការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាលើកកម្ពស់ការយល់ដឹង ជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ និងបុគ្គលរាយការណ៍ អំពីច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញ-ប្បទានភេរវកម្ម និងស្តង់ដាអន្តរជាតិផងដែរ។ ទន្ទឹមនេះ ស.ហ.ក. បានពង្រឹងកិច្ចសហប្រតិបត្តិការក្នុងប្រទេស និងក្រៅប្រទេស ព្រមទាំងបានចូលរួមប្រជុំ និងផ្តល់ធាតុចូលជូនក្រុមលេខាធិការដ្ឋាន APG និង FATF ក្រុម Egmont និង FICG។ ស.ហ.ក. បានបន្តការសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំការវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២។**

## VI- កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ១- កិច្ចសហប្រតិបត្តិការពហុភាគី

#### ក- កិច្ចសហប្រតិបត្តិការអាស៊ាន

ក្នុងនាមប្រធានប្តូរវេន ម៉ាឡេស៊ីបានកំណត់យក "បរិយាបន្ននិងចីរភាព" ជាមូលបទអាស៊ាន ឆ្នាំ២០២៥ ដោយបានដាក់ចេញយុទ្ធសាស្ត្រអាទិភាពចំនួន ៤ ដែលរួមមាន៖ i/-បង្កើនការវិនិយោគ និងពាណិជ្ជកម្ម ii/-ធ្វើសមាហរណកម្មនិងតភ្ជាប់សេដ្ឋកិច្ច iii/-ជំរុញឱ្យមានអនាគតប្រកបដោយបរិយាបន្ននិងចីរភាព និង iv/-ធ្វើការផ្លាស់ប្តូរសម្រាប់អនាគតឌីជីថល។ ជាមួយនឹងយុទ្ធសាស្ត្រអាទិភាពទាំងនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយធនាគារកណ្តាលអាស៊ានដទៃទៀត ដើម្បីអនុវត្តសមិទ្ធផលអាទិភាពសេដ្ឋកិច្ច (PED) ចំនួន ៣ ដែលស្ថិតក្រោមដែនសមត្ថកិច្ចធនាគារកណ្តាល ដូចជា៖ i/-ការពន្លឿនកំណើនទីផ្សារមូលធនអាស៊ានប្រកបដោយចីរភាព ការតភ្ជាប់ និងបរិយាបន្ន ii/-ការជំរុញការតភ្ជាប់ប្រព័ន្ធទូទាត់ទាំងក្នុង និងក្រៅតំបន់ឱ្យបានទូលំទូលាយ និងបង្កើនការលើកកម្ពស់សមាហរណកម្មក្នុងតំបន់ ដែលនឹងជួយពង្រឹងភាពធន់នៃសេដ្ឋកិច្ចអាស៊ាន និង iii/-ការជំរុញលទ្ធភាពទទួលបានហិរញ្ញប្បទានបៃតងសម្រាប់ការសម្របនឹងការប្រែប្រួលអាកាសធាតុ ដែលបច្ចុប្បន្នកម្ពុជាកំពុងរៀបចំផែនទីមគ្គុទេសក៍វដ្តករសាស្ត្រស្តីពី ហិរញ្ញប្បទានប្រកបដោយចីរភាព ស្របតាមឧត្តមានុវត្តន៍អន្តរជាតិនិងតំបន់។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏បានចូលជាសមាជិកទី៩ ក្នុងកិច្ចសហប្រតិបត្តិការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ក្នុងតំបន់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការទូទាត់ឆ្លងដែន និងជំរុញការធ្វើសមាហរណកម្មហិរញ្ញវត្ថុ។ ដើម្បីពង្រឹងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានគាំទ្រនិងចូលរួមដល់បង្កើតកិច្ចព្រមព្រៀងអាស៊ានស្វប់ (ASA) ឡើងវិញ ជាមួយនឹងការបង្កើនទំហំស្វប់ទ្វេដងដល់ ៤ ប៊ីលានដុល្លារអាមេរិក។ ASA នឹងក្លាយជាយន្តការផ្តល់និងទទួលហិរញ្ញប្បទានរយៈពេលខ្លីសម្រាប់តំបន់ ដែលមានភាពរហ័សនិងមានលក្ខខ័ណ្ឌតិចតួច។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏ត្រូវបានជ្រើសរើសជាតំណាងនៃគណៈកម្មាធិការជាន់ខ្ពស់អាស៊ានស្តីពី សមាហរណកម្មហិរញ្ញវត្ថុអាស៊ានប្រចាំនៅក្នុងក្រុមប្រឹក្សាវដ្តករសាស្ត្រអាស៊ាន ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការផ្តល់ហិរញ្ញប្បទានបៃតង និងជាវេទិកាសម្រាប់ជំរុញសកម្មភាពសេដ្ឋកិច្ចនិងការវិនិយោគដែលគិតគូរពីសង្គមនិងបរិស្ថាន។







កិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន (AFMGM) លើកទី១២
កិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ាន (ACGM) និងកិច្ចប្រជុំពាក់ព័ន្ធ
នាថ្ងៃទី៧-១០ ខែមេសា ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

## ខ- កិច្ចសហប្រតិបត្តិការអាស៊ាន+៣

ក្រោមកិច្ចសហប្រតិបត្តិការអាស៊ាន+៣ ដែលមានប្រទេសម៉ាឡេស៊ី និងចិនជាសហប្រធានប្តូរវេនឆ្នាំ២០២៥ ការតាមដានសេដ្ឋកិច្ចនិងបណ្តាញស្ថិរភាពហិរញ្ញវត្ថុតំបន់ត្រូវបានបន្តពង្រឹង ជាពិសេសស្ថិតក្នុងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក។ ក្នុងគោលដៅនេះ ប្រទេសជាសមាជិកអាស៊ាន+៣ បាន ៖ i/- បង្កើតក្រុមប្រឹក្សាជំនាញ ដើម្បីជួយរៀបចំទិសដៅយុទ្ធសាស្ត្រអាស៊ាន+៣ ii/- រៀបចំឧបករណ៍កែតម្រូវគោលនយោបាយសម្រាប់ការផ្តល់ហិរញ្ញប្បទានរយៈពេលវែង iii/- ធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រទំនាក់ទំនងរបស់អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) iv/- ពង្រីកបណ្តាញអ្នកជំនាញហិរញ្ញវត្ថុអាស៊ាន+៣ (AFTN) ដើម្បីចែករំលែកចំណេះដឹងបទពិសោធក្នុងតំបន់ v/- អភិវឌ្ឍទីផ្សារធានារ៉ាប់រងក្នុងស្រុក ក្រោមគំនិតផ្តួចផ្តើមហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយធម្មជាតិ vi/- ជំរុញការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុករបស់ប្រទេសក្នុងតំបន់ ក្រោមក្របខ័ណ្ឌឧបករណ៍ផ្តល់ហិរញ្ញប្បទានរហ័ស vii/- បន្តពិភាក្សាលើការដាក់ដើមទុនក្នុងយន្តការពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ដោយយកគំរូតាម IMF និង viii/- អនុម័តលើការសាកល្បង CMIM លើកទី១៦ ដោយផ្តោតលើឧបករណ៍ផ្តល់ហិរញ្ញប្បទានរហ័ស ដែលមិនភ្ជាប់នឹងឥណទានរបស់ IMF ជាដើម។



កិច្ចប្រជុំរួមថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលរងធនាគារកណ្តាលអាស៊ាន+៣ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៥ នៅទីក្រុងមីឡង់ ប្រទេសអ៊ីតាលី

## គ- កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ

កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាត្រូវបានបន្តពង្រឹងនិងពង្រីក ដើម្បីលើកកម្ពស់ចំណេះដឹងនិងបទពិសោធការងារធនាគារកណ្តាល ព្រមទាំងទទួលបានជំនួយបច្ចេកទេសនិងអនុសាសន៍គោលនយោបាយ សំដៅបន្តបង្កើនសមត្ថភាពស្ថាប័ននិងអភិវឌ្ឍប្រព័ន្ធធនាគារកម្ពុជា។ ជាក់ស្តែង IMF បានបន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ តាមដានស្ថានភាពសេដ្ឋកិច្ច និងផ្តល់ជំនួយបច្ចេកទេសសំខាន់ៗ រួមមាន ការត្រួតពិនិត្យធនាគារ ការពង្រឹងគុណភាពស្ថិតិ ការព្យាករសន្ទនីយភាពនិងសូចនាករម៉ាក្រូសេដ្ឋកិច្ចនានា។ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០ ដែលដឹកនាំដោយធនាគារជាតិនៃកម្ពុជា និងការចូលរួមអនុវត្តអនុកម្មវិធីទី១ នៃកម្មវិធីវិស័យហិរញ្ញវត្ថុប្រកបដោយចីរភាពនិងបរិយាបន្នត្រូវបានបញ្ចប់ជាស្ថាពរ។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំប្រចាំឆ្នាំលើកទី៥៨ របស់ ADB កាលពីថ្ងៃទី៤-៧ ខែឧសភា ឆ្នាំ២០២៥ នៅប្រទេសអ៊ីតាលី លោកជំទាវទេសាភិបាល ត្រូវបានអញ្ជើញឱ្យចូលរួមជាវាគ្មិនក្នុងវេទិកាតុមូលស្តីពី "ប្រព័ន្ធទូទាត់ឆ្លងដែន៖ ពីការដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ រហូតដល់ការប្រើប្រាស់ដោយរលូនរបស់អតិថិជន" ដោយមានការចូលរួមពី ប្រធាន ADB ប្រធានធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ទេសាភិបាលធនាគារកណ្តាលអ៊ីតាលី កូរ៉េ និងថ្នាក់ដឹកនាំក្នុងវិស័យហិរញ្ញវត្ថុសំខាន់ៗដទៃទៀត។ ចំពោះកិច្ចសហការជាមួយមជ្ឈមណ្ឌលស៊ាសិន (SEACEN) ធនាគារជាតិនៃកម្ពុជាបញ្ជូនមន្ត្រី-បុគ្គលិកចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងទទួលធ្វើជាម្ចាស់ផ្ទះរៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "ការគ្រប់គ្រងវិបត្តិការរៀបចំផែនការដោះស្រាយនិងស្តារឡើងវិញ"។ ម៉្យាងទៀត ធនាគារជាតិនៃកម្ពុជាក៏បានរក្សាទំនាក់ទំនងល្អប្រសើរជាមួយបណ្តាធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) ចំនួន ៤៩ ប្រទេស ហើយកំពុងសហការជាមួយនឹងធនាគារកណ្តាលបារាំងដើម្បីធ្វើជាម្ចាស់ផ្ទះ

រៀបចំសន្និសីទថ្នាក់ទេសាភិបាលធនាគារកណ្តាលប្រ្វង់កូហ្វូនលើកទី ២៨ ក្រោមប្រធានបទស្វ័យភាពរបស់ធនាគារកណ្តាលប្រឈមនឹងការរំពឹងទុករបស់រដ្ឋនិងសាធារណជន (L’autonomie des banques centrales face aux attentes des États et du public)។




លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនក្នុងវេទិកាតុមូលស្តីពី "ប្រព័ន្ធទូទាត់ឆ្លងដែន៖ ពីការដាក់ឱ្យប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ រហូតដល់ការប្រើប្រាស់ដោយរលូនរបស់អតិថិជន" នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥ នៅទីក្រុងមីឡង់ ប្រទេសអ៊ីតាលី






ឯកឧត្តម រ័ត្ន សុវណ្ណនរៈ ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំនិទាឃរដូវ ឆ្នាំ២០២៥ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (World Bank) ចាប់ពីថ្ងៃទី២១-២៦ ខែមេសា ឆ្នាំ២០២៥ នៅរដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិក





ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាអធិបតី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពី "ការគ្រប់គ្រងវិបត្តិ ការរៀបចំផែនការដោះស្រាយនិងស្តារឡើងវិញ" នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥ នៅសណ្ឋាគារ Hyatt Regency រាជធានីភ្នំពេញ

**ប្រអប់ ២៖ កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ**

➤**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)៖** ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តគម្រោងស្តីពី ការលើកកម្ពស់សមត្ថភាពក្នុងការស្រាវជ្រាវ វិភាគសេដ្ឋកិច្ច និងប្រតិបត្តិការនយោបាយរូបិយវត្ថុ។ ក្រោមគម្រោងនេះ JICA បានបញ្ជូនជំនាញការថ្មី ១រូបបន្ថែមទៀត ដើម្បីផ្តល់ជំនួយបច្ចេកទេសលើការពង្រឹងការព្យាករសន្ទនីយភាព និងប្រតិបត្តិការអន្តរធនាគារ។

➤**ធនាគារពិភពលោក** (WB)៖ តាមរយៈជំនួយបច្ចេកទេសរបស់ធនាគារពិភពលោក ការបណ្តុះបណ្តាលមន្ត្រីជំនាញលើការគាំទ្រស្ថិរភាពនិងបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ស្របពេលដែលជំនួយបច្ចេកទេសពាក់ព័ន្ធនឹងក្របខ័ណ្ឌគ្រប់គ្រងវិបត្តិត្រូវបាននិងកំពុងពិភាក្សា។

➤**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)៖** ធនាគារជាតិនៃកម្ពុជាសហការជាមួយ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានសិក្សាស្រាវជ្រាវលើប្រធានបទចំនួន ២៖ i/-ដុល្លារូបនីយកម្ម និងផលប៉ះពាល់លើវិស័យកាត់ដេរផលិតផលស្បែកជើង ផលិតផលធ្វើដំណើរ និងកាបូបនៅកម្ពុជា និង ii/-ការបង្កើនឱ្យដល់កម្រិតអតិបរមានៃលំហូរការផ្ទេរប្រាក់ពីប្រទេសថៃមកកម្ពុជា៖ ឧបសគ្គនិងអនុសាសន៍ដើម្បីជំរុញការផ្ទេរប្រាក់តាមរយៈប្រព័ន្ធឌីជីថល។ ម្យ៉ាងទៀត ក្រោមគំនិតផ្តួចផ្តើមរបស់ UNDP និងភាគីពាក់ព័ន្ធផ្សេងទៀត គម្រោង Universal Trusted Credentials (UTC) នឹងត្រូវបានដាក់ឱ្យអនុវត្តនៅកម្ពុជា ក្នុងគោលបំណងបង្កើតនូវប្រព័ន្ធទិន្នន័យមួយដែលមានភាពរឹងមាំ សំដៅជួយសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ដោះស្រាយបញ្ហាប្រឈមនានា ជាពិសេសការទទួលបានហិរញ្ញវត្ថុផ្លូវការពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលនឹងអាចលើកកម្ពស់សមត្ថភាពក្នុងការនាំចេញផលិតផលរបស់ MSMEs ទៅកាន់ប្រទេសជាដៃគូ។

➤ **សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)៖** ធនាគារជាតិនៃកម្ពុជា និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានសហការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "សេចក្តីព្រាងប្រព័ន្ធវគ្គករសាស្ត្រ (Taxonomy)" សម្រាប់ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា ដើម្បីប្រមូលធាតុចូលបន្ថែមសម្រាប់សេចក្តីព្រាងឯកសារដ៏មានសារៈសំខាន់នេះ សំដៅរួមចំណែកក្នុងការដោះស្រាយផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុនៅកម្ពុជា និងជួយពន្លឿនការផ្លាស់ប្តូរសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចបៃតង។ ជាមួយគ្នានេះ IFC បានបន្តគាំទ្រដល់ធនាគារជាតិនៃកម្ពុជាក្នុងការពង្រឹងកិច្ចការពារអតិថិជនក្នុងវិស័យហិរញ្ញវត្ថុ តាមរយៈការគាំទ្រការរៀបចំនិងដាក់ចេញនូវបទប្បញ្ញត្តិព្រមទាំងពង្រឹងការត្រួតពិនិត្យនានាពាក់ព័ន្ធនឹងកិច្ចការពារអតិថិជន ជាដើម។

## ២. កិច្ចសហប្រតិបត្តិការទ្វេភាគី

### ក- អាជ្ញាធររូបិយវត្ថុនៃព្រះរាជាណាចក្រប៊ូតង់



ទស្សនកិច្ចសិក្សារបស់មន្ត្រីជំនាញអាជ្ញាធររូបិយវត្ថុនៃព្រះរាជាណាចក្រប៊ូតង់ នាថ្ងៃទី១២-១៨ ខែមករា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ

ធនាគារជាតិនៃកម្ពុជាបានចែករំលែកចំណេះដឹងនិងបទពិសោធដល់មន្ត្រីជំនាញមកពីអាជ្ញាធររូបិយវត្ថុនៃព្រះរាជាណាចក្រប៊ូតង់ ដែលបានធ្វើទស្សនកិច្ចនៅធនាគារជាតិនៃកម្ពុជា ដើម្បីស្វែងយល់អំពីប្រធានបទមួយចំនួន ដូចជា៖ i/-លំហូរការងារសម្រាប់ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ដោយផ្តោតលើអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងយុទ្ធសាស្ត្របែងចែកទ្រព្យសកម្ម ii/-ប្រតិបត្តិការនិងឧត្តមានុវត្តន៍ក្នុងការ

ផ្ទេរប្រាក់ឆ្លងដែនប្រកបដោយប្រសិទ្ធភាព iii/-ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មប្តូរប្រាក់ iv/-ការទូទាត់ឆ្លងរូបិយប័ណ្ណ v/-ការទូទាត់ឆ្លងដែន និង vi/-ទីផ្សាររូបិយវត្ថុ។

### ខ- ធនាគារកណ្តាលឡាវ

មន្ត្រីជំនាញនៃធនាគារកណ្តាលឡាវបាន ធ្វើទស្សនកិច្ចសិក្សានៅកម្ពុជា ដើម្បីស្វែងយល់ លើប្រធានបទ៖ i/-នីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ ដល់ប្រភេទគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្សេងៗគ្នា និង ii/-យន្តការនៃការគ្រប់គ្រងអត្រាប្តូរប្រាក់ ការគ្រប់គ្រងបំណុល និងការគ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធទូទាត់របស់ធនាគារកណ្តាល។



ទស្សនកិច្ចសិក្សារបស់មន្ត្រីជំនាញនៃធនាគារកណ្តាលឡាវ
នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា

### គ- ធនាគារកណ្តាលម៉ាដាហ្គាស្កា

ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលម៉ាដាហ្គាស្កា បានចុះអនុស្សរណៈយោគយល់ ដើម្បីបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ពាក់ព័ន្ធនឹង i/-ការតភ្ជាប់ប្រព័ន្ធទូទាត់ និងនវានុវត្តន៍ ii/-នវានុវត្តន៍ហិរញ្ញវត្ថុឌីជីថល iii/-រូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាល iv/-សន្តិសុខសាយប័រ v/-អភិបាលកិច្ច និងហេដ្ឋារចនាសម្ព័ន្ធផ្នែកព័ត៌មានវិទ្យា vi/-ការការពារទិន្នន័យ vii/-ទុនបម្រុងអន្តរជាតិនិងមាស viii/-ការគ្រប់គ្រងរូបិយវត្ថុនិងប្រាក់បម្រុងកាតព្វកិច្ច ix/-បរិយាបន្នហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជន x/-ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ xi/-ការត្រួតពិនិត្យធនាគារ និង xii/-ការអភិវឌ្ឍធនធានមនុស្ស ជាដើម។




ធនាគារជាតិនៃកម្ពុជា និង ធនាគារកណ្តាលម៉ាដាហ្គាស្កា
បានចុះអនុស្សរណៈយោគយល់ នាថ្ងៃទី១៨ ខែកុម្ភៈ
ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ

### ឃ- ធនាគារកណ្តាលទីម័រឡេស្តេ

គណៈប្រតិភូធនាគារកណ្តាលទីម័រ-ឡេស្តេ បានមកធ្វើទស្សនកិច្ចនៅធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងសិក្សាអំពីបទពិសោធរបស់ធនាគារជាតិនៃកម្ពុជា លើការអភិវឌ្ឍប្រព័ន្ធទូទាត់អេឡិចត្រូនិក។



ទស្សនកិច្ចរបស់គណៈប្រតិភូធនាគារកណ្តាលទីម័រឡេស្តេ
ដឹកនាំដោយលោកជំទាវ ទេសាភិបាលរង Sara Lobo Brites
នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា

### ខ- អាជ្ញាធររូបិយវត្ថុហុងកុង



លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានជួបពិភាក្សាការងារ ជាមួយតំណាងអាជ្ញាធររូបិយវត្ថុហុងកុង នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥ នៅទីក្រុងហុងកុង

ធនាគារជាតិនៃកម្ពុជាបានជួបពិភាក្សាការងារជាមួយតំណាងអាជ្ញាធររូបិយវត្ថុហុងកុង ដោយផ្តោតលើ៖ i/-ការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់រាយ ii/-ការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់តម្លៃធំ និង iii/-កិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងការប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ។ ភាគីទាំងពីរក៏បានជំរុញ និងពិនិត្យលើលទ្ធភាពចុះអនុស្សរណៈយោគយល់ ក្នុងការផ្តល់នូវយន្តការសមស្រប ឱ្យភាគីទាំងពីរធ្វើការពិភាក្សាលើការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ និងការគ្រប់គ្រងទុនបម្រុងផងដែរ។

### ច- ធនាគារកណ្តាលបង់ក្លាដេស



ទស្សនកិច្ចសិក្សារបស់គណៈប្រតិភូធនាគារកណ្តាលបង់ក្លាដេស នាថ្ងៃទី៤-១០ ខែឧសភា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ

គណៈប្រតិភូធនាគារកណ្តាលបង់ក្លា-ដេស បានមកបំពេញទស្សនកិច្ចសិក្សា ដើម្បីពិភាក្សាលើប្រធានបទចំនួន ៥ ដែលរួមមាន៖ i/-តួនាទី-ភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជាក្នុងការអភិវឌ្ឍគោលនយោបាយនិងបទប្បញ្ញត្តិលើការផ្តល់ឥណទានដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ii/-យុទ្ធសាស្ត្រក្នុងការបង្កើនទំហំឥណទានសម្រាប់ MSMEs iii/-យុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ iv/-តួនាទីសេវាហិរញ្ញវត្ថុឌីជីថល ដោយរួមមានធនាគារចល័ត (Mobile Banking) និង v/-បច្ចេកវិទ្យាហិរញ្ញវត្ថុនិងប្រព័ន្ធបាគង។

សរុបមក ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែកក្នុងសមាហរណកម្មវិស័យធនាគារ និងហិរញ្ញវត្ថុទាំងក្នុងតំបន់និងពិភពលោក តាមរយៈការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ ទ្វេភាគីនិងពហុភាគីជាមួយធនាគារកណ្តាល អាជ្ញាធររូបិយវត្ថុ ស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា។ កិច្ចសហប្រតិបត្តិការល្អទាំងនេះបានលើកកិត្តិនាមរបស់ធនាគារជាតិនៃកម្ពុជាក៏ដូចជាប្រទេសកម្ពុជានៅលើឆាកអន្តរជាតិ អភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងទទួលបានជំនួយបច្ចេកទេស។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បានចែករំលែកចំណេះដឹងនិងបទពិសោធជាមួយនឹងប្រទេសនានាទាំងក្នុងតំបន់និងពិភពលោក ជាពិសេសលើភាពជោគជ័យក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់ ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ និងការត្រួតពិនិត្យជាដើម។

# VII-ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

## ១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល

**សមាសភាពក្រុមប្រឹក្សាភិបាល**



**លោកជំទាវ ជា សិរី**
អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
ជាប្រធាន



**ឯកឧត្តម ស៊ុំ សន្និសិទ្ធ**
ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា
ជាសមាជិក



**ឯកឧត្តម ហួត ពុំ**
តំណាងប្រមុខរាជរដ្ឋាភិបាល
ជាសមាជិក



**ឯកឧត្តម រស់ សីលវ៉ា**
តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ជាសមាជិក



**លោកស្រី អេង នេត្រា**
តំណាងមជ្ឈដ្ឋានឧត្តមសិក្សា
ជាសមាជិក



**លោក ឡាយ ម៉េងស៊ុន**
តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច
ជាសមាជិក



**លោក មុំ ដារ៉ែត**
តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា
ជាសមាជិក

នៅក្នុងឆមាសទី១ ឆ្នាំ២០២៥ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានជួបប្រជុំចំនួន ៣ លើក មានដូចតទៅ៖

- លើកទី១៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦៨ នាថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ដើម្បីពិនិត្យ និងអនុម័ត លើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជី គណនេយ្យធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២៤
- លើកទី២៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦៩ នាថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០២៤ និងផែនការឆ្នាំ២០២៥ និង
- លើកទី៣៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៧០ នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០២៥ ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាពការងារគ្រប់គ្រងទុនបម្រុងវិនិយោគ ឆ្នាំ២០២៤ និងវឌ្ឍនភាពនៃការគ្រប់គ្រងទុនបម្រុងវិនិយោគ។

## ២- ការអភិវឌ្ឍធនធានមនុស្ស

ការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា មានការអភិវឌ្ឍ និងរីកចម្រើនជាបន្តបន្ទាប់ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួនមន្ត្រី-បុគ្គលិកប្រកបដោយគុណវុឌ្ឍិ វចនាសម្ព័ន្ធការងាររឹងមាំ និងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ន ការគ្រប់គ្រងធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា បានផ្តោតទៅលើការជ្រើសរើសមន្ត្រីបុគ្គលិកដោយផ្អែកលើតម្រូវការជំនាញជាក់ស្តែង និងការដាក់ឱ្យបំពេញការងារទៅតាមកន្លែងដោយផ្អែកលើសមត្ថភាពដែលពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារកណ្តាល។

### ក- ស្ថិតិមន្ត្រី-បុគ្គលិក

មន្ត្រី-បុគ្គលិកក្នុងក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសមានចំនួន ២.០២៦រូប (ប្រុស ១.០៣៦រូប ស្រី ៩៩០រូប) ដែលក្នុងនោះទីស្នាក់ការកណ្តាលមានចំនួន ១.៥១៤រូប (ប្រុស ៨០៣រូប ស្រី ៧១១រូប) និងសាខារាជធានី-ខេត្ត មានចំនួន ៥១២រូប (ប្រុស ២៣៣រូប ស្រី ២៧៩រូប)។ នាឆមាសទី១ ក្របខ័ណ្ឌមន្ត្រី-បុគ្គលិកនៅទីស្នាក់ការកណ្តាលបានថយចុះចំនួន ២រូប (ចូលថ្មី ១៨រូប ចូលនិវត្តន៍ ១៧រូប លាឈប់ ២រូប មរណភាព ១រូប បញ្ឈប់ពីការងារ ១រូប និងផ្ទេរភារកិច្ចចូល ១រូប) ខណៈនៅសាខាថយចុះ ១០រូប (ចូលនិវត្តន៍ ៨រូប លាឈប់ ១រូបនិងផ្ទេរភារកិច្ចចេញ ១រូប)។

**ក្រាហ្វ ៨៤៖ ស្ថិតិមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា តាមកម្រិតវប្បធម៌**
(គិតត្រឹមឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ- ការងារបណ្តុះបណ្តាល

### i/- ការងារបណ្តុះបណ្តាលក្នុងប្រទេស

សមត្ថភាពមន្ត្រី-បុគ្គលិកត្រូវបានបន្តអភិវឌ្ឍជាប្រចាំ តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជាក្នុងនោះរួមមាន ការបណ្តុះបណ្តាលលើផ្នែកបទប្បញ្ញត្តិ ការត្រួតពិនិត្យធនាគារ ការរៀបចំនិងអនុវត្តនយោបាយរូបិយវត្ថុ ការអភិវឌ្ឍប្រព័ន្ធទូទាត់ ភាពជាអ្នកដឹកនាំ រដ្ឋបាល ពិធីការជាតិនិងអន្តរជាតិ និងជំនាញផ្សេងៗទៀតពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ធនាគារកណ្តាល ចំនួន ១៦លើក ដោយមានសិក្ខាកាមសរុបចំនួន ១.៨៧៧រូប។ ទន្ទឹមនេះ សមត្ថភាពភាសាបរទេស របស់មន្ត្រី-បុគ្គលិកត្រូវបានជំរុញបន្ថែម តាមរយៈការផ្តល់អាហារូបករណ៍សិក្សា ១០០% ដែលជាក់ស្តែង មានមន្ត្រី-បុគ្គលិក ២៦០រូប បានចុះឈ្មោះនិងបន្តការសិក្សាភាសាអង់គ្លេស បារាំង ចិន កូរ៉េ ជប៉ុន និងថៃ។ ក្រៅពីការចូលរួមវគ្គបណ្តុះបណ្តាលផ្ទាល់ដល់ទីកន្លែង វគ្គសិក្សាតាមប្រព័ន្ធអនឡាញ ក៏ត្រូវបានរៀបចំឡើងចំនួន ៦វគ្គគឺ៖

១/- វគ្គ NBC FSI Connect ជំនាញត្រួតពិនិត្យធនាគារ ក្រោមកម្មវិធីរបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុនៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មមុខវិជ្ជា សម្រាប់សិក្ខាកាមចំនួន ២៧៦រូប ហើយគ្រោងនឹងដំណើរការឡើងវិញនៅឆមាសទី២ ឆ្នាំ២០២៥

២/- វគ្គបណ្តុះបណ្តាល Coursera មាន ៥ជំនាញ មានសិក្ខាកាមសរុបចំនួន ២០០រូប ដែលក្នុងនោះសិក្ខាកាមចំនួន ១៥៦រូប បានបញ្ចប់គ្រប់មុខវិជ្ជា

៣/- វគ្គសិក្សាលើជំនាញការគ្រប់គ្រងហានិភ័យ (Certified Expert in Risk Management) មាន ១០មុខវិជ្ជា និងមានសិក្ខាកាមកំពុងសិក្សាចំនួន ២០រូប

៤/- វគ្គបណ្តុះបណ្តាលជំនាញធនាគារស្នូលរបស់វិទ្យាស្ថាន Chartered Banker មាន ៤មុខវិជ្ជា និងមានសិក្ខាកាមកំពុងសិក្សាចំនួន ២០រូប

៥/- កម្មវិធីសិក្សាកម្រិត Micro-Master របស់វិទ្យាស្ថាន MIT មានសិក្ខាកាមចំនួន ៥៣រូប (ជំនាន់ទី១ មាន ១១រូប និងជំនាន់ទី២ មាន ៤២រូប) កំពុងសិក្សាលើជំនាញទិន្នន័យ សេដ្ឋកិច្ច ការរៀបចំគោលនយោបាយ ហិរញ្ញវត្ថុ ព្រមទាំងស្ថិតិនិងវិទ្យាសាស្ត្រទិន្នន័យ និង

៦/- វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់តាមប្រព័ន្ធអនឡាញ ក៏មានមន្ត្រី-បុគ្គលិកចុះឈ្មោះ និងបំពេញលក្ខខណ្ឌចាំបាច់នានារបស់សាកលវិទ្យាល័យដើម្បីចូលសិក្សាជាបន្តបន្ទាប់ផងដែរ។



វគ្គបណ្តុះបណ្តាលស្តីពី ពិធីការជាតិនិងអន្តរជាតិ នាថ្ងៃទី២៧-២៨ ខែមីនា ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ



វគ្គបណ្តុះបណ្តាលស្តីពី ការកាត់តែងលិខិតរដ្ឋបាលនិងលិខិតបទដ្ឋានគតិយុត្ត នាថ្ងៃទី៨-៩ ខែមេសា ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

### ii/- ការងារបណ្តុះបណ្តាលក្រៅប្រទេស

មន្ត្រី-បុគ្គលិកត្រូវបានចាត់បញ្ជូនឱ្យចូលរួម៖ i/- វគ្គបណ្តុះបណ្តាលរយៈពេលខ្លី រួមមាន សិក្ខាសាលា វគ្គសិក្សា និងទស្សនកិច្ចសិក្សាផ្សេងៗ ចំនួន ៦៥លើក ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១៦២រូប និង ii/-វគ្គបណ្តុះបណ្តាលរយៈពេលវែងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានមន្ត្រី-បុគ្គលិកចំនួន ៣៧រូប កំពុងបន្តការសិក្សា។

### iii/-ការងារបណ្តុះបណ្តាលផ្នែកសុខុមាលភាព

បន្ថែមលើការបណ្តុះបណ្តាលជំនាញបច្ចេកទេស ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងបន្តយកចិត្តទុកដាក់និងគិតគូរអំពីសុខភាពផ្លូវចិត្តរបស់មន្ត្រីបុគ្គលិក តាមរយៈ ការរៀបចំកម្មវិធីបណ្តុះបណ្តាលសុខុមាលភាព (Well-being) ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងផ្នែកសុខភាព ជំនាញក្នុងការថែទាំសុខភាពខ្លួនឯងនិងជួយអ្នកដទៃ និងរបៀបនៃការរស់នៅប្រកបដោយសុខភាពល្អ ព្រមទាំងជួយជំរុញផលិតភាពការងារ។ វគ្គនេះរួមមានការពិគ្រោះយោបល់លើបញ្ហាផ្លូវចិត្ត ការគ្រប់គ្រងអារម្មណ៍ ការធ្វើសមាធិ និងវិធីសាស្ត្របង្កើនថាមពលចិត្ត។ ជាក់ស្តែង ក្នុងឆមាសទី១ ឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា បានរៀបចំ i/-កម្មវិធី Arts of living ៤លើក ដោយមានមន្ត្រី-បុគ្គលិកចូលរួមចំនួន ២៣១រូប ii/-វគ្គបណ្តុះបណ្តាលវិទ្យាសាស្ត្រនិង សុខមាលភាពផ្លូវចិត្ត ចំនួន ៥លើក មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៣០៧រូប iii/-វគ្គ Retreat ១លើក មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៨០រូប iv/- វគ្គបណ្តុះបណ្តាលដែលរៀបចំដោយមន្ទីរពេទ្យ Intercare មានវគ្គប្រឹក្សាសុខភាពចំនួន ៣លើក មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ២៤១រូប និងវគ្គសង្គ្រោះបឋម (First Aid) ចំនួន ២លើក មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ២២១រូប និងv/-ការចុះទស្សនកិច្ចនៅតាមបណ្តារមណីយដ្ឋានប្រវត្តិសាស្ត្រ វប្បធម៌ និងធម្មជាតិ និងសហគមន៍អេកូទេសចរណ៍ ចំនួន ២លើក មានមន្ត្រី-បុគ្គលិកចូលរួមចំនួន ៣៣២រូប។




**វគ្គបណ្តុះបណ្តាលស្តីពី "ការសង្គ្រោះបឋម" នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ**

## គ- វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារបាននិងកំពុងបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រគ្រប់គ្រងធនាគារជំនាន់ទី១ បន្ទាប់ពីទទួលបានអនុក្រឹត្យលេខ ២២៨.អនក្រ.បក ស្តីពី ការទទួលស្គាល់ការប្រែក្លាយមណ្ឌលសិក្សាបច្ចេកទេសធនាគារទៅជាវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ។ ទន្ទឹមនេះ វិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារបាននិងកំពុងរៀបចំអភិវឌ្ឍកម្មវិធីសិក្សាដែលមានលក្ខណៈអន្តរជាតិ ព្រមទាំងសិក្សាទៅលើការបញ្ចូលភាសាបរទេស ដូចជាភាសាបារាំង ចិន ជាដើម ជាពិសេសភាសាសញ្ញាដើម្បីគាំទ្រនិស្សិតពិការដែលមានចំណាប់អារម្មណ៍លើមុខជំនាញធនាគារនិងហិរញ្ញវត្ថុផងដែរ។

**ក្រាហ្វ ៨៥៖ ស្ថិតិសាស្ត្រាចារ្យ**
(ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បច្ចុប្បន្ន និស្សិតដែលកំពុងសិក្សានៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារមានចំនួន ៤០៨រូប ដែលក្នុងនោះថ្នាក់បរិញ្ញាបត្រជំនាន់ទី១ មាន ៩៣រូប (ស្រី ៦៦រូប) ថ្នាក់បរិញ្ញាបត្ររងជំនាន់ទី៣៣ មាន ១២៤រូប (ស្រី ៩០រូប) និងជំនាន់ទី៣៤ មាន ១៩១រូប (ស្រី ១៦៦រូប)។

មន្ត្រី-បុគ្គលិកមានចំនួន ៩៦រូប និងសាស្ត្រាចារ្យចំនួនមាន ៧៣រូប (ស្រី ១៧រូប) ដែល សាស្ត្រាចារ្យក្នុងប្រព័ន្ធធនាគារជាតិនៃកម្ពុជាមាន ៥៨រូប (ស្រី ១២រូប) និងក្រៅប្រព័ន្ធធនាគារជាតិនៃកម្ពុជាមានចំនួន ១៥រូប (ស្រី ៥រូប)។

**ក្រាហ្វ ៨៦៖ ស្ថិតិនិស្សិត**
(ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ទន្ទឹមនេះ វិទ្យាស្ថានបានបន្តសហការជាមួយដៃគូយុទ្ធសាស្ត្រទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិនានា ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុធនាគារកណ្តាល និងអាជ្ញាធររូបិយវត្ថុ និងដៃគូ សហការមួយចំនួនទៀត ដើម្បីវាយតម្លៃលក្ខណៈបច្ចេកទេសលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់វិទ្យាស្ថាន ធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សា ផ្លាស់ប្តូរបទពិសោធពាក់ព័ន្ធនឹងការរៀបចំកម្មវិធីសិក្សា បណ្តុះបណ្តាលនិស្សិតនិងការកែទម្រង់កម្មវិធីសិក្សា ក៏ដូចជារៀបចំសិក្ខាសាលានិងកិច្ចប្រជុំនានាសរុបប្រមាណ ៥១ កម្មវិធី ដែលមានអ្នកចូលរួមជាង ១២.៧៤៧រូប។



ការទស្សនាល្ខោននិយាយរឿង៖ "ឃាតករលាក់មុខ (Hidden Killer)" នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ



បទឧទ្ទេសនាម ក្រោមប្រធានបទស្តីពី ទំនាក់ទំនងអន្តរកម្ម និងផលប៉ះពាល់នៃការវិនិយោគ លើបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) លើសេដ្ឋកិច្ចគ្មានឧស្ម័នពុល (Zero Economy) ក្នុងក្របខ័ណ្ឌអាស៊ាន និងសិង្ហបុរី នាថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៥ នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ

សៀវភៅថ្មីៗពាក់ព័ន្ធនឹងចំណេះដឹងផ្នែកធនាគារ ហិរញ្ញវត្ថុ សេដ្ឋកិច្ច និងប្រវត្តិសាស្ត្រនានាត្រូវបានបន្តរៀបចំដាក់បញ្ចូលក្នុងបណ្ណាល័យ សម្រាប់បម្រើដល់ការសិក្សាស្រាវជ្រាវរបស់និស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ។ លើសពីនេះ បណ្ណាល័យអេឡិចត្រូនិក (E-Library) ត្រូវបាននិងកំពុងអភិវឌ្ឍដោយតភ្ជាប់ជាមួយបណ្ណាល័យអេឡិចត្រូនិករបស់ស្ថាប័នអន្តរជាតិ ដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងមហាវិទ្យាល័យនានាទាំងក្នុងនិងក្រៅប្រទេស។

ក្រៅពីមុខវិជ្ជាស្នូល វិទ្យាស្ថានក៏បានរៀបចំសកម្មភាពនិងកម្មវិធីសិក្សាបន្ថែម ដូចជាការទស្សនាភាពយន្ត ដំណើរទស្សនកិច្ចសិក្សា ថ្នាក់កីឡាតេក្វាន់ដូ និងការអានអត្ថបទខ្លីៗ One Week One Article ស្តីពី វិស័យធនាគារ ដោយអ្នកនិពន្ធបរទេសទាំងជាភាសាអង់គ្លេសនិងភាសាខ្មែរ។

## ៣- ការងារសវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

ដើម្បីឱ្យអនុវត្តការងាររបស់ធនាគារជាតិនៃកម្ពុជាប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចត្រូវបានបន្តពង្រឹងការប្រតិបត្តិតាម ការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចរបស់សវនដ្ឋាន។

ការងារសវនកម្មសម្រេចបានប្រមាណ ៩៥% នៃផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដោយបានអនុវត្តនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តស្វាយរៀង កំពង់ចាម កំពង់ធំ និងបាត់ដំបង។ វិសាលភាពសវនកម្មបានគ្របដណ្តប់លើប្រតិបត្តិការសំខាន់ៗដើម្បីការពារហានិភ័យតាមរយៈការពិនិត្យលើការប្រតិបត្តិតាម និងភាពគ្រប់គ្រាន់នៃការត្រួតពិនិត្យផ្ទៃក្នុងពាក់ព័ន្ធនឹងការគ្រប់គ្រងសាច់ប្រាក់ ការគ្រប់គ្រងគណនី ភាពត្រឹមត្រូវនៃការចុះកិច្ចបញ្ជិកា សន្តិសុខរូបវន្តនិងសុវត្ថិភាពប្រព័ន្ធ ជាដើម។ ទន្ទឹមនេះ ការពិនិត្យលើលក្ខណៈវិនិច្ឆ័យរបស់នាយកដ្ឋាន-អង្គភាពសម្រាប់កំណត់អាទិភាពក្នុងការធ្វើសវនកម្មកំពុងត្រូវបានរៀបចំសម្រាប់ជាមូលដ្ឋានក្នុងការកសាងផែនការសវនកម្មឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ លើសពីនេះ ការយល់ដឹងរបស់សវនករត្រូវបានពង្រឹងជាបន្តបន្ទាប់តាមរយៈការបណ្តុះបណ្តាលផ្សេងៗនិងការស្វែងយល់អំពីការងារនិងប្រតិបត្តិការរបស់នាយកដ្ឋាននានា ដូចជា នាយកដ្ឋានគ្រប់គ្រងទិន្នន័យនិងវាយតម្លៃហានិភ័យ នាយកដ្ឋានស្ថិរភាពហិរញ្ញវត្ថុ និងនាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់។ ចំណែកឯការងារអធិការកិច្ចត្រូវបានអនុវត្តលើការងារគ្រប់គ្រងសាច់ប្រាក់និងឃ្លាំងប្រាក់នៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តចំនួន ៩

(ខេត្តព្រៃវែង បាត់ដំបង កំពង់ស្ពឺ បន្ទាយមានជ័យ រតនគិរី តាកែវ កំពង់ឆ្នាំង ពោធិ៍សាត់ និងក្រចេះ) និងការពិនិត្យលើការងារកាត់កម្ទេចនិងដុតបំផ្លាញក្រដាសប្រាក់ចាស់ ទក់ រហែក ដើម្បីធានានូវសុវត្ថិភាពសាច់ប្រាក់ក្នុងឃ្លាំង និងការប្រតិបត្តិតាមគោលការណ៍ណែនាំ។

ក្នុងគោលដៅពង្រឹងការគ្រប់គ្រងហានិភ័យ និងធានានិរន្តរភាពធុរកិច្ចលើប្រតិបត្តិការ ផែនការនិរន្តរភាពធុរកិច្ចសម្រាប់ប្រព័ន្ធធនាគារស្នូលត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នកម្មដើម្បីឆ្លើយតបទៅនឹងការវិវត្តថ្មីៗនិងការផ្លាស់ប្តូរមុខងារ-ភារកិច្ច នៅតាមនាយកដ្ឋាននិងអគ្គនាយកដ្ឋានមួយចំនួន។



កិច្ចប្រជុំការងារអធិការកិច្ច នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥
នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តកំពង់ឆ្នាំង

ទន្ទឹមនេះ គណៈកម្មការគ្រប់គ្រងហានិភ័យនៃប្រព័ន្ធធនាគារស្នូលបានប្រជុំចំនួន ២លើក ដោយបានពិភាក្សាលើបញ្ហាដែលនៅដក់សល់ និងបញ្ហាថ្មីៗពាក់ព័ន្ធនឹងដំណើរការប្រព័ន្ធធនាគារស្នូល ១៤.៧ ការធ្វើបច្ចុប្បន្នកម្មផែនការបន្តនិរន្តរភាពធុរកិច្ចប្រព័ន្ធធនាគារស្នូល និងការធ្វើបច្ចុប្បន្នកម្មសៀវភៅកម្រងឯកសារណែនាំស្តីពីប្រតិបត្តិការរបស់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត។



កិច្ចប្រជុំគណៈកម្មការគ្រប់គ្រងហានិភ័យនៃប្រព័ន្ធធនាគារស្នូល
លើកទី៦៩ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ នៅធនាគារជាតិនៃកម្ពុជា

## ៤- សាខាធនាគារជាតិនៃកម្ពុជា

ប្រតិបត្តិការនៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តត្រូវបានបន្តពង្រឹងនិងពង្រីកជាប្រចាំ សំដៅគ្រប់គ្រងការធ្វើចរាចរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារឱ្យបានកាន់តែទូលំទូលាយ តាមរយៈការផ្តល់សេវាជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រសួងនិងមន្ទីរ-អង្គភាពរបស់រាជរដ្ឋាភិបាល ឱ្យកាន់តែមានគុណភាពនិងប្រសិទ្ធភាពខ្ពស់ថែមទៀត។ លើសពីនេះ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានបន្តចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល និងប្រមូលព័ត៌មាន-ទិន្នន័យសេដ្ឋកិច្ចតាមបណ្តារាជធានី-ខេត្តដូចជា ថ្លៃទំនិញនិងសេវា អត្រាប្តូរប្រាក់ និងអង្កេតទំនុកចិត្តធុរកិច្ច ដើម្បីរួមចំណែកក្នុងការតាមដានស្ថានភាពសេដ្ឋកិច្ច និងការរៀបចំគោលនយោបាយនានា។

ទន្ទឹមនេះ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ក៏បានផ្តល់សេវាបង់ប្រាក់ បើកប្រាក់ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអង្គភាពរដ្ឋ ប្តូរក្រដាសប្រាក់រៀលចាស់ ទក់ រហែកជូនសាធារណជន ក្នុងគោលបំណងជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយថែមទៀត។

**ក្រាហ្វ ៨៧៖ ស្ថិតិមន្ត្រី-បុគ្គលិកសាខារាជធានី-ខេត្ត**

(គិតត្រឹមខែមិថុនា ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ការប្តូរក្រដាសប្រាក់រៀល ចាស់ ទក់ និងរហែក ចូលក្នុងគណនីធាគច ឬធនាគារដែលជាសមាជិកធាគច ដោយមិនគិតកម្រៃសេវា នៅតាមបណ្តារាជធានី-ខេត្ត**





## ៥- សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា

សមាគមមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា (ស.ម.ធ) មានសមាជិកសរុប ២.៤៩៦រូប ដែលក្នុងនោះនៅស្នាក់ការកណ្ដាលចំនួន ១.៧៨៥រូប (និវត្តជន ១៥១រូប) និងនៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តចំនួន ៧១១រូប (និវត្តជន ១២៨រូប)។

គណៈកម្មាធិការ ស.ម.ធ អាណត្តិទី១០ បានប្រជុំចំនួន ២ លើក ដោយបានពិនិត្យនិងពិភាក្សាលើរបាយការណ៍សកម្មភាពការងារ និងការគ្រប់គ្រងមូលនិធិ ស.ម.ធ។ ទន្ទឹមនេះ គណៈកម្មាធិការ ស.ម.ធ បានចេញសេចក្ដីសម្រេចទទួលសមាជិកថ្មីចំនួន ២៩រូប និងលុបឈ្មោះសមាជិកចំនួន ៧រូប ដែលបានលាឈប់ពីការងារ និងទទួលមរណភាព។ អនុលោមតាមគោលការណ៍ ស.ម.ធ បានប្រើប្រាស់ថវិកាឧបត្ថម្ភជូនសមាជិកនិងសហព័ទ្ធសមាជិកចំនួន ១២៤ករណី ដែលក្នុងនោះសមាជិកនិងសហព័ទ្ធសមាជិកសម្រាលកូនចំនួន ៦៣រូប គ្រោះថ្នាក់ ១៦រូប ជំងឺធ្ងន់ធ្ងរ ៣៩រូប និងមរណភាព ៦រូប។ លើសពីនេះ ស.ម.ធ តែងតែចុះសួរសុខទុក្ខសមាជិកជាប្រចាំ។

**ក្រាហ្វ ៨៨៖ ការឧបត្ថម្ភរបស់ ស.ម.ធ**
(ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ជារួម ការបន្តអភិវឌ្ឍធនធានមនុស្សនិងអភិបាលកិច្ច គឺជាការងារអាទិភាពសម្រាប់ធនាគារជាតិនៃកម្ពុជា ដែលបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួន និងសមត្ថភាពរបស់មន្ត្រី-បុគ្គលិក ស្របពេលដែលវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ បានបន្តដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ជាពិសេសវិស័យធនាគារនិងហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ការងារសវនកម្ម និងអធិការកិច្ចត្រូវបានបន្តយកចិត្តទុកដាក់ ដើម្បីធានាបាននូវ អភិបាលកិច្ចល្អ។**

## VIII- ទំនាក់ទំនងសាធារណៈ

### ១- ការផ្សព្វផ្សាយតាមបណ្តាញសង្គម

ការងារផ្សព្វផ្សាយបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹង និងទំនុកចិត្តរបស់សាធារណជន និងភាគីពាក់ព័ន្ធលើការអនុវត្តតួនាទីធនាគារកណ្តាល ឱ្យបានកាន់តែទូលំទូលាយ។ បច្ចុប្បន្ន បណ្តាញសង្គមផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា រួមមាន គេហទំព័រផ្លូវការ ទំព័រហ្វេសប៊ុក LinkedIn, Instagram, X, Tiktok និង Youtube មានអ្នកតាមដានសរុបចំនួន ៣៧៥ ពាន់គណនី ដែលកើនឡើង ១២,៦ ពាន់គណនី ធៀបនឹងចុងឆ្នាំ២០២៤ ហើយមាតិកាដែលបានផ្សព្វផ្សាយសរុបមាន ១២៩ មាតិកា និងមានការចូលទស្សនាប្រមាណ ១៣ លានដង។ ការផ្សព្វផ្សាយក្នុងបណ្តាញសង្គមទាំងនេះ រួមមាន សកម្មភាពថ្នាក់ដឹកនាំនៅក្នុងកិច្ចប្រជុំ កិច្ចពិភាក្សាចែករំលែកចំណេះដឹង និងព្រឹត្តិការណ៍ផ្សេងៗជាច្រើនទៀតទាំងថ្នាក់ជាតិ និងអន្តរជាតិ ទាក់ទងនឹងប្រព័ន្ធទូទាត់ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល នយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងបរិយាបន្នហិរញ្ញវត្ថុជាដើម។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏ទទួលបាននិងឆ្លើយតបសាររបស់សាធារណជន តាមរយៈបណ្តាញសង្គម រួមទាំងអ៊ីមែលផ្នែកទំនាក់ទំនងចំនួន ៥៨៥ ដែលភាគច្រើនពាក់ព័ន្ធនឹងឥណទានក្រៅផ្លូវការ ការអនុវត្តគោលការណ៍ផ្សេងៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បណ្តឹងតវ៉ាពីការពន្យារពេលសងនិងបង់ផ្តាច់ឥណទាន ការបំភ្លឺទាក់ទងនឹងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាការអនុវត្តប្រកាសនិងបទប្បញ្ញត្តិថ្មីៗជាដើម។ ជំនួបអ្នកសារព័ត៌មានក៏ត្រូវបានរៀបចំឡើងផងដែរ ដើម្បីបញ្ជ្រាបការយល់ដឹងរបស់អ្នកសារព័ត៌មានលើប្រធានបទស្តីពី គោលនយោបាយគ្រប់គ្រងទុនបម្រុងអន្តរជាតិ និងហិរញ្ញប្បទានបៃតង។

### ២- ការផ្សព្វផ្សាយប្រព័ន្ធបាគង

ចំណេះដឹងអំពីការប្រើប្រាស់ប្រព័ន្ធបាគងនិងខេអេចឃ្យូអរ (KHQR) ត្រូវបានបញ្ជ្រាបដល់សាធារណជនតាមរយៈ៖ i/-សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ (KHQR)" ii/-កម្មវិធីចែករំលែកចំណេះដឹងស្តីពី "ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធនាគារ និងបរិយាបន្នហិរញ្ញវត្ថុ" iii/-កម្មវិធីតាំងពិព័រណ៍និងព្រឹត្តិការណ៍សាទរកម្ពុជា ជាដើម។ ការផ្សព្វផ្សាយទាំងនេះត្រូវបានធ្វើជាប្រចាំលើទំព័រហ្វេសប៊ុកផ្លូវការរបស់ "បាគង" និងនៅតាមបណ្តាគ្រឹះស្ថានអប់រំ និងក្រសួង-ស្ថាប័នស្តីពី ការទូទាត់បែបឌីជីថលនិងសន្ទានកម្មប្រព័ន្ធទូទាត់របស់ក្រសួង-ស្ថាប័នជាមួយប្រព័ន្ធទូទាត់បាគងសំដៅជំរុញនិងប្រែក្លាយជារាជរដ្ឋាភិបាលឌីជីថល។ ជាលទ្ធផល ការចុះឈ្មោះប្រើប្រាស់កម្មវិធីទូទាត់បាគងមានការកើនឡើង ២៦,៨ ពាន់គណនី ក្នុងឆមាសទី១ ឆ្នាំ២០២៥។



ក្រុមការងារបាគងផ្តល់ការបណ្តុះបណ្តាលអំពីកម្មវិធីទូទាត់បាគងទេសចរ និងនីតិវិធីក្នុងការបញ្ជាក់អត្តសញ្ញាណសម្រាប់ភ្ញៀវទេសចរអន្តរជាតិ

ការប្រើប្រាស់បាគងទេសចរ (Bakong Tourists) ក៏ត្រូវបានផ្សព្វផ្សាយដល់សាធារណជនជាតិនិងអន្តរជាតិយ៉ាងទូលំទូលាយ ជាពិសេសក្នុងព្រឹត្តិការណ៍ពិព័រណ៍ Natas Travel 2025 នៅប្រទេសសិង្ហបុរី ដើម្បីជំរុញកំណើនទេសចរមកកម្ពុជា និងទទួលបានអត្ថប្រយោជន៍ពីការទូទាត់

បែបឌីជីថលដែលមានភាពងាយស្រួល រហ័ស និងសុវត្ថិភាព។ ទន្ទឹមនេះ ការបណ្តុះបណ្តាលអំពីកម្មវិធីទូទាត់បាគងទេសចរ និងនីតិវិធីក្នុងការបញ្ជាក់អត្តសញ្ញាណភ្ញៀវទេសចរអន្តរជាតិ ក៏ត្រូវបានរៀបចំឡើងសម្រាប់ភ្នាក់ងារទេសចរ មគ្គុទ្ទេសក៍ទេសចរ សមាគមសណ្ឋាគារ សមាជិកបាគង ព្រមទាំងមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាតាមបណ្តារាជធានី-ខេត្តមួយចំនួនដែលមានសក្តានុពលទេសចរណ៍រួមមាន៖ រាជធានីភ្នំពេញ សៀមរាប កំពត ព្រះសីហនុ បាត់ដំបង និងបន្ទាយមានជ័យ សរុបប្រមាណ ៣០០ ស្ថាប័ន។

### ៣- ការលើកកម្ពស់ការយល់ដឹងអំពីប្រាក់រៀល



សិក្ខាសាលាស្តីពី "ប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និងខេអេចឃ្យូអរ" នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥ នៅវិមានរដ្ឋសភា

សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ប្រាក់រៀល ប្រព័ន្ធទូទាត់បាគង និងខេអេចឃ្យូអរ" ត្រូវបានរៀបចំឡើងនៅវិមានរដ្ឋសភា ក្នុងឱកាសអបអរសាទរ ខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ដោយមានការអញ្ជើញចូលរួមជាអធិបតីពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃព្រឹទ្ធសភា និងរដ្ឋសភា សមាជិក-សមាជិកា និងតំណាងមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ សរុបប្រមាណ ៣០០នាក់។ ជាលទ្ធផល អង្គសិក្ខាសាលាបានគាំទ្រទៅលើការប្រើប្រាស់ប្រាក់រៀលនៅក្នុងគ្រប់វិស័យ និងការបង្កើតជាយុទ្ធសាស្ត្រជាតិលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ ជាមួយគ្នានេះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានឯកភាពឱ្យបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងក្រុមការងារបច្ចេកទេសចំពោះកិច្ចការទទួលបន្ទុករៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងវិធានការគោលនយោបាយស្តីពី ការពង្រឹងការប្រើប្រាស់ប្រាក់រៀល។

សិក្ខាសាលាផ្សព្វផ្សាយអំពីប្រាក់រៀល ក៏ត្រូវបានរៀបចំឡើងនៅខេត្តចំនួន ៣ គឺ តាកែវ ក្រចេះ និងស្ទឹងត្រែង ដោយមានអ្នកចូលរួមទស្សនាសរុបជាង ២០ម៉ឺននាក់ ទាំងអ្នកចូលរួមផ្ទាល់ (១ម៉ឺននាក់) និងតាមបណ្តាញសង្គម។ នៅក្នុងកម្មវិធីនេះក៏មានការតាំងពិព័រណ៍ស្តីពីប្រវត្តិសេដ្ឋកិច្ច និងរូបិយវត្ថុ ការធ្វើបទបង្ហាញរបស់ក្រុមសិស្សានុសិស្សស្តីពីសារៈសំខាន់នៃប្រាក់រៀល និងវីដេអូខ្លីៗក្រោមប្រធានបទ "តើប្រាក់១ម៉ឺនរៀលអាចទិញអ្វីបានខ្លះ?" ក៏ដូចជាចំណេះដឹងផ្នែកហិរញ្ញវត្ថុ ប្រព័ន្ធទូទាត់បាគង និងសេវាហិរញ្ញវត្ថុរបស់បណ្តាគ្រឹះស្ថានហិរញ្ញវត្ថុផងដែរ។





កម្មវិធីផ្សព្វផ្សាយស្តីពី "ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ"

ដោយឡែក ធនាគារជាតិនៃកម្ពុជានិងក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំរួម ស្តីពី "ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល សម្រាប់សេវាទូទាត់នៅតាមគ្រឹះស្ថានសិក្សា" ដើម្បីឱ្យគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន៖ i/-ពិនិត្យលទ្ធភាពបើកគណនីប្រាក់បញ្ញើ គណនីទូទាត់សងប្រាក់ជាប្រាក់រៀល និងគណនីប្រាក់បៀវត្សរ៍តាមប្រព័ន្ធធនាគារជូនដល់គ្រប់បុគ្គលិកអប់រំទាំងអស់ ii/-បង្ហាញតម្លៃសិក្សានិងសេវានានាជាប្រាក់រៀល និង iii/-រៀបចំយន្តការសម្របសម្រួល និងលើកទឹកចិត្តបុគ្គលពាក់ព័ន្ធឱ្យធ្វើប្រតិបត្តិការទូទាត់ទៅគណនីធនាគារជាប្រាក់រៀលក្នុងសកម្មភាព ដូចជា ការបង់ថ្លៃសិក្សា និងសេវាទូទាត់ផ្សេងៗ។

### ៤- កិច្ចសហការជាមួយសមាគម និងស្ថាប័នផ្សេងៗក្នុងការងារផ្សព្វផ្សាយ

សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា នៅតែបន្តចូលរួមជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជន ដើម្បីបង្កើនការយល់ដឹង ការទទួលបាន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព បរិយាបន្ន និងចីរភាព។ កិច្ចសហប្រតិបត្តិការនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការរៀបចំសិក្ខាសាលា យុទ្ធនាការ និងកម្មវិធីផ្សព្វផ្សាយនានាដល់ក្រុមគោលដៅនីមួយៗ រួមទាំងកិច្ចការពាក់ព័ន្ធនឹងហិរញ្ញវត្ថុប្រកបដោយចីរភាពផងដែរ។

### ៥- ការរួមចំណែកក្នុងការងារសង្គម

ថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា បានចូលរួមក្នុងសកម្មភាពសង្គមសប្បុរសធម៌ជាពិសេសក្នុងវិស័យអប់រំ សុខាភិបាល និងសាសនា រួមមាន៖ i/- ចូលរួមឧបត្ថម្ភគម្រោងស្ថាបនា និងជួសជុលមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវនិងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានានៅក្នុងវត្តឧណ្ណាលោម រាជធានីភ្នំពេញ ii/- សម្ពោធអគារបណ្ណាល័យវិទ្យាល័យតាអោក ស្ថិតនៅក្នុងឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ iii/- ចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋរស់នៅក្នុងឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ iv/- នាំយកអំណោយនិងគ្រឿងឧបភោគបរិភោគមួយចំនួនជូនដល់នាយទាហាន នាយទាហានរង និងពលទាហានក្នុងកងពលតូចអន្តរាគមន៍លេខ១ v/- នាំយកចំណីអាហារ សម្លៀកបំពាក់ និងសម្ភារមួយចំនួនទៀតទៅឱ្យកុមារតូចៗនៅមណ្ឌលមែកឈើ (Branch Center) vi/- រៀបចំសិក្ខាសាលាស្តីពី "ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា" សម្រាប់សិស្សានុសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យចំនួន៣ នៅស្រុកសន្ទុក ខេត្តកំពង់ធំ និង vii/- ចុះសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ និងថវិកា ជូនប្រជាពលរដ្ឋដែលផ្លាស់ទីលំនៅបណ្តោះអាសន្នចេញពីតំបន់ប្រឈមនឹងបញ្ហាព្រំដែនកម្ពុជា-ថៃ។ លើសពីនេះ នាខែកុម្ភៈ ឆ្នាំ២០២៥ ក្រសួង អប់រំ យុវជន និងកីឡា បានចេញសេចក្តីប្រកាស ស្តីពី ការទទួលស្គាល់ជ័យលាភី សាលាបឋមសិក្សាតាំងក្រសាំង ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំជាសាលារៀនគំរូប្រចាំឆ្នាំសិក្សា ២០២៣-២០២៤ ដែលសាលានេះ តែងទទួលបានការឧបត្ថម្ភជាបន្តបន្ទាប់ពីថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា។





ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សព្វព្រះរាជហឫទ័យស្ដេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ សម្ពោធមហាកុដិសម្ដេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានា នៅក្នុងវត្តឧណ្ណាលោម ក្នុងសង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគ្រឿងឥស្សរិយយសមេដាយសម្ដេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរត្ន ថ្នាក់មហាសេរីវឌ្ឍន៍ ដល់លោកជំទាវបណ្ឌិត ជា សិរី នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥



លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារបណ្ណាល័យវិទ្យាល័យតាអោក ស្ថិតនៅក្នុងឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥



លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាអធិបតី ក្នុងពិធីចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជូនប្រជាពលរដ្ឋរស់នៅក្នុងឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥



លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញនាំយកចំណីអាហារ សម្លៀកបំពាក់ និង សម្ភារមួយចំនួនទៀតទៅឱ្យកុមារតូចៗ នៅមណ្ឌលមែកឈើ នាថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៥



លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមជាអធិបតីក្នុងទិវាស្ដាប់ឮកម្ពុជា ឆ្នាំ២០២៥ ក្រោមប្រធានបទ "បង្កើនអានុភាពសម្រាប់តម្លៃទាំត្រចៀក និងការស្ដាប់ឮ" របស់អង្គការរក្សាកុមារ នៅវិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៥



លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាស្តីពី "ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា" នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ នៅស្រុកសន្ទុក ខេត្តកំពង់ធំ



លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញដឹកនាំក្រុមការងារ ចុះសួរសុខទុក្ខ និងនាំយកអំណោយ ជាគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន ជូនប្រជាពលរដ្ឋដែលបានផ្លាស់ទីលំនៅបណ្តោះអាសន្នចេញពីតំបន់ប្រឈមនឹងបញ្ហាព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តព្រះវិហារ នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥

## ៦- សារមន្ទីរព្រះស្រីល្បសានវរ្ម័ន

ក្នុងឆមាសនេះ ភ្ញៀវចូលមកទស្សនា សារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីល្បសានវរ្ម័ន (ស.ស.រ.) មានចំនួន ២៤.៣៣៨នាក់ ក្នុងនោះមានភ្ញៀវជាសិស្សប្រមាណ ៤៧%។ ទន្ទឹមនេះ សារមន្ទីរបានទទួលបដិសណ្ឋារកិច្ចឥស្សរជនជាន់ខ្ពស់ រួមមាន៖ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី វង្សី វិស្សុត រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃព្រឹទ្ធសភា ឯកឧត្តម Masato Kanda ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ឯកឧត្តម Aivo H. Andrianarivelo ទេសាភិបាលធនាគារកណ្តាលម៉ាដាហ្គាស្កា ឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំកម្ពុជា ឯកឧត្តម Tull Traisorat ឯកអគ្គរាជទូតថៃប្រចាំកម្ពុជា និងលោក Jo Scheuer អ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា។ ស.ស.រ. តែងតែទទួលបានការវាយតម្លៃខ្ពស់ពីអ្នកមកទស្សនា ទាំងជាតិ និងអន្តរជាតិ។ ជាក់ស្តែង ស.ស.រ. ទទួលបានពានរង្វាន់ Travelers' Choice Awards Winner ប្រចាំឆ្នាំ២០២៤ ពីគេហទំព័រ Tripadvisor ដែលជាក្រុមហ៊ុនផ្សព្វផ្សាយរមណីយដ្ឋានទេសចរណ៍ទូទាំងពិភពលោក។ លើសពីនេះ ស.ស.រ. បានរៀបចំនូវវេទិកាសាធារណៈ ក្នុងគោលបំណងផ្សព្វផ្សាយចំណេះដឹងស្តីពី ប្រវត្តិសាស្ត្រនិងសេដ្ឋកិច្ចដល់សាធារណជន ព្រមទាំងលើកស្ទួយស្នាដៃវិចិត្រករជាតិ និងអន្តរជាតិ។

**ក្រាហ្វ ៨៩៖ ចំនួនភ្ញៀវទស្សនាសរុប**

(ឆ្នាំ២០២១- ឆមាសទី១ ឆ្នាំ២០២៥)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់ ៣៖ វេទិកាសាធារណៈនានា ដែលរៀបចំដោយសារមន្ទីរ ស.ស.រ.**

i/- ស.ស.រ.បានសហការជាមួយធនាគារកណ្ដាលម៉ាឡេស៊ី និងធនាគារកណ្ដាលអាស៊ានផ្សេងទៀតរៀបចំពិព័រណ៍ក្រោមប្រធានបទ "Numismatic Marvels, Mints History" ក្នុងឱកាសដែលប្រទេសម៉ាឡេស៊ីជាប្រធានអាស៊ាន នៅទីក្រុងកូឡាឡាំពួរ

ii/- សម្ពោធពិព័រណ៍ក្រោមកិច្ចសហការរៀបចំជាមួយមូលនិធិនៃប្រទេសជប៉ុន (Japan Foundation) ក្រោមប្រធានបទ "ទីក្រុងតូក្យូ អតីតកាល និងបច្ចុប្បន្នកាល" (Tokyo before and after) នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៥ រយៈពេល១ខែ ទទួលបានភ្ញៀវចូលទស្សនាចំនួន ៩៥០រូប

iii/- ការរៀបចំពិធីប្រកាសសៀវភៅស្ដីអំពី "ប្រវត្តិព្រះមហាក្សត្រខ្មែរពីអតីតកាលដល់បច្ចុប្បន្ន" និពន្ធដោយ ឯកឧត្ដមបណ្ឌិត Julio A.Jeldres ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាអ្នកតាក់តែងជីវប្រវត្តិផ្លូវការរបស់ **ព្រះបរមរតនកោដ្ឋ** នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥

iv/- សិក្ខាសាលាលើប្រធានបទស្ដីអំពី "ជនជាតិភាគតិចស្អូចនៅកម្ពុជា" និង "ភាសាខ្មែរ" ដោយលោកបណ្ឌិត Jean-Michel Filippi ជាវាគ្មិន នាថ្ងៃទី៩ និងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ ដោយមានអ្នកចូលរួមប្រមាណ ១០០នាក់ ក្នុង១វគ្គ និង

v/- ពិព័រណ៍ខ្នាតតូចនៅក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល នាថ្ងៃទី១៥-១៧ ខែឧសភា ឆ្នាំ២០២៥។

ស.ស.រ. ក៏បានបោះផ្សាយសៀវភៅកាតាឡុកដែលមានចំណងជើងថា "វត្តអារាមនៅប្រទេសកម្ពុជា" នៃពិព័រណ៍មិនអចិន្ត្រៃយ៍ក្រោមប្រធានបទ "ទិដ្ឋភាពប្រទេសកម្ពុជាក្នុងគំនូរតាមវត្តអារាម (១៨៩០-១៩៧០)" ជាភាសាខ្មែរ និងភាសាអង់គ្លេស។ លើសពីនេះ ស.ស.រ. បាត់ដំបងបានឈានដល់ដំណាក់កាលដំឡើងផ្ទាំងព័ត៌មាន និងទូតាំងវត្ថុនៃពិព័រណ៍ ដើម្បីគ្រោងសម្ពោធដាក់ដំណើរការនៅក្នុងឆ្នាំ២០២៦ខាងមុខនេះ។ ដោយឡែក ការងារមជ្ឈមណ្ឌលតាំងពិព័រណ៍នៅខេត្តកំពត ត្រូវបានបញ្ចប់រួចរាល់នូវប្លង់បច្ចេកទេស និងត្រៀមបើកការដ្ឋានជួសជុល និងកែលម្អក្នុងឆ្នាំ២០២៥នេះ។




កិច្ចសហការជាមួយ ធនាគារកណ្ដាលប្រទេសម៉ាឡេស៊ី ក្រោមប្រធានបទ "Numismatic Marvels, Mints History" ក្នុងឱកាសដែលប្រទេសម៉ាឡេស៊ីជាប្រធានអាស៊ាន នៅទីក្រុងកូឡាឡាំពួរ នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៥



ពិធីប្រកាសសៀវភៅស្ដីអំពី "ប្រវត្តិព្រះមហាក្សត្រខ្មែរពីអតីតកាលដល់បច្ចុប្បន្ន" និពន្ធដោយ ឯកឧត្ដមបណ្ឌិត Julio A.Jeldres ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាអ្នកតែងជីវប្រវត្តិផ្លូវការរបស់ ព្រះបរមរតនកោដ្ឋ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥



ឯកឧត្តមឧបនាយករដ្ឋមន្ត្រី វង្សី វិស្សុត រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃព្រឹទ្ធសភា អញ្ជើញមកទស្សនាសារមន្ទីរ ស.ស.រ. នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥



ឯកឧត្តម Masato Kanda ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អញ្ជើញមកទស្សនាសារមន្ទីរ ស.ស.រ. នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥



រូបភាពសារមន្ទីរ ស.ស.រ. ខេត្តបាត់ដំបង



រូបភាពមជ្ឈមណ្ឌលតាំងពិព័រណ៍ ខេត្តកំពត

សរុបមក ការងារទំនាក់ទំនងសាធារណៈត្រូវបានបន្តលើកកម្ពស់ជាប្រចាំ តាមរយៈការពង្រឹង និងពង្រីកការផ្សព្វផ្សាយតាមបណ្តាញសង្គម ព្រមទាំងនៅក្នុងកម្មវិធីនានា នូវគោលនយោបាយ បទប្បញ្ញត្តិ គោលការណ៍ថ្មីៗ សកម្មភាពសង្គម កម្មវិធីអប់រំចំណេះដឹង សិក្ខាសាលា និងពិព័រណ៍ ពាក់ព័ន្ធនឹងសកម្មភាពលើកកម្ពស់ប្រាក់រៀល ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងប្រព័ន្ធបាគង ទាំងនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្នុងគោលបំណងបង្កើនការយល់ដឹងនិងជំនឿទុកចិត្តរបស់សាធារណជនមកលើធនាគារជាតិនៃកម្ពុជា ក៏ដូចជាប្រព័ន្ធធនាគារកម្ពុជា។ បន្ថែមពីនេះ ស.ស.រ. បានផ្សព្វផ្សាយយ៉ាងសកម្មនូវចំណេះដឹងស្តីពី ប្រវត្តិសាស្ត្រសេដ្ឋកិច្ចនិងរូបិយវត្ថុ ដល់សាធារណជន។

## សេចក្ដីសន្និដ្ឋាន

សេដ្ឋកិច្ចកម្ពុជាបន្តមានកំណើនល្អនាឆមាសទី១ ឆ្នាំ២០២៥នេះ ជាមួយនឹងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជា បន្តសម្រេចបាននូវគោលដៅសំខាន់ៗ ដែលរួមចំណែកក្នុងការគាំទ្រកំណើន ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ ជាក់ស្ដែង អតិផរណាបានបន្តស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន បើទោះបីជាបានកើនឡើងខ្ពស់កាលដើមឆ្នាំក៏ដោយ ក្នុងពេលដែលអត្រាប្ដូរប្រាក់មានស្ថិរភាពល្អប្រសើរ ដែលបានចូលរួមការពារអំណាចទិញរបស់ប្រជាពលរដ្ឋ។ លើសពីនេះ ទុនបម្រុងអន្តរជាតិបានកើនឡើងគួរឱ្យកត់សម្គាល់ ដែលបានជួយពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិនមកលើសេដ្ឋកិច្ចកម្ពុជា។

ប្រព័ន្ធធនាគារបន្តមានវឌ្ឍនភាព និងរក្សាបានភាពធន់ ព្រមទាំងបានរួមចំណែកគាំទ្រសកម្មភាពសេដ្ឋកិច្ច និងនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជួយសម្រាលការលំបាករបស់អាជីវករ និងប្រជាជនដែលកំពុងប្រឈមនឹងការថយចុះចំណូលជាបណ្ដោះអាសន្ន។ ចំណែកឯចំណេះដឹងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានយកចិត្តទុកដាក់លើកកម្ពស់ជាលំដាប់ ដែលបានបង្កើនការយល់ដឹងរបស់សាធារណជន និងភាគីពាក់ព័ន្ធ ព្រមទាំងលើកកម្ពស់ការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលឱ្យកាន់តែទូលំទូលាយ។ ទន្ទឹមនេះ ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ក៏បានចូលរួមលើកកម្ពស់សេដ្ឋកិច្ចឌីជីថល បរិយាបន្នហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រាក់រៀលផងដែរ។ ការតភ្ជាប់ប្រព័ន្ធទូទាត់សងប្រាក់ជាមួយបណ្ដាប្រទេសជាច្រើនក្នុងតំបន់ និងក្រុមហ៊ុនផ្ដល់សេវាទូទាត់អន្តរជាតិនានា ត្រូវបានពង្រីកជាបន្តបន្ទាប់ ដែលបានសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងទេសចរណ៍។ ម្យ៉ាងទៀត ការគ្រប់គ្រងចរាចរណ៍សាច់ប្រាក់បានរួមចំណែកក្នុងការបំពេញតម្រូវការប្រើប្រាស់ និងគាំទ្រដល់ការរីកចម្រើនសេដ្ឋកិច្ចនៅតាមតំបន់នានាទូទាំងប្រទេស។

ដោយឡែក ស.ហ.ក. បានបន្តពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការវិភាគរបាយការណ៍ប្រតិបត្តិការនិងបញ្ជូនរបាយការណ៍ទៅអាជ្ញាធរអនុវត្តច្បាប់និងភាគីជាដៃគូ ការធានាអនុលោមភាពរបស់បុគ្គលរាយការណ៍ ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងស្រុកនិងក្រៅប្រទេស និងការបណ្ដុះបណ្ដាលដល់មន្ត្រី-បុគ្គលិករបស់ ស.ហ.ក. និងភាគីពាក់ព័ន្ធ ព្រមទាំងបន្តសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ លើការងារវាយតម្លៃហានិភ័យថ្នាក់ជាតិ លើកទី២។

ម្យ៉ាងទៀត អភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្ស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារ និងគុណភាពនៃការផ្ដល់សេវាធនាគារកណ្ដាល។ ជាមួយគ្នានេះ កិច្ចសហប្រតិបត្តិការអន្តរជាតិបានលើកកិត្តិនាមរបស់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាប្រទេសកម្ពុជានៅលើឆាកអន្តរជាតិ ជំរុញការផ្លាស់ប្ដូរចំណេះដឹងនិងបទពិសោធ ព្រមទាំងបានរួមចំណែកពង្រឹងសមាហរណកម្មវិស័យធនាគារនិងហិរញ្ញវត្ថុទៅក្នុងតំបន់និងពិភពលោក និងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុក្នុងតំបន់។

# ផ្នែកទី២ - ទស្សនវិស័យ និងទិសដៅការងារ ឆមាសទី២ ឆ្នាំ២០២៥

## ទស្សនវិស័យ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៥

ពិភពលោកបន្តប្រឈមនឹងភាពមិនច្បាស់លាស់កាន់តែខ្លាំង ដោយសារការកើនឡើងជម្លោះប្រដាប់អាវុធនៅតាមតំបន់នានា បន្ថែមលើនិន្នាការគាំពារនិយម និងហានិភ័យនៃការប្រែប្រួលអាកាសធាតុ គួបផ្សំនឹងបញ្ហាដក់សល់ពីវិបត្តិកូវីដ-១៩ ជាពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍ។ កត្តាទាំងនេះអាចនាំឱ្យសេដ្ឋកិច្ចពិភពលោកថយចុះជាងការរំពឹងទុក និងដាក់សម្ពាធលើទីផ្សារហិរញ្ញវត្ថុក៏ដូចជាបង្កើនហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុ។ មូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករ[1]បន្ទាបអត្រាកំណើនសេដ្ឋកិច្ចពិភពលោកប្រចាំឆ្នាំ២០២៥ មកត្រឹម ២,៨%[2] (៣,៣% នៅឆ្នាំ២០២៤) មុនពេលងើបឡើងវិញបន្តិចដល់ ៣% ក្នុងឆ្នាំ២០២៦ ដោយបានរួមបញ្ចូលផលប៉ះពាល់មួយចំនួនពីការអនុវត្តគោលនយោបាយពន្ធគយបដិការ។ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ត្រូវបានប៉ាន់ស្មានថាមានកំណើនទាបត្រឹម ១,៤% ដែលក្នុងនោះ សហរដ្ឋអាមេរិក ១,៨% តំបន់អឺរ៉ូ ០,៨% និងបណ្ដាប្រទេសអភិវឌ្ឍន៍[3]ផ្សេងទៀត ១,៨%។ ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍអាចនឹងថយល្បឿនកំណើនមកត្រឹម ៣,៧% ដែលក្នុងនោះ ប្រទេសចិន ៤% ឥណ្ឌា ៦,២% រុស្ស៊ី ១,៥% និងតំបន់អាស៊ាន ៤,១%។ អត្រាអតិផរណាពិភពលោកត្រូវបានប៉ាន់ស្មានថាថយចុះមក ៤,៣%[4] ក្នុងឆ្នាំ២០២៥ (ពី ៥,៧% ឆ្នាំ២០២៤) ដែលក្នុងនោះប្រទេសអភិវឌ្ឍន៍មានកម្រិត ២,៥% ហើយប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍ ៥,៥% ។

ស្ថិតក្នុងបរិការណ៍នេះ សេដ្ឋកិច្ចកម្ពុជាអាចបន្តប្រឈមនឹងហានិភ័យពីខាងក្រៅកាន់តែខ្លាំងនាឆមាសទី២ ឆ្នាំ២០២៥។ ទន្ទឹមនេះ ហានិភ័យខាងក្នុងលើសេដ្ឋកិច្ចកម្ពុជា រួមមាន i/- ឥទ្ធិពលនៃការអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាមេរិក លើការនាំចេញទំនិញរបស់កម្ពុជា ii/- ផលប៉ះពាល់ពីជម្លោះព្រំដែនកម្ពុជា-ថៃ iii/- ភាពទន់ខ្សោយនៃវិស័យសំណង់និងអចលនទ្រព្យ iv/- ការពឹងផ្អែកខ្លាំងនៃវិស័យកសិកម្មទៅលើអាកាសធាតុ v/- កំណើនយឺតនៃឥណទាន និងការកើនឡើងឥណទានមិនដំណើរការ vi/- ពិពិធកម្មសេដ្ឋកិច្ចនៅមានកម្រិត និង vii/- កម្រិតខ្ពស់នៃដុល្លារូបនីយកម្មដែលដាក់កំហិតលើការអនុវត្តនយោបាយរូបិយវត្ថុ។ ក្រោមសម្មតិកម្មនៃការថយចុះកំណើនសេដ្ឋកិច្ចនៃប្រទេសដៃគូពាណិជ្ជកម្មកម្ពុជា ការថយល្បឿនកំណើននៃការនាំចេញ និងការកើនឡើងទាបជាងការរំពឹងទុកនៃវិស័យទេសចរណ៍ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងអាចសម្រេចបានក្នុងអត្រា ៥,២%។ កំណើននេះគាំទ្រដោយចម្បងដោយ៖ i/-វិស័យកម្មន្តសាលកើន ៧,៣% (អនុវិស័យកម្មន្តសាលកាត់ដេរ ៥% និងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ១០%) ii/-សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារកើន ៦,៦% iii/-វិស័យកសិកម្មកើន ១,១% និង iv/-វិស័យសំណង់ និងអចលនទ្រព្យកើន ០,៧% ដូចគ្នា។

---

[1] ខែមេសា ឆ្នាំ២០២៥។

[2] ពីការព្យាករ ៣,៣% ក្នុងខែមករា ឆ្នាំ២០២៥។

[3] លើកលែងប្រទេសក្នុងតំបន់អឺរ៉ូ និងប្រទេសធំទាំង៧ (កាណាដា បារាំង អាល្លឺម៉ង់ អ៊ីតាលី ជប៉ុន អង់គ្លេស និងសហរដ្ឋអាមេរិក)។

[4] របាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចពិភពលោករបស់ IMF ចេញផ្សាយខែមេសា ឆ្នាំ២០២៥។

**ក្រាហ្វ ៩០ ៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**

(គិតជាភាគរយ, ឆ្នាំ២០១៩ - ២០២៥ព)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា *ព=ព្យាករ

## ការព្យាករអតិផរណា

អតិផរណានាឆមាសទី២ ឆ្នាំ២០២៥ ត្រូវបានព្យាករថានឹងថមថយមកត្រឹម ១,៣% ក្នុងនោះ ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈធ្លាក់ចុះ -១,៤% (ធៀបនឹង -២,៥% នាឆមាសទី១) កំណើនថ្លៃក្រុមម្ហូបអាហារនឹងថមថយមក ២,៤% (ធៀបនឹង ៤,៨% នាឆមាសទី១) និងអតិផរណាស្នូលថយល្បឿនមកត្រឹម ០,៥% (ធៀបនឹង ២,៩% នាឆមាសទី១)។ ការព្យាករនេះត្រូវបានធ្វើឡើងក្រោមការសន្មតថា៖ i/- តម្រូវការក្នុងស្រុកនៅមានកំណើនយឺត ii/-ការផ្គត់ផ្គង់ក្នុងស្រុកនៅបន្តមានភាពរឹងមាំ iii/-ថ្លៃប្រេងនៅពិភពលោកបន្តនិន្នាការធ្លាក់ចុះ[៩] និង iv/-ភាពតានតឹងភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ចមិនបង្កឱ្យមានការឡើងថ្លៃម្ហូបអាហារនិងប្រេងឥន្ធនៈយ៉ាងគំហុក។ សម្រាប់ឆ្នាំ២០២៥ អតិផរណាត្រូវបានព្យាករថាមានកម្រិតជាមធ្យម ២,៤%។

**ក្រាហ្វ ៩១៖ អតិផរណាព្យាករ**

(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, សម្រាប់ឆមាសទី២ ឆ្នាំ២០២៥)




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិនិងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា *ព=ព្យាករ

[៩] កម្រិតថ្លៃប្រេងនៅជាមធ្យមត្រូវបានរំពឹងទុកថានឹងថយចុះ ១៥% ពី ៧៧,២៣ ដុល្លារអាមេរិក/បារ៉ែល នាឆមាសទី២ ឆ្នាំ២០២៤ មកត្រឹម ៦៦ ដុល្លារអាមេរិក/បារ៉ែល នាឆមាសទី២ ឆ្នាំ២០២៥។

**តារាង ២៖ ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជា ដោយរាជរដ្ឋាភិបាលនិងស្ថាប័នអន្តរជាតិនានា**

| | ឆ្នាំ២០២៥ប | ឆ្នាំ២០២៦ព |
|---|---|---|
| រាជរដ្ឋាភិបាល | ៥,២% | ៥% |
| មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) | ៤% | ៣,៤% |
| ធនាគារពិភពលោក (WB) | ៤% | ៤,៥% |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ៦,១% | ៦,២% |
| អង្គភាព AMRO | ៤,៩% | ៤,៧% |

សម្គាល់៖ ប=ប៉ាន់ស្មាន, ព=ព្យាករណ៍

ដើម្បីបន្តរួមចំណែកគាំទ្រនិងអនុវត្តតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ របស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា បានកំណត់ទិសដៅការងារសំខាន់ៗសម្រាប់ឆមាសទី២ ឆ្នាំ២០២៥ ដូចខាងក្រោម៖

### ១- ការអនុវត្តនយោបាយរូបិយវត្ថុ

- គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប
- រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដោយតាមដាននិងធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជនលើរូបិយវត្ថុជាតិ
- លើកកម្ពស់ការប្រើប្រាស់និងចំណេះដឹងពីប្រាក់រៀល
- កែលម្អនិងពង្រឹងប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុ និងអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ
- អភិវឌ្ឍក្របខ័ណ្ឌកូរីដ័រអត្រាការប្រាក់ និង
- លើកកម្ពស់ការយល់ដឹងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្តីពី ក្របខ័ណ្ឌនិងឧបករណ៍នយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

### ២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

- ធ្វើវិសិដ្ឋកម្មប្រព័ន្ធគ្រប់គ្រងទុនបម្រុង Calypso ពីជំនាន់ទី១៧ ទៅជំនាន់ទី១៨
- បន្តធ្វើបច្ចុប្បន្នកម្មឯកសារស្តីពី ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រី-បុគ្គលិក ឱ្យស្របតាមស្តង់ដាអន្តរជាតិ
- បន្តតាមដានស្ថានភាពទីផ្សារហិរញ្ញវត្ថុសកល បណ្តាប្រទេសអភិវឌ្ឍន៍ និងប្រទេសទីផ្សារកំពុងលូតលាស់ ដើម្បីត្រៀមរៀបចំយុទ្ធសាស្ត្រវិនិយោគដែលមានភាពបត់បែនប្រកបដោយសុវត្ថិភាព សន្ទនីយភាព និងស្វែងរកចំណូលសមស្រប
- បន្តការងាររៀបចំគោលនយោបាយវិនិយោគមូលនិធិសោធនរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា
- បន្តសិក្សាលើឱកាសនិងនីតិវិធីវិនិយោគមូលនិធិសោធនរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា
- បន្តសិក្សាស្រាវជ្រាវលើឧបករណ៍វិនិយោគថ្មីៗ ដើម្បីសម្រេចបានពិពិធកម្មហានិភ័យ និងបង្កើនចំណូល និង

- បន្តសិក្សាពីឱកាស និងលទ្ធភាពពង្រីកការវិនិយោគក្រោមក្របខ័ណ្ឌការវិនិយោគប្រកបដោយការទទួលខុសត្រូវលើបរិស្ថាន សង្គម និងអភិបាលកិច្ចល្អ។

**៣- ការងារអភិវឌ្ឍទីផ្សារប្ដូរប្រាក់**

- រៀបចំកែសម្រួលវិធីសាស្ត្រក្នុងការកំណត់អត្រាប្ដូរប្រាក់ផ្លូវការដើម្បីឱ្យស្របតាមការវិវត្តជាក់ស្ដែងនៃទីផ្សារប្ដូរប្រាក់នៅប្រទេសកម្ពុជា
- រៀបចំលក្ខខណ្ឌ និងខចែង ស្ដីពីការប្រើប្រាស់សេវាប្ដូរប្រាក់តាមប្រព័ន្ធទូរស័ព្ទចល័ត Bakong Foreign Exchange Application (Bakong FX App) របស់ធនាគារជាតិនៃកម្ពុជា
- បន្តសហការក្នុងការធ្វើទំនើបកម្មប្រព័ន្ធ NBCP សម្រាប់ជួញដូរប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក
- សិក្សាពីការបង្កើតសន្ទស្សន៍សម្ពាធទីផ្សារប្ដូរប្រាក់ (Exchange Market Pressure index) ដើម្បីតាមដានវដ្ដនៃការធ្លាក់ថ្លៃប្រាក់រៀល និងប្រព័ន្ធព្រមាននៃការវិវត្តទៅវិបត្តិអត្រាប្ដូរប្រាក់ (Early Warning System) និង
- សិក្សាពីការបង្កើតឧបករណ៍ FX Swap និង FX Forward ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងហានិភ័យអត្រាប្ដូរប្រាក់។

**៤- ប្រព័ន្ធទូទាត់សងប្រាក់**

- បន្តអភិវឌ្ឍ និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់
- បន្តអនុវត្តគម្រោងទូទាត់សងប្រាក់ និងផ្ទេរប្រាក់ឆ្លងដែនទាំងទ្វេភាគីនិងពហុភាគីជាមួយប្រទេស និងដៃគូសហការក្នុងតំបន់ និងអន្តរជាតិ
- បន្តលើកកម្ពស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ស្របតាមផែនទីមគ្គុទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ និងបន្តរៀបចំវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា
- បន្តលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល និងការប្រើប្រាស់ប្រព័ន្ធបាគងឱ្យកាន់តែទូលំទូលាយ និងបន្តការអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ជំហានបន្ទាប់
- បន្តដាក់ចេញនូវក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ និង
- បន្តតាមដាន និងត្រួតពិនិត្យគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់។

**៥- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

- តាមដានជាប្រចាំអំពីស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈការត្រួតពិនិត្យលើឯកសារ ការចុះត្រួតពិនិត្យដល់ទីកន្លែង ការធ្វើស្ត្រេសតេស្ត ហានិភ័យបច្ចេកវិទ្យា ព្រមទាំងការតាមដានការអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- បន្តធ្វើបច្ចុប្បន្នកម្ម វិធីសាស្ត្រត្រួតពិនិត្យស្របតាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគត
- បន្តតាមដានការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម
- បន្តសិក្សាសមិទ្ធិលទ្ធភាពដាក់ឱ្យប្រើប្រាស់បរិវត្តឌីជីថលក្នុងការត្រួតពិនិត្យ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

- បន្តកិច្ចសហការជាមួយស្ថាប័នជាតិ និងដៃគូអភិវឌ្ឍន៍នានា
- បន្តការកសាងសមត្ថភាព តាមរយៈវគ្គបណ្តុះបណ្តាលជូនដល់មន្ត្រីត្រួតពិនិត្យ និងបុគ្គលិកគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បន្តតាមដាន និងត្រួតពិនិត្យលើវឌ្ឍនភាពនៃការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិរបស់អ្នកផ្តល់ទិន្នន័យ និងអ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន និង
- រៀបចំឱ្យមានផ្ទាំងព័ត៌មានលម្អិត សម្រាប់គាំទ្រដល់ការវិភាគ វាយតម្លៃហានិភ័យ និងការដាក់ចេញនូវគោលនយោបាយនានាសម្រាប់ប្រព័ន្ធធនាគារ។

## ៦- ការងារបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ

### ការងារច្បាប់ និងបទប្បញ្ញត្តិ

- រៀបចំប្រកាសស្តីពី៖ i/-វិធានការបុរេសកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ii/-ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iii/-ការកំណត់ពិដានអត្រាការប្រាក់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ iv/-ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ v/-អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ vi/-ការគូបសរុបផ្នែកបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង vii/-សេចក្តីណែនាំស្តីពីការវាយតម្លៃទ្រព្យធានាក្នុងគោលបំណងវាយតម្លៃលើអ៊ីមភែរមិន។

### ការងារបរិយាបន្នហិរញ្ញវត្ថុ

- តាមដាន និងវាយតម្លៃលើយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥
- ធ្វើបច្ចុប្បន្នកម្មលើយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ និង
- ជំរុញការអនុវត្តការងារបរិយាបន្នហិរញ្ញវត្ថុ និងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល នៅតាមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

### ការងារហិរញ្ញវត្ថុប្រកបដោយចីរភាព

- បញ្ចប់ការរៀបចំផែនទីចង្អុលទិសសម្រាប់ហិរញ្ញវត្ថុបៃតងនៅកម្ពុជា និងការអភិវឌ្ឍប្រព័ន្ធវគ្គីករសាស្ត្រហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា សម្រាប់ដំណាក់កាលទី១ និងសិក្សាបន្ថែមវិស័យផ្សេងទៀតនៅដំណាក់កាលក្រោយទៀត
- រៀបចំយន្តការស្តីពី ការរាយការណ៍ និងតម្លាភាពហិរញ្ញវត្ថុប្រកបដោយចីរភាព (Reporting and Disclosure)
- បញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងក្របខ័ណ្ឌវាយតម្លៃ និងការពារហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ
- កសាងសមត្ថភាព និងចំណេះដឹងដល់វិស័យធនាគារ និងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធលើប្រធានបទហិរញ្ញវត្ថុប្រកបដោយចីរភាព និង
- សិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនានា ក្នុងគោលដៅរៀបចំនិងដាក់ចេញគោលនយោបាយគាំទ្រហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា ដើម្បីជំរុញការកៀរគរប្រភពទុន សំដៅគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងមានកម្រិតកាបូនទាប។

**កិច្ចការពារប្រាក់បញ្ញើ**

- រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់បុព្វលាភ ការផ្តល់សំណង មូលនិធិ គោលដៅ និងប្រភេទប្រាក់បញ្ញើដែលស្ថិតក្រោមវិសាលភាពនៃយន្តការកិច្ចការពារប្រាក់បញ្ញើ
- រៀបចំនីតិវិធី និងគោលនយោបាយនៃការវិនិយោគមូលនិធិកិច្ចការពារប្រាក់បញ្ញើ
- បន្តសិក្សាអំពីការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងដំណោះស្រាយគ្រឹះស្ថានធនាគារដែលមានបញ្ហា និងនីតិវិធីជម្រះបញ្ជីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បន្តទំនាក់ទំនងជាមួយសមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ធនាគារអភិវឌ្ឍន៍ពហុភាគី និងដៃគូអភិវឌ្ឍន៍នានា ក្នុងការអនុវត្តក្របខ័ណ្ឌកិច្ចការពារប្រាក់បញ្ញើ និង
- បន្តកសាងសមត្ថភាពមន្ត្រីបុគ្គលិកនៃនាយកដ្ឋានកិច្ចការពារប្រាក់បញ្ញើ។

**កិច្ចការពារអតិថិជននិងចំណេះដឹងផ្នែកហិរញ្ញវត្ថុ**

- បន្តកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ពាក់ព័ន្ធនឹងការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ ទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ដំណាក់កាលទី៣
- រៀបចំកម្មវិធីចែករំលែកចំណេះដឹងស្តីពី ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធនាគារ និងបរិយាបន្នហិរញ្ញវត្ថុ នៅតាមសាកលវិទ្យាល័យធំៗតាមបណ្តាខេត្តនានា
- រៀបចំសិក្ខាសាលាស្តីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន" សម្រាប់ថ្នាក់ខេត្ត និងថ្នាក់ស្រុកជូនអាជ្ញាធរមូលដ្ឋាន
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រមូលធាតុចូល ស្តីពី "ការប្រើប្រាស់ផលិតផល និងសេវាហិរញ្ញវត្ថុ" ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុជូនដល់កម្មករ-កម្មការិនី នៅរោងចក្រចំនួន ៧ ក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដើម្បីបង្កើនការយល់ដឹងអំពីការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ និងជៀសវាងការប្រើប្រាស់ឥណទានក្រៅផ្លូវការ
- រៀបចំសិក្ខាសាលា ស្តីពី "ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ" ជូននិស្សិតនៃបណ្តាគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេស
- រៀបចំទិវាសន្សំអាស៊ាន
- រៀបចំវីដេអូអប់រំពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន
- រៀបចំកម្មវិធីទូរសព្ទចល័តសម្រាប់ការគណនាអត្រាការប្រាក់ ដើម្បីជំរុញតម្លាភាពក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ
- សហការជាមួយ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ដើម្បីរៀបចំគម្រោងកម្មវិធីប្រកួតប្រជែងស្វែងរកដំណោះស្រាយបញ្ហាប្រឈមក្នុងបរិយាបន្នហិរញ្ញវត្ថុ និងគម្រោងកម្មវិធីកិច្ចប្រជុំកំពូលស្តីពី ចំណេះដឹងផ្នែកហិរញ្ញវត្ថុឌីជីថល និង
- សហការជាមួយអង្គការ Good Return ដើម្បីអនុវត្តយុទ្ធនាការ "គោះ! និយាយពីលុយ" ដំណាក់កាលទី៣។

## ៧- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- បន្តរៀបចំនិងសម្របសម្រួលការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្ម លើកទី២
- បន្តអនុវត្តការចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះបុគ្គលរាយការណ៍ដែលស្ថិតក្នុងវិស័យធនាគារ មូលបត្រ ធានារ៉ាប់រង បរធនបាលកិច្ច អចលនវត្ថុ និងកាស៊ីណូ
- បន្តរៀបចំឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យសម្រាប់វិស័យអចលនវត្ថុ កាស៊ីណូ និង មេធាវី
- បន្តអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យាដើម្បីសម្រួលដល់ការងារវិភាគ និងការងារត្រួតពិនិត្យ
- បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ លើការងារប្រឆាំង ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បន្តពង្រឹងសមត្ថភាពមន្ត្រី ស.ហ.ក. និង
- បន្តសហការលើការងារបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង ជាមួយ ក្រសួង-ស្ថាប័ន ក្នុងស្រុក និងដៃគូអន្តរជាតិ។

## ៨- ការងារប្រតិបត្តិការទីផ្សាររូបិយវត្ថុ

- បន្តការដាក់ឱ្យដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) និង មូលបត្រអាចជួញដូរបាន (NCD) តាមកាលវិភាគដែលបានកំណត់
- បន្តអនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF)
- បន្តអភិវឌ្ឍទីផ្សារអន្តរធនាគារតាមរយៈការវាយតម្លៃទីផ្សារ សិក្សាលើឧបករណ៍ហិរញ្ញវត្ថុថ្មីៗ និងជំរុញសកម្មភាពប្រតិបត្តិការជួញដូរក្នុងថ្នាលធនាគារជាតិនៃកម្ពុជា (NBCP)
- បន្តរៀបចំការបណ្តុះបណ្តាល និងពង្រឹងការផ្សព្វផ្សាយអំពីក្របខណ្ឌប្រតិបត្តិការរូបិយវត្ថុ ដល់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ដើម្បីជំរុញប្រសិទ្ធភាពការអនុវត្តនយោបាយរូបិយវត្ថុ
- បន្តអភិវឌ្ឍមុខងារ និងលំហូរប្រតិបត្តិការរបស់ NBCP
- ត្រៀមអនុវត្តប្រតិបត្តិការទីផ្សារចំហ
- អនុវត្តយន្តការអង្កេតទីផ្សារលើការគ្រប់គ្រងសន្ទនីយភាពក្នុងប្រព័ន្ធធនាគារតាមរយៈការ ស្ទង់មតិ និងកិច្ចពិភាក្សាជាមួយសមាជិក NBCP ដើម្បីតាមដានសន្ទនីយភាព និងពង្រឹង ប្រសិទ្ធភាពការព្យាករណ៍សន្ទនីយភាព។

## ៩-ការងារសេវាធនាគារ

- បន្តគាំទ្រការធ្វើសន្ទានកម្មប្រព័ន្ធទូទាត់ បណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធទូទាត់ និង ត្រៀមលក្ខណៈចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ថ្មីៗ
- បន្តសហការជាមួយក្រុមការងារពាក់ព័ន្ធនឹងការផ្លាស់ប្តូរ E-Token ពី Alladin ទៅ Yubikey ការរៀបចំផែនការនិរន្តភាពប្រព័ន្ធទូទាត់ និងការរៀបចំវិធាននិងនីតិវិធីប្រព័ន្ធទូទាត់សងប្រាក់រួម
- បន្តបង្កើនប្រសិទ្ធភាពសេវាគ្រប់គ្រងគណនីតាមប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS) តាមប្រព័ន្ធ ទទួលចំណូលតាម KHQR និងតាមបញ្ជរទទួលអតិថិជន

- សិក្សាពីលទ្ធភាពក្នុងការផ្តល់សេវាធនាគារកណ្តាលតាមប្រព័ន្ធឌីជីថល
- ដាក់ឱ្យអនុវត្តលំហូរប្រតិបត្តិការបញ្ញាផ្ទេរឥណទានរបស់អគ្គនាយកដ្ឋានរតនាគារជាតិ តាមច្រកនៃប្រព័ន្ធទូទាត់បាគង ទៅគណនីអ្នកទទួលផលនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ប្រព័ន្ធធនាគារអេឡិចត្រូនិក (OBS) សម្រាប់ការទូទាត់ត្រង់របស់ក្រសួង-ស្ថាប័នរដ្ឋ តាមច្រកប្រព័ន្ធបាគង ដើម្បីកាត់បន្ថយការប្រើប្រាស់មូលប្បទានប័ត្រ
- ដាក់ឱ្យអនុវត្តសារស្វីហ្វទម្រង់ MX សម្រាប់ប្រតិបត្តិការផ្ទេរប្រាក់ទៅក្រៅប្រទេស តាមប្រព័ន្ធស្វីហ្វ
- បន្តផ្សព្វផ្សាយជាទៀងទាត់នូវផែនការបោះផ្សាយមូលបត្ររដ្ឋ និងបន្តសម្របសម្រួលបោះផ្សាយមូលបត្ររដ្ឋឱ្យសម្រេចបានតាមផែនការនៃការបោះផ្សាយមូលបត្ររដ្ឋឆ្នាំ២០២៥
- បន្តសហការ និងសម្របសម្រួលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ធ្វើប្រតិបត្តិការក្នុងថ្នាលធនាគារជាតិនៃកម្ពុជា (NBCP)
- បន្តរៀបចំយន្តការជួញដូរមូលបត្ររដ្ឋក្នុងទីផ្សារបន្ទាប់ តាមរយៈថ្នាលធនាគារជាតិនៃកម្ពុជា សំដៅបង្កើតឱ្យបាននូវទីផ្សារបន្ទាប់ដែលមានលក្ខណៈពេញលេញ សន្ទនីយភាពខ្ពស់ ថ្លៃប្រតិបត្តិការ និងហានិភ័យទាប
- បន្តសហការរៀបចំកិច្ចពិគ្រោះយោបល់ដើម្បីស្វាបស្ទង់ទីផ្សារជាមួយវិនិយោគិនមូលបត្ររដ្ឋជាប្រចាំ និង
- សិក្សាលើលទ្ធភាពនៃការបោះផ្សាយមូលបត្ររដ្ឋដែលមានការការពារហានិភ័យអត្រាប្តូរប្រាក់។

## ១០- ការងារគ្រប់គ្រងសាច់ប្រាក់

- បន្តពង្រឹងសេវាបង់ និងបើកសាច់ប្រាក់ឱ្យកាន់តែល្អប្រសើរ
- ពង្រឹងការអនុវត្តការងារដឹកជញ្ជូនធនបត្រឱ្យកាន់តែមានសុវត្ថិភាព
- បង្កើនលទ្ធភាពការរាប់ស្រាល់ជ្រើសក្រដាសប្រាក់ឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងការប្តូរក្រដាសប្រាក់ចាស់ ទក់ រហែកតាមរយៈប្រព័ន្ធបាគង
- បន្តលើកកម្ពស់ការងារគ្រប់គ្រងសាច់ប្រាក់ និងការថែរក្សាសុវត្ថិភាពឃ្លាំងប្រាក់ និង
- បន្តពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ការចរាចរក្រដាសប្រាក់ក្លែងក្លាយ។

## ១១- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

- អនុវត្តការងារសវនកម្មនិងអធិការកិច្ច ស្របតាមផែនការឆ្នាំ២០២៥ និងតាមការចាំបាច់
- ពិនិត្យ និងតាមដានការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធធនាគារស្នូលរបស់ធនាគារជាតិនៃកម្ពុជា
- ពិនិត្យនិងរៀបចំឡើងវិញនូវនីតិវិធីសវនកម្ម
- បន្តសិក្សានិងរៀបចំលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសវនដ្ឋានសម្រាប់ការធ្វើសវនកម្ម
- បន្តសិក្សាលទ្ធភាពបង្កើតអង្គភាពគ្រប់គ្រងហានិភ័យស្ថាប័ននៅធនាគារជាតិនៃកម្ពុជា និង
- បន្តពង្រឹងសមត្ថភាពមន្ត្រីសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចបន្ថែមទៀត ដើម្បីបង្កើនគុណភាពការងារ ស្របតាមនិន្នាការបច្ចុប្បន្ន។

## ១២- ការគ្រប់គ្រងសាខា

- បន្តផ្សព្វផ្សាយសេចក្តីសម្រេច ឬការណែនាំរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ដល់បណ្តាសាខាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់
- បន្តតាមដាន និងរាយការណ៍ពីការវិវត្តនៃសកម្មភាពការងារ និងបញ្ហាប្រឈមទាំងឡាយជូនថ្នាក់ដឹកនាំ និង
- បន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានប្រចាំសាខារាជធានី-ខេត្ត សំដៅជំរុញការប្រើប្រាស់ប្រាក់រៀល និងសេវាទូទាត់ប្រព័ន្ធបាគង ឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

## ១៣- ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស

- បន្តកែលម្អក្របខ័ណ្ឌគោលនយោបាយគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា
- បច្ចុប្បន្នកម្មបទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌វិជ្ជាជីវៈ និងលក្ខន្តិកៈដោយឡែកមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា
- បន្តរៀបចំផែនការបណ្តុះបណ្តាលប្រចាំឆ្នាំឱ្យកាន់តែមានសង្គតិភាព
- បន្តរៀបចំគោលនយោបាយលើកទឹកចិត្តមន្ត្រីបុគ្គលិកស្របតាមសមិទ្ធផលការងារ
- ជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈវគ្គសិក្សានានាទាំងអនឡាញ និងសិក្សាផ្ទាល់ និង
- ពង្រឹងការងារចាត់តាំងមន្ត្រីបុគ្គលិក ស្របតាមគោលនយោបាយយុទ្ធសាស្ត្រ និងតម្រូវការការងារជាក់ស្តែងរបស់ធនាគារជាតិនៃកម្ពុជា។

## ១៤- កិច្ចសហប្រតិបត្តិការអន្តរជាតិ

- សហការរៀបចំកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំជាមួយធនាគារកណ្តាលឡាវ និងធនាគាររដ្ឋវៀតណាម
- សហការរៀបចំនិងសម្របសម្រួលបេសកកម្មពិគ្រោះយោបល់មាត្រា IV របស់មូលនិធិរូបិយវត្ថុអន្តរជាតិ
- ពង្រីកកិច្ចសហការទ្វេភាគីជាមួយធនាគារកណ្តាលជាដៃគូក្នុងតំបន់
- ពង្រឹងបន្ថែមការធ្វើសមាហរណកម្មហិរញ្ញវត្ថុទៅក្នុងអាស៊ាន និងតំបន់ផ្សេងៗ និង
- ពង្រឹងកិច្ចសន្ទនាជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងដៃគូអភិវឌ្ឍន៍។

## ១៥- ការងារស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច

- រៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី១២ របស់ធនាគារជាតិនៃកម្ពុជា
- បន្តធ្វើបច្ចុប្បន្នភាពសូចនាករគន្លឹះ វាយតម្លៃស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងព្យាករអំពីការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លីខាងមុខ (Nowcasting and Near-term Forecasting) សម្រាប់ឆ្នាំ២០២៥ និង២០២៦
